ISSN 1560-7615 / ISBN 978-99950-52-06-5

# ទស្សនាវដ្តីអភិវឌ្ឍន៍កម្ពុជា

ឯកសារបោះពុម្ពផ្សាយរបស់
វិទ្យាស្ថានបណ្តុះបណ្តាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា

ឆ្នាំទី ១៦ លេខ ៣ | តុលា ឆ្នាំ២០១២ | តម្លៃ ១.៥០០៛

# បញ្ហាប្រឈមចំពោះជីវភាពរស់នៅតាមតំបន់ជនបទ ក្នុងបរិបទនៃការផ្លាស់ប្តូរអាកាសធាតុ[១]

## សេចក្តីផ្តើម

ក្រោមក្របខ័ណ្ឌនៃអភិបាលកិច្ចល្អ និងកំណើនសម្រាប់គ្រប់គ្នា ដែលក្នុងនោះសិទ្ធិពេញច្បាប់លើធនធានធម្មជាតិ និងអត្ថប្រយោជន៍បានពីធនធានទាំងនោះ ត្រូវបានបែងចែកប្រកបដោយសមធម៌ និងចីរភាព ទៅដល់គ្រប់វិស័យក្នុងសង្គម ហើយការគ្រប់គ្រងធនធានធម្មជាតិបានបង្វែរការយកចិត្តទុកដាក់ ចេញពីផលិតភាព ទៅផ្តោតលើចីរភាពនៃធនធានវិញ។ ប្រការនេះបាននាំឲ្យមានការគិតគូរពី ទំនាក់ទំនងនៃវិស័យសេដ្ឋកិច្ច សង្គម និងបរិស្ថាន ទៅនឹងការអភិវឌ្ឍប្រកបដោយចីរភាព ដែលទទួលស្គាល់ថា ប្រព័ន្ធអេកូឡូស៊ីល្អ ជាមូលដ្ឋានគ្រឹះសម្រាប់ សុខមាលភាពសង្គមនិងសេដ្ឋកិច្ច និងការកាត់បន្ថយភាពក្រីក្រ (Saad-Filho 2010; Ianchovichina & Lundstrom 2009; Davidson *et al.* 2006)។ ចក្ខុវិស័យសាកល នៅពីក្រោយទស្សនៈថ្មីនេះគឺ "...ពិភពលោកមួយប្រកបដោយចីរភាពផ្នែកសេដ្ឋកិច្ច សង្គម និងបរិស្ថាន ហើយក្នុងនោះ កំណើនសេដ្ឋកិច្ចអាចសម្រេចបានក្នុងលក្ខខណ្ឌដែលទទួលស្គាល់នូវ គោលបំណងសង្គមនៃការលុបបំបាត់ភាពក្រីក្រ ការពង្រឹងសមធម៌សង្គម និងក្នុងលក្ខខណ្ឌសមត្ថភាពទ្រទ្រង់ជីវិតរបស់ធម្មជាតិ និងកសាងពិភពលោកមួយដែលបញ្ហាប្រឈមផ្សេងៗ ដូចជា ការផ្លាស់ប្តូរអាកាសធាតុ ការបាត់បង់ជីវចម្រុះ និងវិសមភាពសង្គមត្រូវបានដោះស្រាយដោយជោគជ័យ" (UNEP 2012: 2)។

ស្របនឹងក្របខ័ណ្ឌទាំងនេះ កម្ពុជាបានប្តេជ្ញាចិត្តយ៉ាងមុតមាំធានាឲ្យមានការប្រើប្រាស់ និងគ្រប់គ្រងប្រកបដោយប្រសិទ្ធភាពលើធនធានធម្មជាតិ ដូចជា ព្រៃឈើ ទឹក ដី ជលផល និងជីវចម្រុះ។ ការប្តេជ្ញាចិត្តនេះផ្តល់នូវ គោលដៅជាយុទ្ធសាស្ត្រនៃការដាក់បញ្ចូលការគ្រប់គ្រងធនធានធម្មជាតិ ទៅក្នុងផែនការអភិវឌ្ឍសេដ្ឋកិច្ចទូទៅ ដើម្បីទទួលបានផលិតភាពប្រកបដោយចីរភាព និងអត្ថប្រយោជន៍រយៈពេលវែង ពីធនធានធម្មជាតិរបស់កម្ពុជា។ គោលនយោបាយ និងយុទ្ធសាស្ត្រសំដៅធានាដល់ការអភិវឌ្ឍ



ប្រព័ន្ធធារាសាស្ត្រជួយបង្កើនភាពធន់ទ្រាំនឹងការធ្លាក់ភ្លៀង កាន់តែមិនទៀងទាត់ ប្រព័ន្ធធារាសាស្ត្ររលួស ខេត្តកំពង់ធំ ខែមិថុនា ២០១២។

និងកំណើនសេដ្ឋកិច្ចប្រកបដោយចីរភាព ការកាត់បន្ថយភាពក្រីក្រ និងចីរភាពបរិស្ថាន ត្រូវបានកំណត់ឡើងនៅក្នុងគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍របស់កម្ពុជា។ ទោះយ៉ាងនេះក្តី ផលប៉ះពាល់បង្កដោយការផ្លាស់ប្តូរអាកាសធាតុ មានជាអាទិ៍ គ្រោះរាំងស្ងួត ទឹកជំនន់ កំណើនសីតុណ្ហភាព ក៏ដូចជា ការផ្លាស់ប្តូរបណ្តាលមកពីសកម្មភាពអភិវឌ្ឍន៍របស់មនុស្ស ដូចជា ការកែប្រែដីព្រៃ ការកាប់ឈើ និងនេសាទខុសច្បាប់ កំពុងបង្កហានិភ័យដល់សមត្ថភាពទ្រទ្រង់រយៈពេលវែងនៃធនធានធម្មជាតិនៅសេសសល់ (MoE &

## មាតិកា

បញ្ហាប្រឈមចំពោះជីវភាពរស់នៅតាមតំបន់ជនបទ ក្នុងបរិបទនៃការផ្លាស់ប្តូរអាកាសធាតុ ............................ ១
ឥណទានសម្រាប់កសិករដាំស្រូវ៖ ករណីសិក្សានៅខេត្តតាកែវ . ៦
ចំណេះដឹង អាកប្បកិរិយា និងការអនុវត្តរបស់គ្រួសារនៅជនបទ ពាក់ព័ន្ធនឹងទឹកស្អាត សុខភាព និងអនាម័យ ...... ១០
តាមដានសេដ្ឋកិច្ច — ស្ថានភាពក្រៅប្រទេស ..................... ១៥
— ស្ថានភាពក្នុងប្រទេស....................... ១៧
ព័ត៌មានថ្មីៗពីវិទ្យាស្ថាន CDRI ....................................... ២៤

[១] អត្ថបទនេះរៀបរៀងដោយលោក ណាំង ភិរុណ ជាអ្នកស្រាវជ្រាវក្នុងកម្មវិធីធនធានធម្មជាតិ និងបរិស្ថាន នៃវិទ្យាស្ថាន CDRI។

UNDP 2011; RGC 2010a)។ ប្រជាជននៅទីជនបទដែលមានជីវភាពពឹងផ្អែកលើធនធានធម្មជាតិ និងការដាំដុះ នឹងត្រូវតស៊ូយ៉ាងលំបាក ដើម្បីទប់ទល់នឹងឥទ្ធិពលមិនល្អនៃការប្រែប្រួលផ្លាស់ប្តូរអាកាសធាតុ។ ក្រុមប្រជាជនខ្លះ ដូចជា ស្ត្រី គ្រួសារមាននារីជាមេគ្រួ មនុស្សចាស់ និងជនពិការជាដើម ងាយរងគ្រោះខ្លាំងពីផលប៉ះពាល់នៃការផ្លាស់ប្តូរអាកាសធាតុ ហើយទំនងត្រូវជួបការលំបាកកាន់តែខ្លាំងឡើង។

ការសិក្សានេះ ពិនិត្យពីបញ្ហាប្រឈមនានាដែលអាចបង្កឡើងពីការផ្លាស់ប្តូរអាកាសធាតុទៅលើធនធានចម្បងៗសម្រាប់ទ្រទ្រង់ជីវភាពប្រជាជននៅទីជនបទ និងព្យាយាមស្វែងរកមធ្យោបាយកាន់តែប្រសើរ ដើម្បីកាត់បន្ថយភាពងាយរងគ្រោះ ពង្រឹងសមត្ថភាពបន្សាំ ក៏ដូចជា ធានាស្ថិរភាពជីវភាពប្រជាជន នៅចំពោះមុខការប្រែប្រួលផ្លាស់ប្តូរអាកាសធាតុកាន់តែខ្លាំងឡើងនេះ។

## ភាពស្មុគស្មាញបង្កដោយបម្រែបម្រួលអាកាសធាតុទៅលើជីវភាពរស់នៅ

### និយមន័យពាក្យ បម្រែបម្រួលអាកាសធាតុ និងជីវភាពរស់នៅ

សម្រាប់គោលដៅនៃការសិក្សានេះ ពាក្យ "ការផ្លាស់ប្តូរអាកាសធាតុ" សំដៅដល់ "ការផ្លាស់ប្តូរណាមួយនៃអាកាសធាតុពីមួយឆ្នាំទៅមួយឆ្នាំ ដោយសារទាំងការប្រែប្រួល និងការផ្លាស់ប្តូរធម្មជាតិ ឬដោយសារសកម្មភាពមនុស្ស" (IPCC 2001: 984) ហើយពាក្យ "ជីវភាពរស់នៅ" សំដៅដល់ "មធ្យោបាយដែលគ្រួសារនីមួយៗ ទទួលនិងរក្សាបាននូវលទ្ធភាពប្រើប្រាស់ធនធានចាំបាច់ ដើម្បីធានាជីវភាពរស់នៅក្នុងរយៈពេលខ្លី និងរយៈពេលវែង។ ធនធានដ៏ចាំបាច់ទាំងនេះ អាចជា ធនធានរូបវ័ន្ត ធម្មជាតិ មនុស្ស ហិរញ្ញវត្ថុ សង្គម និងនយោបាយ។ គ្រួសារនីមួយៗប្រើប្រាស់ធនធានទាំងនេះ ដើម្បីបង្កើនសមត្ថភាពក្នុងការទប់ទល់នឹងផលប៉ះពាល់ និងការគ្រប់គ្រងលើហានិភ័យដែលគំរាមកំហែងដល់សុខមាលភាពរបស់ខ្លួន" (USAID 2005: 2)។

### ធនធានសំខាន់ៗសម្រាប់ទ្រទ្រង់ដល់ជីវភាពនៅទីជនបទ

ផ្អែកលើបញ្ហាប្រឈមសំខាន់ៗ នៃការផ្លាស់ប្តូរអាកាសធាតុ និងការផ្លាស់ប្តូរបណ្តាលមកពីសកម្មភាពមនុស្ស ដែលគំរាមកំហែងដល់ចីរភាពនៃធនធានទ្រទ្រង់ជីវភាពសំខាន់ៗ ការសិក្សានេះ ពិនិត្យជាសង្ខេបពីស្ថានភាពបច្ចុប្បន្នក្នុងវិស័យ (១) កសិកម្ម និង (២) ធនធានធម្មជាតិ (ទឹក គម្របដី/ព្រៃឈើ និងជលផល)។

### វិស័យកសិកម្ម

ការផ្លាស់ប្តូរអាកាសធាតុ មិនត្រឹមតែប៉ះពាល់ខ្លាំងទៅលើប្រទេសកំពុងអភិវឌ្ឍ និងប្រជាជនក្រីក្រប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងប៉ះពាល់ដល់ទិដ្ឋភាពសង្គម និងសេដ្ឋកិច្ច នៃការអភិវឌ្ឍប្រកបដោយចីរភាពទៀតផង។ នៅតំបន់អាស៊ី ការផ្លាស់ប្តូរអាកាសធាតុ និងការប្រែប្រួលធាតុអាកាសកាន់តែខ្លាំងនាពេលអនាគត នឹងប៉ះពាល់ដល់វិស័យកសិកម្ម និងបង្កើនហានិភ័យនៃកង្វះទឹកសាប និងស្បៀងអាហារ (IPCC 2007a)។ បញ្ហានេះពិតជានឹងកើតមានឡើង សម្រាប់ប្រទេសកម្ពុជាដែលមានប្រជាជនភាគច្រើន ជាពិសេសជនក្រីក្រនៅជនបទ ពឹងផ្អែកលើវិស័យកសិកម្មជាប្រភពចំណូលចម្បង។ កម្ពុជាបានរងគ្រោះជាញឹកញាប់ដោយសារទឹកជំនន់ ខ្យល់ព្យុះ និងការរាំងស្ងួតក្នុងមួយទសវត្សរ៍កន្លងទៅនេះ។ ទឹកជំនន់ បានប៉ះពាល់ធ្ងន់ធ្ងរដល់ដំណាំកសិកម្ម សត្វចិញ្ចឹម ជលផល ហេដ្ឋារចនាសម្ព័ន្ធលំនៅស្ថាន និងសុខមាលភាពប្រជាជន។ តួយ៉ាងនៅឆ្នាំ២០០៩ ខ្យល់ព្យុះទីហ្វុងកេតសាណា បានប៉ះពាល់ដល់ខេត្តចំនួន១០ ដោយបំផ្លាញផ្ទៃដីកសិកម្មអស់ ៤០.១៣៦ហិកតា និងធ្វើឲ្យខូចខាតផលស្រូវអស់ ៦៧.៣៥៥ហិកតា។ ការខូចខាតសរុបនៃ ផលកសិកម្ម/សត្វចិញ្ចឹម និងផលនេសាទ ដែលសំខាន់បំផុតសម្រាប់សន្តិសុខស្បៀងនៅកម្ពុជានោះ មានតម្លៃរហូតដល់ ៥៦លានដុល្លារ (RGC 2010b)។ ទឹកជំនន់កាលពីឆ្នាំ២០១១ បណ្តាលឲ្យស្លាប់មនុស្ស ២៥០នាក់ ព្រមទាំងប៉ះពាល់ដល់ ៣៥៤.២១៧គ្រួសារ និងធ្វើឲ្យខូចខាតផ្ទះ ១២៩៧ខ្នង។ ផលដំណាំក្នុងបណ្តាខេត្តនៅជុំវិញបឹងទន្លេសាប រងការខូចខាតយ៉ាងធ្ងន់ធ្ងរ។ ការខាតបង់ រួមមាន ការខូចខាតដំណាំស្រូវ ៤៣១.៤៧៦ហិកតា ដោយមានផ្ទៃដីដាំស្រូវ ២៦៧.១៨៤ហិកតា ត្រូវខូចខាតទាំងស្រុង និងការខូចខាតដំណាំដទៃទៀត ២១.៩២៩ហិកតា ដោយមាន ១៧.២៦៤ហិកតា ត្រូវខូចផលអស់រលីង (RGC 2012)។

ដោយប្រើម៉ូដែលឥទ្ធិពលសេណារីយ៉ូ និងគម្រោងការអភិវឌ្ឍអាងស្តុកនានា គណៈកម្មការទន្លេមេគង្គ (MRC) បានគន់គូរថា កម្រិត (អប្បបរមា និងអតិបរមា) និងរយៈពេលនៃទឹកជំនន់តាមរដូវនៅក្នុងប្រព័ន្ធទន្លេសាប នឹងមានការផ្លាស់ប្តូរ (MRC 2010)។ MRC បានគណនាទៀតថា ពីឆ្នាំ១៩៦០ ដល់ ២០០៥ សីតុណ្ហភាពជាមធ្យម កើនឡើង ០,៨អង្សាសេ ដោយមានអត្រាកំណើនក្នុងមួយទសវត្សរ៍ ០,២០-០,២៣អង្សាសេ នៅរដូវប្រាំង និង ០,១៣-០,១៦អង្សាសេ នៅរដូវវស្សា ហើយនៅត្រឹមឆ្នាំ ២១០០ សីតុណ្ហភាពមធ្យមប្រចាំឆ្នាំ នឹងកើនឡើងប្រហែល ១,៤-៤,៣អង្សាសេ (MRC 2009)។ កំណើនសីតុណ្ហភាពនេះ នឹងនាំឲ្យបរិមាណភ្លៀងធ្លាក់ប្រចាំឆ្នាំមធ្យម ក្នុងរដូវវស្សាកើនឡើង រីឯទឹកជំនន់ និងគ្រោះរាំងស្ងួត ក៏កាន់តែធ្ងន់ធ្ងរ និងអូសបន្លាយយូរជាងមុន ហើយពួកសត្វចង្រៃ និងជំងឺផ្សេងៗក៏កាន់តែមានច្រើនពាសពេញដែរ។ ការផ្លាស់ប្តូរទាំងនេះ នឹងប៉ះពាល់ដល់ផលិតកម្មដំណាំ ធ្វើឲ្យទិន្នផលដំណាំអាចកើនឡើងនៅកន្លែងខ្លះ និងថយចុះនៅកន្លែងខ្លះទៀត (ibid)។ ការផ្លាស់ប្តូរអាកាសធាតុ បាននិងកំពុងប៉ះពាល់រួចហើយមកលើអាយុជីវិត និងជីវភាពរបស់បុគ្គល និងសហគមន៍។ កំណើនសីតុណ្ហភាពក្នុងពីរ-បីឆ្នាំចុងក្រោយនេះ បានប៉ះពាល់ដល់ដំណាំក្នុងខេត្តជាច្រើននៅកម្ពុជា។ គ្រោះរាំងស្ងួតនៅឆ្នាំ១៩៩៧/៩៨ បានបង្កការលំបាកខ្លាំងដល់កសិករ និងរុញច្រានពួកគាត់ឲ្យធ្លាក់ទៅក្នុងភាពក្រីក្រ ឬអាចបាត់បង់ជីវិតទៀតផង។ នៅចំកណ្តាលរដូវវស្សា តាមធម្មតាតែងមានការរាំងស្ងួតមួយរយៈពេលខ្លី ដែលអាចអូសបន្លាយជាគ្រោះរាំងស្ងួតធ្វើឲ្យខូចខាតដល់ដំណាំស្រូវរបស់កសិករជារឿយៗ។ គ្រោះរាំងស្ងួតអាក្រក់បំផុតមួយនៅកម្ពុជា ក្នុងឆ្នាំ២០០២ បានប៉ះពាល់លើ

ប្រជាជន ២លាននាក់ និងបង្កការខូចខាតសរុប ៣៨លានដុល្លារ (UNESCAP 2008)។

ការផ្លាស់ប្ដូរលំនាំធាតុអាកាសតាមរដូវ (ពិសេសសីតុណ្ហភាព និងទឹកភ្លៀង) បានបង្កការខូចខាតដល់គុណភាពបរិស្ថាន ដែលអាចនាំឲ្យកើតវាលខ្សាច់ និងជះឥទ្ធិពលទៅលើរដូវដាំដុះ ហើយអាចធ្វើឲ្យកសិករថយចុះទំនុកចិត្តក្នុងការដាំដំណាំ និងគ្រប់គ្រងផលិតកម្ម។ បញ្ហាប្រឈមទាំងនេះ ប៉ះពាល់ជាពិសេសទៅលើស្ត្រី ដែលដើរតួនាទីយ៉ាងសំខាន់ក្នុងការផ្ដល់/ផលិតស្បៀងអាហារ បំប៉នអាហារូបត្ថម្ភកុមារ ព្រមទាំងបង្កើតប្រាក់ចំណូលសម្រាប់គ្រួសារ។ ការសិក្សាមួយរបស់ CARE (2002) នៅខេត្តព្រៃវែង ដែលតែងមានទឹកជន់ជារៀងរាល់ឆ្នាំ បានបង្ហាញថា ទឹកជំនន់មិនត្រឹមតែបំផ្លាញទ្រព្យសម្បត្តិ និងដំណាំរបស់ស្ត្រីប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងបង្កើនបន្ទុកការងាររបស់ពួកគេទៀតផង។ ដោយសារពួកគេត្រូវចំណាយពេលកាន់តែច្រើន រកម្ហូបអាហារទទួលទាន (នៅឆ្ងាយពីភូមិ) សម្រាប់ក្រុមគ្រួសារ ដូច្នេះពួកគាត់មានពេលកាន់តែតិចសម្រាប់ធ្វើកសិកម្ម និងស្វែងរកចំណូលប្រចាំថ្ងៃ។ នៅទីបំផុត ពួកគាត់តែងត្រូវបង្ខំចិត្តទៅខ្ចីបុលពីគេ ដើម្បីដោះស្រាយបញ្ហា (CARE 2002)។ ករណីសិក្សាមួយទៀតធ្វើឡើងដោយអង្គការបណ្ដាញបរិស្ថាននារី (Women's Environmental Network 2010) ក៏បានបង្ហាញដែរថា ស្ត្រីមេម៉ាយ និងកុមារកំព្រាត្រូវជួបប្រទះការលំបាកជាខ្លាំង ក្នុងការទប់ទល់នឹងការផ្លាស់ប្ដូរអាកាសធាតុ។ ម្យ៉ាងវិញទៀត ដោយសារកង្វះអាហារូបត្ថម្ភដែលធ្វើឲ្យសុខភាព និងរាងកាយចុះខ្សោយស្រាប់នោះ ពួកគេងាយរងគ្រោះដោយជម្ងឺតម្កាត់ផ្សេងៗណាស់។

### ធនធានធម្មជាតិ

***(១) ទឹក***

ការវិភាគពីការផ្លាស់ប្ដូរអាកាសធាតុ (ឧទាហរណ៍ ការវាយតម្លៃ/ការកំណត់ពី ហានិភ័យនៃការផ្លាស់ប្ដូរអាកាសធាតុ និងជម្រើសសម្រាប់ការបន្សាំ) ដោយទីភ្នាក់ងារអភិវឌ្ឍន៍អន្តរជាតិដាណឺម៉ាក (DANIDA) និងការិយាល័យបម្រែបម្រួលអាកាសធាតុកម្ពុជា (CCCO) នៃក្រសួងបរិស្ថាន (MoE) ក្នុងឆ្នាំ២០០៨ បង្ហាញថា នៅកម្ពុជាភាពងាយរងគ្រោះចំពោះការផ្លាស់ប្ដូរអាកាសធាតុ មានកម្រិតខ្ពស់ ហើយសមត្ថភាពបច្ចុប្បន្នក្នុងការបន្សាំ និងដោះស្រាយផលប៉ះពាល់នៃបម្រែបម្រួលអាកាសធាតុ នៅមានកម្រិតនៅឡើយ (DANIDA 2008)។ កង្វះខាតទឹក អសន្តិសុខស្បៀង និងហានិភ័យកាន់តែខ្ពស់ ចំពោះសុខភាពនិងជីវិតមនុស្ស ដែលបង្កឡើងដោយការផ្លាស់ប្ដូរអាកាសធាតុ នឹងប៉ះពាល់ជាពិសេសទៅលើប្រជាជនក្រីក្រ និងប្រជាជនងាយរងគ្រោះ។ ការសិក្សាមួយដោយលោក ចែម និងសុមេធ (2011) បង្ហាញថា នៅកម្ពុជា កសិករតែងជួបកង្វះទឹកយ៉ាងខ្លាំងនៅរដូវប្រាំង ទោះបីនៅរដូវវស្សាមានទឹកប្រើប្រាស់ច្រើនហួរហៀរក្ដី។ ជម្លោះលើការប្រើប្រាស់ទឹករវាងសហគមន៍នៅខ្សែទឹកខាងលើ សហគមន៍នៅខ្សែទឹកខាងក្រោម និងក្រុមប្រើប្រាស់ទឹកផ្សេងៗទៀត តែងកើតមានឡើងគួរឲ្យកត់សម្គាល់ក្នុងរដូវប្រាំង។ ប្រព័ន្ធស្រោចស្រពដែលមានស្រាប់ ពុំមានសមត្ថភាពចែកចាយទឹកស្រោចស្រពប្រកបដោយសមធម៌ ឬក៏ពង្រឹងដល់ការអនុវត្តគោលនយោបាយគ្រប់គ្រងធនធានទឹក ឲ្យបានប្រកបដោយប្រសិទ្ធភាពនោះទេ (Chem & Someth 2011)។

របនាសម្ព័ន្ធស្រោចស្រព និងទំនប់វារីអគ្គិសនីនៅតំបន់ខ្សែទឹកខាងលើ បានបង្វែរលំហូរទឹក ហើយជាក់ស្ដែងបានធ្វើឲ្យដាច់ដំណើរការផ្នែកធារាសាស្ត្រ ដោយបានផ្លាស់ប្ដូរគុណភាព និងបរិមាណទឹក នាំឲ្យមានទឹកច្រើនពេក ឬតិចពេក និងរារាំងដល់ការផ្លាស់ទីរបស់ត្រី និងចលនាដីល្បប់។ ការផ្លាស់ប្ដូរក្នុងវដ្ដធារាសាស្ត្រ នឹងបង្កបញ្ហាស្មុគស្មាញដល់គុណភាពទឹក បរិមាណទឹកមានជាក់ស្ដែង និងការបែងចែកទឹក រវាងក្រុមអ្នកប្រើប្រាស់ផ្សេងៗនៅក្នុងអាងផ្ទៃរងទឹកភ្លៀង (MoE & UNDP 2011)។ ម្យ៉ាងទៀតដោយសារការគ្រប់គ្រង និងការធ្វើផែនការទឹកស្រោចស្រពពុំមានលក្ខណៈជាប្រព័ន្ធក្នុងកម្រិតអាងផ្ទៃរងទឹកភ្លៀង ដូច្នេះកង្វះទឹកនៅរដូវប្រាំងវាជាបញ្ហាចម្បងមួយដែលកើតមានឡើងជារៀងរាល់ឆ្នាំ (Chem & Someth 2011)។

សកម្មភាពមនុស្ស (ការកែប្រែព្រៃឈើសម្រាប់ធ្វើកសិកម្ម កសិ-ឧស្សាហកម្ម ការអភិវឌ្ឍវារីអគ្គិសនី) និងផលប៉ះពាល់នៃការផ្លាស់ប្ដូរអាកាសធាតុ (ទឹកជំនន់ គ្រោះរាំងស្ងួត) បានធ្វើឲ្យដីស្រទាប់លើសឹករេចរឹល និងហូរធ្លាក់ចុះពីតំបន់ដីខ្ពស់ ទៅតំបន់ទំនាប។ សំណឹកដីនេះ ថែមទាំងបង្កើនភក់ល្បប់ ព្រោះដាច់ជីវជាតិដី បង្កើនកំទេចថ្មនិងខ្សាច់ ហើយបង្កើនល្បឿនទឹកហូរ ព្រមទាំងកាត់បន្ថយគុណភាពទឹក និងផលិតភាពកសិកម្ម នៅតាមតំបន់ទីជំរាល។ ក្នុងកិច្ចប្រឹងប្រែងគ្រប់គ្រង និងការពារស្ថិរភាពធនធានធម្មជាតិ និងជីវចម្រុះឲ្យមានចីរភាព កន្លងមកមានច្បាប់ អនុក្រឹត្យ និងផែនការសកម្មភាពសំខាន់ៗមួយចំនួន ដូចជាសេចក្ដីព្រាងអនុក្រឹត្យស្ដីពី ការគ្រប់គ្រងអាងស្ទឹង និងសហគមន៍កសិករប្រើប្រាស់ទឹក សេចក្ដីព្រាងផែនការសកម្មភាពជាតិ (NAP 2011-20) ដើម្បីប្រយុទ្ធប្រឆាំងនឹងឱនភាពដី ច្បាប់ស្ដីពីតំបន់ការពារធនធានធម្មជាតិ ច្បាប់ស្ដីពីជលផល និងច្បាប់ស្ដីពីព្រៃឈើជាដើម ត្រូវបានបង្កើតឡើង។ មួយវិញទៀត អាងស្តុកទឹកនានាដែលខុសលក្ខណៈបច្ចេកទេសនៅតំបន់ការពារ និងអភិរក្សបឹងទន្លេសាប ១, ២ និង ៣ ត្រូវបានកំទេចចោល ហើយសម្បទានដីសេដ្ឋកិច្ចមួយចំនួន និងឡូត៍នេសាទឯកជនទាំងអស់ ក៏ត្រូវបានលុបចោលដែរ (MAFF 2012; MOWRAM 2011; Nang & Yem 2010)។

***(២) គម្របដី/ព្រៃឈើ***

ព្រៃឈើមានសារៈសំខាន់ណាស់ចំពោះ បរិស្ថានវដ្ដកាបូន និងប្រព័ន្ធអាកាសធាតុ ព្រមទាំងការទ្រទ្រង់ជីវភាពប្រជាជនមូលដ្ឋាន ដូចជា ការងារនៅតាមចំការដំណាំ និងក្នុងឧស្សាហកម្មព្រៃឈើ (ការកែច្នៃផលនិងអនុផលព្រៃឈើ) ការប្រមែប្រមូលផលព្រៃឈើសម្រាប់ជាអាហារ រុក្ខជាតិឱសថ និងសម្ភារៈប្រើប្រាស់ផ្សេងៗ ក៏ដូចជាការរកចំណូលអំពីផល/អនុផលព្រៃឈើក្នុងមូលដ្ឋាន និងទីផ្សារកាបូនផងដែរ (Maff 2009)។ ការផ្លាស់ប្ដូរអាកាសធាតុនឹងប៉ះពាល់ដល់ផលិតភាពព្រៃឈើ បង្កើនការបាត់បង់ជីវចម្រុះ និងពន្លឿនភាពរេចរឹលព្រៃឈើ រួមទាំងការបាត់បង់ភាពសើម និងស្ងួតនៃប្រព័ន្ធអេកូឡូស៊ីព្រៃឈើផងដែរ (MoE 2002; MRC

2009)។ក្រុមអន្តររដ្ឋាភិបាលផ្នែកបម្រែបម្រួលអាកាសធាតុ(IPCC) រាយការណ៍ថា ការរីករាលដាលនៃព្រៃឈើ និងការផ្លាស់ទីនៃព្រៃឈើ នឹងថយចុះ ហើយជីវចម្រុះនឹងទទួលរងការគំរាមកំហែង ដោយសារការផ្លាស់ប្តូរការប្រើប្រាស់ដី ការថយចុះគម្របព្រៃឈើ និងកំណើនប្រជាជន (IPCC 2007a)។ ការកាប់បំផ្លាញព្រៃឈើ សម្រាប់ការកសាងតំបន់ទីក្រុង កសិកម្ម និងការអភិវឌ្ឍផ្សេងៗ នឹងបណ្តាលឲ្យថយចុះចំនួនព្រៃឈើ ដែលត្រូវជួយស្រូបយកឧស្ម័នកាបូនឌីអុកស៊ីដ និងបញ្ចេញអុកស៊ីសែន។ កំណើនឧស្ម័នផ្ទះកញ្ចក់ និងការបំភាយឧស្ម័នកាបូនឌីអុកស៊ីដ ធ្វើឲ្យបរិយាកាសឡើងកំដៅ និងប្រែប្រួលកាន់តែខ្លាំង និងមិនទៀងទាត់ឡើង ហើយផលប៉ះពាល់នៃការផ្លាស់ប្តូរអាកាសធាតុ ក៏ប្រែប្រួលដូច្នេះដែរ។

ការថយចុះធនធានព្រៃឈើ ដោយសារកង្វះការគ្រប់គ្រងព្រៃឈើ និងការធ្វើផែនការប្រើប្រាស់ដី អាចមានផលវិបាកធ្ងន់ធ្ងរលើបរិយាកាសនិងជីវភាពនៅមូលដ្ឋាន សហគមន៍ពឹងផ្អែកលើព្រៃឈើ ជាពិសេសប្រជាជនដើមម្ចាស់ស្រុក។ ការកែប្រែដីព្រៃតែងនាំឲ្យមានការថយចុះភ្លាមៗនូវស្តុកកាបូននៃព្រៃឈើ (IPCC 2007b)។ ផ្ទៃដីព្រៃឈើកម្ពុជា បានថយចុះយ៉ាងច្រើន (Vong & Michael 2009) ដោយពីឆ្នាំ១៩៦៥ ដល់ ២០១០ គម្របព្រៃឈើនៅកម្ពុជា បានថយចុះអស់ ១៦% ហើយអត្រាបាត់បង់ព្រៃឈើប្រចាំឆ្នាំ មានកម្រិត 0,៥២% ក្នុងអំឡុងឆ្នាំ២០០២-២០១០ (MAFF 2012)។ កំណើនតាមការរំពឹងទុកសម្រាប់ផលិតកម្មដំណាំកសិ-ឧស្សាហកម្ម ជាពិសេសកៅស៊ូ ដំឡូងឈើ ដំឡូងផ្វា និងសណ្តែកសៀង ក្នុងប៉ុន្មានឆ្នាំខាងមុខនេះ នឹងនាំឲ្យមានការពង្រីកផ្ទៃដីដាំដុះដោយជៀសមិនរួច (Ros *et al.* 2011)។ ច្បាស់ណាស់ ប្រព័ន្ធចិញ្ចឹមជីវិតរបស់បណ្តាសហគមន៍នៅក្បែរតំបន់ដែលមានការកែប្រែផ្ទៃដីធំៗ នឹងត្រូវប៉ះពាល់ភ្លាមៗពីឥទ្ធិពលអាក្រក់នៃការផ្លាស់ប្តូរបង្កឡើងដោយមនុស្ស (ឧទាហរណ៍ ការដាក់កំហិតលើការប្រើប្រាស់ និងការត្រួតត្រាលើដីធ្លី ទឹក និងធនធានព្រៃឈើ) ជាជាង ដោយសារបម្រែបម្រួលអាកាសធាតុតាមលក្ខណៈធម្មជាតិ។ ប៉ុន្តែក្នុងរយៈពេលវែង កម្រិតជីវភាពរបស់ពួកគេ (ឧទាហរណ៍ ឱកាសការងារ ហេដ្ឋារចនាសម្ព័ន្ធ សេវាសាធារណៈ ដូចជា សាលារៀននិងមណ្ឌលសុខភាព ទីផ្សារ) ទំនងជានឹងបានល្អប្រសើរឡើង។

### *(៣) វិស័យជលផល (ទឹកសាប និង សមុទ្រ)*

ធនធានជលផលទាំងទឹកសាប និងទឹកប្រៃ មានសារៈសំខាន់ជាខ្លាំងសម្រាប់ជីវភាពប្រជាជនកម្ពុជា។ ការវិភាគបឋមពីផលប៉ះពាល់នៃកំណើនកម្ពស់ទឹកសមុទ្រ ១ម៉ែត្រ នៅតំបន់ឆ្នេររបស់កម្ពុជា ដោយក្រសួងបរិស្ថាន បានរកឃើញថា ខេត្តកោះកុងងាយរងគ្រោះជាងគេ ក្នុងចំណោម ៥ខេត្ត ដែលរំពឹងថា នឹងត្រូវទទួលរងឥទ្ធិពលនេះ។ ដោយហេតុថា តំបន់ឆ្នេរភាគច្រើនក្នុងខេត្តកោះកុង មានសណ្ឋានដីទាប ដូច្នេះប្រហែល 0,៤% នៃផ្ទៃដីទាំងអស់ក្នុងខេត្ត នឹងស្ថិតនៅក្រោមផ្ទៃទឹកជាអចិន្ត្រៃយ៍ ហើយព្រៃកោងកាង និងព្រៃផ្សេងទៀត រួមទាំងវារីវប្បកម្ម វាលស្មៅ និងកន្លែងរស់នៅជាច្រើនរបស់ប្រជាជនផង នឹងត្រូវរងការខូចខាតធ្ងន់ធ្ងរ (MoE 2002)។

អាងទន្លេសាប ជាតំបន់នេសាទទឹកសាបធំជាងគេនៅកម្ពុជា និងនៅតំបន់អាស៊ីអាគ្នេយ៍ទាំងមូល។ បម្រែបម្រួលផ្នែកជលសាស្ត្រ ក្នុងប្រព័ន្ធបឹងទន្លេសាប នឹងធ្វើឲ្យផ្លាស់ប្តូរខ្លាំងដល់ប្រព័ន្ធធម្មជាតិនៅក្នុងអាងទន្លេសាប។ ដោយឡែក ការរួមតូចនៃតំបន់លិចទឹកសរុប នឹងជះឥទ្ធិពលលើចង្វាក់ទឹកជំនន់ (ទឹកស្រក និងទឹកឡើង) នៃបឹងទន្លេសាបដែលទ្រទ្រង់ដល់រុក្ខជាតិ និងសត្វទឹកជាច្រើនប្រភេទ ហើយវាក៏នឹងរំខានដល់វដ្តនៃការដោះដូរជីវជាតិផ្សេងៗតាមលក្ខណៈធម្មជាតិ កាត់បន្ថយផលិតភាពប្រព័ន្ធអេកូឡូស៊ី និងធ្វើឲ្យធ្លាក់ចុះផលិតកម្មត្រី និងផលត្រី (MRC 2010)។ ឥទ្ធិពលគួបផ្សំគ្នានៃការនេសាទត្រីហួសកម្រិត ការផ្លាស់ប្តូរអាកាសធាតុ (របបទឹកភ្លៀង) បម្រែបម្រួលផ្នែកជលសាស្ត្រ (លំហូរ គុណភាព និងបរិមាណទឹក) និងការថយចុះកម្រិតជីវជាតិនៅក្នុងទន្លេមេគង្គ និងបឹងទន្លេសាប ត្រូវបានប្រមើលឃើញថា នឹងបំផ្លាញជម្រកត្រី និងស្តុកត្រី ដែលនាំទៅដល់ការផុតពូជត្រីមួយចំនួន (Ros *et al.* 2011)។

## ការពិភាក្សា និងសេចក្តីសន្និដ្ឋាន

បម្រែបម្រួលអាកាសធាតុ និងឥទ្ធិពលអវិជ្ជមានរបស់វា បានបង្កជាបញ្ហាប្រឈម ចំពោះជីវភាពប្រជាជនរស់នៅតាមជនបទ ប៉ុន្តែវានឹងមានផលប៉ះពាល់ជាក់លាក់អ្វីខ្លះ គេនៅមិនទាន់ដឹងច្បាស់លាស់នៅឡើយ។ ក្នុងមួយទសវត្សរ៍កន្លងទៅនេះ កម្ពុជាមានកំណើនសេដ្ឋកិច្ចរឹងមាំល្អ ប៉ុន្តែអាកាសធាតុប្រែប្រួលខ្លាំងពេកបានរារាំងដល់កិច្ចប្រឹងប្រែងកាត់បន្ថយវិសមភាពរវាង ប្រជាជនរស់នៅក្នុងតំបន់ទីក្រុង និងប្រជាជនរស់នៅតំបន់ជនបទ ក៏ដូចជាបានរារាំងដល់ កិច្ចប្រឹងប្រែងក្នុងការកាត់បន្ថយគំលាតរវាងអ្នកមាន និងអ្នកក្រផងដែរ (MoP 2010)។

វិស័យកសិកម្ម គួរទទួលបានការយកចិត្តទុកដាក់ច្រើនថែមទៀត ព្រោះវិស័យនេះ ជាធនធានទ្រទ្រង់ជីវភាពចម្បងនៅតាមជនបទ។ ការគ្រប់គ្រងដី និងទឹក ត្រឹមត្រូវ អាចរួមចំណែកជាវិជ្ជមានដល់សន្តិសុខទឹក (លទ្ធភាពទទួលបានទឹកគ្រប់គ្រាន់ និងមានគុណភាពល្អ) ផលិតកម្មដំណាំ និងភាពធន់នៃប្រព័ន្ធដាំដុះ (ឧទាហរណ៍ ពិពិធកម្មមុខចំណូល និងដំណាំដាំដុះ ជាពិសេសនៅក្នុងប្រព័ន្ធកសិកម្មដែលផ្អែកលើទឹកភ្លៀង) (Nang *et al.* 2011)។ តាមការព្យាករណ៍ នៅឆ្នាំ២០០៩ សហគមន៍ព្រៃឈើនៅកម្ពុជាត្រូវកើន ១១% ដោយមានចំនួនសរុបដល់ ៤០១សហគមន៍ និងគ្របដណ្តប់លើផ្ទៃដី ៣៨០.៥៨៧ហិកតា ឬប្រហែល ២% នៃផ្ទៃដីប្រទេសកម្ពុជា។ ប្រសិនបើអាចសម្រេចគោលដៅនេះបាន សហគមន៍ព្រៃឈើសរុប នឹងគ្របដណ្តប់លើផ្ទៃដីជាងពីរលានហិកតា ហើយចូលរួមចំណែកជួយដល់ជីវភាពរបស់ប្រជាជនមូលដ្ឋានផង និងជួយសម្រាលបន្ទុកនៃការប្រែប្រួលអាកាសធាតុផងដែរ (Vong & Dutschke 2009)។

ការធ្វើអាជីវកម្មលើវិស័យជលផលនៅតំបន់ឆ្នេរ និងនៅលំហសមុទ្រ មានលក្ខណៈលើសពីសមត្ថភាពកកើតឡើងវិញនៃធនធាន ហើយប្រសិនបើសកម្មភាពនេះនៅតែបន្តដោយគ្មានការ

ត្រួតពិនិត្យត្រឹមត្រូវនោះ វាអាចនឹងធ្វើឲ្យថយចុះពូជសត្វសមុទ្រ និងស្តុកត្រី ព្រមទាំងធ្វើឲ្យជីវភាពរបស់សហគមន៍នេសាទកាន់តែលំបាកខ្លាំងឡើង (Ros *et al.* 2011)។ ធនធានជលផលទឹកសាប និងជីវភាពរស់នៅរបស់ប្រជាពលរដ្ឋដែលពឹងផ្អែកលើធនធានទាំងនេះ កំពុងជួបបញ្ហាប្រឈមប្រហាក់ប្រហែលគ្នា។ កង្វះធនធានហិរញ្ញវត្ថុ និងសមត្ថភាពទាប បានរារាំងអ្នកនេសាទនៅតំបន់បឹងទន្លេសាបក្នុងការកែលំអជីវភាពរបស់ខ្លួន ទោះបីជារដ្ឋាភិបាលបានអនុវត្តកំណែទម្រង់ជលផលដ៏មោះមុត ដោយបានកែប្រែឡូត៍នេសាទឯកជនដល់ទៅ ៥៣៨.០០០ហិកតា (៥៦% នៃឡូត៍នេសាទឯកជនសរុប) ឲ្យប្រើប្រាស់ជាសាធារណៈក្តី (So *et al.* 2011)។ ជំនួយទ្រទ្រង់ពហុវិស័យ (ផ្នែកបច្ចេកទេស ហិរញ្ញវត្ថុ) ពីអ្នកពាក់ព័ន្ធគ្រប់គ្នា គួបផ្សំនឹងវិធានការតឹងរ៉ឹងពង្រឹងការអនុវត្តច្បាប់ មានសារៈសំខាន់បំផុតសម្រាប់ការការពារធនធានជលផល និងពង្រឹងជីវភាពប្រជាជននៅតាមជនបទ។ ទន្ទឹមគ្នានេះដែរ ត្រូវគិតគូរពីការធ្វើពិពិធកម្មមុខរបរចិញ្ចឹមជីវិត (អេកូទេសចរណ៍ ការដាំបន្លែ អាជីវកម្មខ្នាតតូច) ដើម្បីកាត់បន្ថយសំពាធលើធនធានជលផលដែលកំពុងតែមានការថយចុះនេះ (ibid)។

ក្នុងគំនិតផ្តួចផ្តើមនានាដើម្បី លើកកម្ពស់ជីវភាពរស់នៅ កាត់បន្ថយភាពក្រីក្រ និងបន្សាំទៅនឹងការផ្លាស់ប្តូរអាកាសធាតុ គួរមានគិតគូរពីផលប៉ះពាល់ផ្នែកសេដ្ឋកិច្ច សង្គម និងផលិតភាព នៃវិធានការការពារ និងកែលំអធនធានធម្មជាតិសំខាន់ៗ និងធានាឲ្យសហគមន៍មូលដ្ឋានមានលទ្ធភាពក្នុងការគ្រប់គ្រង និងប្រើប្រាស់ធនធានសំខាន់ៗទាំងនោះប្រកបដោយសមធម៌។ គោលនយោបាយសំដៅការពារបរិស្ថាន និងសុខភាពប្រព័ន្ធអេកូឡូស៊ី ត្រូវបានដាក់បញ្ចូលរួចហើយទៅក្នុងផែនការ និងការសម្រេចចិត្តផ្សេងៗក្នុងការអភិវឌ្ឍវិស័យកសិកម្ម ឧស្សាហកម្ម និងសេដ្ឋកិច្ច។ ការអភិវឌ្ឍប្រកបដោយចីរភាពផ្នែកបរិស្ថាន មានលក្ខណៈចាំបាច់បំផុតសម្រាប់ដោះស្រាយបញ្ហាប្រឈមនានា ដែលជាប់ទាក់ទងនឹងកំណើនសេដ្ឋកិច្ចសម្រាប់គ្រប់គ្នា វឌ្ឍនភាពសង្គម និងការកាត់បន្ថយភាពក្រីក្រ រីឯការបន្សាំទៅនឹងការផ្លាស់ប្តូរអាកាសធាតុ និងសម្រាលបម្រែបម្រួលអាកាសធាតុ ជាគន្លឹះដ៏សំខាន់មួយទៀតសម្រាប់ជួយទ្រទ្រង់ និងលើកកម្ពស់ជីវភាពប្រជាពលរដ្ឋនៅជនបទ។

កម្មវិធីកាត់បន្ថយហានិភ័យនៃគ្រោះមហន្តរាយ យុទ្ធសាស្ត្រឆ្លើយតប និងត្រៀមទប់ទល់នឹងមហន្តរាយនៃបម្រែបម្រួលអាកាសធាតុ ព្រមទាំងធនធានសំខាន់ៗ (ធនធានមនុស្ស ភ័ស្តុភារ ទូរគមនាគមន៍/ព័ត៌មាន) ត្រូវចាំបាច់រៀបចំឲ្យមាន ដើម្បីកំណត់ និងផ្តល់អាទិភាពច្បាស់ថា ត្រូវធ្វើសកម្មភាពនៅកន្លែងណា ពេលណា និងតាមរបៀបណា ហើយស្ថាប័នណា សហគមន៍ណា និងបុគ្គលណា ដែលគួរអនុវត្តយុទ្ធសាស្ត្រឆ្លើយតបនឹងកម្មវិធីបន្សាំទាំងនោះ។ ទាំងអស់នេះ គឺដើម្បីកាត់បន្ថយភាពមិនប្រាកដប្រជានៃការផ្លាស់ប្តូរអាកាសធាតុ និងឥទ្ធិពលរបស់វាទៅលើការផ្គត់ផ្គង់ទឹកនិងស្បៀងអាហារ ជីវភាពរស់នៅ និងសេដ្ឋកិច្ច។ ការចូលរួមរបស់រដ្ឋ វិស័យឯកជន សង្គមស៊ីវិល និងជាពិសេសការដាក់បញ្ចូលចំណេះដឹងរបស់ ប្រជាជនមូលដ្ឋាន/ប្រជាជនដើមភាគតិច ទៅក្នុងការធ្វើផែនការ ការអនុវត្តយុទ្ធសាស្ត្រ ធ្វើពិពិធកម្មមុខចំណូល ការប្រើប្រាស់ដី និងការដាំដុះ ដោយប្រើបច្ចេកវិទ្យាដែលមិនប៉ះពាល់ដល់ប្រព័ន្ធអេកូឡូស៊ី នឹងរួមចំណែកជួយទ្រទ្រង់ជីវភាពប្រជាជនមូលដ្ឋាន ព្រមទាំងកាត់បន្ថយផលប៉ះពាល់នៃការអភិវឌ្ឍ និងការផ្លាស់ប្តូរអាកាសធាតុផងដែរ។ ការបង្កើនសមត្ថភាពបន្សាំ ដើម្បីទប់ទល់នឹងបញ្ហាប្រឈមនានានៃការផ្លាស់ប្តូរអាកាសធាតុក្នុងរយៈពេលខ្លី និងរយៈពេលវែង គឺជាអាទិភាពបន្ទាន់មួយ ពិសេសក្នុងវិស័យកសិកម្ម និងការគ្រប់គ្រងធនធានធម្មជាតិ។ ម៉្យាងវិញទៀត ត្រូវមានស្ថាប័នប្រកបដោយប្រសិទ្ធភាពនៅគ្រប់កម្រិត ជាអាទិ៍នៅកម្រិតសហគមន៍ និងមូលដ្ឋាន ដើម្បីធ្វើផែនការ និងអនុវត្តសកម្មភាពបន្សាំ សំដៅពង្រឹងភាពធន់ទ្រាំចំពោះការផ្លាស់ប្តូរអាកាសធាតុ ជាពិសេស ដើម្បីជួយទ្រទ្រង់ក្រុមគ្រួសារក្រីក្រដែលពឹងផ្អែកលើធនធានធម្មជាតិ ស្ត្រី និងក្រុមជនងាយរងគ្រោះផ្សេងទៀតដែលមានសមត្ថភាព ទ្រព្យសម្បត្តិ និងធនធានតិចតួច ដើម្បីទប់ទល់នឹងបញ្ហាប្រឈមបង្កដោយបម្រែបម្រួលអាកាសធាតុ។

## ឯកសារយោង


CARE (2002), *Flood Impact on Women & Girls: Prey Veng Province, Cambodia* (Phnom Penh: CARE)

Chem P. & Someth P. (2011), *Use of Hydrological Knowledge and Community Participation for Improving Decision-making on Irrigation Water Allocation,* Working Paper Series No. 49 (Phnom Penh: CDRI)

DANIDA (2008), *Climate Change Screening of Danish Development Cooperation with Cambodia*, Ministry of Foreign Affairs of Denmark, DANIDA

IPCC (2001), *Climate Change 2001: Impacts, Adaptation and Vulnerability* - Contribution of Working Group II to the Second Assessment Report on Climate Change of the Intergovernmental Panel on Climate Change, http://www.grida.no/publications/other/ipcc_tar/ (accessed 12 July 2012)

IPCC (2007a), *Climate Change 2007: Impacts, Adaptation and Vulnerability* - Contribution of Working Group II to the Fourth Assessment Report on Climate Change of the Intergovernmental Panel on Climate Change [M.L. Parry, O.F. Canziani, J.P. Palutikof, P.J. van der Linden &C.E. Hanson (eds.)] (Cambridge,UK; New York: Cambridge University Press)

IPCC (2007b), *Climate Change 2007: Mitigation Options* -Contribution of Working Group III to the Fourth Assessment Report of the Intergovernmental Panel on Climate Change [B. Metz, O.R. Davidson, P.R. Bosch, R. Dave & L.A. Meyer (eds.)], *Chapter 9: Forestry* (Cambridge,


តទៅទំព័រ ២១

# ឥណទានសម្រាប់កសិករដាំស្រូវ៖ ករណីសិក្សានៅខេត្តតាកែវ[១]

## សេចក្តីផ្តើម

កង្វះលទ្ធភាពរបស់កសិករក្នុងការទទួលបានទុនបង្វិល និង មូលធនវិនិយោគ ជាកត្តាចម្បងដែលរារាំងដល់ការឈានឡើង ពីប្រព័ន្ធកសិកម្មប្រើធាតុចូលតិច ទៅកាន់ប្រព័ន្ធមានផលិតភាពខ្ពស់ជាងមុន (ACI 2005)។ មីក្រូហិរញ្ញវត្ថុ បានរីកដុះដាលខ្លាំងនៅកម្ពុជា ប៉ុន្តែការផ្តល់សេវាឥណទានទៅដល់កសិករតូចតាចនៅមានកម្រិតទាប ដោយសារហានិភ័យកើតចេញពីអសន្តិសុខនៃសិទ្ធិកាន់កាប់ដីធ្លី និងភាពមិនប្រាកដប្រជានៃផលត្រឡប់បានពីវិនិយោគលើកសិកម្ម។ ទន្ទឹមគ្នានេះ ផលិតភាពស្រូវនៅកម្ពុជានៅមានកម្រិតទាប ដោយសារការប្រើប្រាស់ធាតុចូលកសិកម្មតិចតួច ដូចជា ជី គ្រឿងយន្ត និងការស្រោចស្រព (ACI 2005; Wold Bank 2007)។ ដូច្នេះ ការសម្រួលបង្កើនលទ្ធភាពទទួលបានឥណទានជនបទ ជាជំហានទៅមុខដ៏សំខាន់មួយសម្រាប់ការអភិវឌ្ឍកសិកម្ម។ ការយល់ដឹងពីលំនាំនៃការទទួលបានឥណទាន និងបែបបទដែលវាជះឥទ្ធិពលទៅលើការសម្រេចចិត្តខ្ចីបុលរបស់កសិករ ជាព័ត៌មានដ៏មានប្រយោជន៍សម្រាប់កំណត់ជម្រើសគោលនយោបាយផ្សេងៗ សំដៅជួយកែលំអលទ្ធភាពអាចរស់រាននៃប្រព័ន្ធផ្តល់ឥណទាននៅតំបន់ជនបទ។

សម្មតិកម្មនៃការស្រាវជ្រាវនេះគឺលទ្ធភាពទទួលបានឥណទានជួយបង្កើនផលិតភាពរបស់កសិករដាំស្រូវ និងចំណូលពីការដាំដុះ ហើយនឹង ជួយលើកកម្ពស់សុខុមាលភាពគ្រួសារនៅតាមជនបទ និងកាត់បន្ថយភាពងាយរងគ្រោះ។ ការសិក្សានេះព្យាយាម (១) ស្វែងយល់ពីលំនាំ និងលក្ខណៈនៃលទ្ធភាពទទួលបានឥណទានរបស់កសិករខុសៗគ្នា (២) ពិនិត្យស្រាវជ្រាវពីផលប៉ះពាល់នៃឥណទានទៅលើជីវភាពរស់នៅរបស់កសិករ និងប្រព័ន្ធផលិតកម្ម (៣) កំណត់ពីបញ្ហាប្រឈម និងឱកាសសម្រាប់ការប្រើប្រាស់ឥណទានឲ្យបានជោគជ័យ និង (៤) ផ្តល់ជាជម្រើសសំខាន់ៗសម្រាប់លើកកម្ពស់លទ្ធភាពទទួលបានឥណទាន និងជំរុញការប្រើប្រាស់ឥណទានបម្រើការដាំដុះឲ្យបានជោគជ័យ។

## ប្រព័ន្ធដាំដុះស្រូវនៅខេត្តតាកែវ

នៅខេត្តតាកែវ មានប្រព័ន្ធកសិកម្មដំណាំស្រូវចម្បងពីរគឺ ដីទំនាបគ្មានការស្រោចស្រព និង ដីទំនាបមានការស្រោចស្រព (UNCDF 2011)។ ស្រុកចំនួន ៤ គឺគិរីវង់ កោះអណ្តែត បូរី

រូបភាព ១៖ ផែនទីតំបន់សិក្សា




ប្រភព៖ អ្នកនិពន្ធកសាងឡើងដោយប្រើផែនទីជំរឿនថ្នាក់ជាតិ (NIS 2008)

ជលសារ និងអង្គរបុរី នាំមុខគេក្នុងការដាំស្រូវប្រាំង ដោយសារមានធម្មជាតិអំណោយផល ដូចជា ការផ្គត់ផ្គង់ទឹកជាប់លាប់ល្អ និងទីតាំងនៅជិតព្រំដែនវៀតណាម ងាយឲ្យកសិករទទួលបានធាតុចូលកសិកម្ម និងទីផ្សារ។ ស្រុកទាំង៤ មានផ្ទៃដីដាំដុះសរុប ២៤៨.២២៨ហិកតា ក្នុងនេះប្រមាណ ៩១៣៩ហិកតា ជាដីមានប្រព័ន្ធស្រោចស្រព ៩៧.៥០៥ហិកតា ជាតំបន់ស្រូវឡើងទឹក ហើយក្រៅពីនោះ ជាដីគ្មានប្រព័ន្ធស្រោចស្រព និងប្រើសម្រាប់ដំណាំផ្សេងទៀត។ ទិន្នផលជាមធ្យមក្នុងឆ្នាំ២០១១ គឺ ២,៥៣តោន/ហិកតា សម្រាប់ស្រូវវស្សា និង ៣,៣តោន/ហិកតា សម្រាប់ស្រូវប្រាំង។ ផលិតកម្មស្រូវសរុបក្នុងឆ្នាំ២០១១ គឺ ១.១០៥.០៣១តោន ដែលនាំឲ្យមានអតិរេកស្រូវប្រមាណ ៨០០.០០០តោន ឬស្មើនឹង ១៧,៦១% នៃអតិរេកស្រូវសរុប ក្នុងទូទាំងប្រទេស (UNCDF 2011)។

ការដាំដុះស្រូវនៅខេត្តតាកែវ កំពុងផ្លាស់ប្តូរពីលក្ខណៈជាប្រពៃណីសម្រាប់មួយរស់ ទៅជាលក្ខណៈពាណិជ្ជកម្ម (Oveson *et al.* 2012) ដែលគេអាចពិនិត្យឃើញតាមការបោះបង់ធាតុចូលជាប្រពៃណីជាបណ្តើរៗ ទៅប្រើ ជី ថ្នាំសម្លាប់សត្វចង្រៃ និងគ្រឿងយន្តនៅក្នុងរដូវវស្សា ការស្រោចស្រពនៅរដូវប្រាំង និងការដាំដុះពូជស្រូវលូតលាស់លឿននិងផ្តល់ទិន្នផលខ្ពស់ (UNCDF 2011)។ តម្រូវការទីផ្សារក្នុងការនាំចេញអង្ករទៅប្រទេសវៀតណាម ជាកត្តាជំរុញចម្បងមួយនៃ ការដាំដុះស្រូវជាលក្ខណៈពាណិជ្ជកម្មនៅខេត្តតាកែវ។ កត្តារួមចំណែកផ្សេងទៀត រួមមាន វត្តមានទឹក និងប្រព័ន្ធស្រោចស្រព លទ្ធភាពបានប្រើប្រាស់បច្ចេកវិទ្យាផ្នែកផលិតកម្មស្រូវ និងធាតុចូល (គ្រាប់ពូជ ជី ថ្នាំសម្លាប់សត្វចង្រៃ ឥណទាន) និងកំណើនយន្តកម្មកសិកម្ម។

## លទ្ធផលរកឃើញសំខាន់ៗ

### ដែនឈោងដល់នៃឥណទាន

នៅខេត្តតាកែវសព្វថ្ងៃ មានទាំងឥណទានផ្លូវការ និងមិនផ្លូវការ។ ស្ថាប័នមីក្រូហិរញ្ញវត្ថុ (MFI) ចំនួន ១០ កំពុងធ្វើប្រតិបត្តិការក្នុងស្រុកទាំង ១០ នៅខេត្តតាកែវ។ ចំនួនអ្នកខ្ចីសរុបនៅឆ្នាំ២០១១ មានដល់ ១១៦.៦៩៥នាក់ ប៉ុន្តែ រូបភាព ២ និង ៣ បង្ហាញថា របាយឥណទាននៅតាមស្រុក ប្រែប្រួលខុសគ្នាខ្លាំងទៅតាមដង់ស៊ីតេប្រជាជន ពិពិធកម្មសេដ្ឋកិច្ច និងផលិតកម្ម

---

[១] អត្ថបទនេះរៀបរៀងដោយលោក គឹម សុធន ជាអ្នកស្រាវជ្រាវក្នុងកម្មវិធីភាពក្រីក្រ កសិកម្ម និងអភិវឌ្ឍន៍ជនបទ វិទ្យាស្ថាន CDRI។ អត្ថបទនេះដកស្រង់ពីករណីសិក្សាទី៤ នៃគម្រោង ACIAR (ASEM/2009/023) ស្តីពី "ការអភិវឌ្ឍគោលនយោបាយកសិកម្មសម្រាប់ប្រព័ន្ធដាំដុះផ្អែកលើដំណាំស្រូវនៅប្រទេសឡាវ និងកម្ពុជា" ដែលគ្រោងចប់សព្វគ្រប់នៅខែឧសភា ឆ្នាំ២០១៤។

រូបភាព ២៖ ទំហំកម្ចី គិតតាមស្រុក ទឹកប្រាក់កម្ចីជាលានរៀល




ប្រភព៖ CMA database 2011

រូបភាព ៣៖ ចំនួនអ្នកខ្ចី គិតតាមស្រុក




ប្រភព៖ CMA database 2011

កសិកម្ម (CMA 2011)។ ការដាំដុះភាគច្រើននៅខេត្តតាកែវ មានលក្ខណៈប្រពៃណី។ ប្រជាជនភាគច្រើនប្រើប្រាស់ឥណទានមិនមែនដើម្បីធ្វើវិនិយោគក្នុងកសិកម្មទេ ប៉ុន្តែដើម្បីបម្រើគោលដៅផ្សេង ដូចជា ពង្រីកជំនួញ ធ្វើចំណាកស្រុក និងទិញទ្រព្យដាក់ផ្ទះ។ អ្នកខ្ចីប្រាក់ប្រហែល៧០%ចូលចិត្តកម្ចីខ្នាតតូចពី២៥០ដុល្លារដល់១៥០០ដុល្លារ។ នៅស្រុកបាទី និងត្រាំកក់ មានអ្នកខ្ចីច្រើនជាងគេ ប៉ុន្តែ តម្រូវការធំបំផុតនូវកម្ចីកសិកម្ម វាផុសចេញពីអ្នកផលិតស្រូវសម្រាប់លក់នៅស្រុកអង្គរបូរី បូរីជលសារ គិរីវង់ និងកោះអណ្តែត ដែលគេរាយការណ៍ថា មានចំនួនកសិករប្រើប្រាស់ឥណទានសម្រាប់ផលិតកម្មស្រូវប្រើទឹកស្រោចស្រព ច្រើនជាងគេ។

ការសិក្សាជាច្រើន (ឧទាហរណ៍ Kim 2011 និង Phlong 2009) បានគូសបញ្ជាក់ពីតួនាទីសំខាន់នៃបណ្តាញសង្គមក្នុងការជួយឲ្យកសិករទទួលបានសេវាកម្មហិរញ្ញវត្ថុ។ កសិករភាគច្រើនចូលចិត្តទទួលយក ឥណទានពីអ្នករកស៊ីចងការប្រាក់នៅក្នុងមូលដ្ឋាន (ក្រៅផ្លូវការ) (រូបភាព ៤) ពីព្រោះប្រព័ន្ធនេះអាចបត់បែនបានខ្លះ និងមិនតម្រូវឲ្យដាក់របស់ធានាទេ។ ការប្រាក់ជាមធ្យមគឺ ១០% ក្នុងមួយខែ ដែលខ្ពស់ជាងការប្រាក់របស់ MFIs មួយជាបី។ ពិតមែនតែអត្រាការប្រាក់ទាប ប៉ុន្តែនៅមានកត្តាជាច្រើនដែលរារាំងកសិករក្នុងការប្រើប្រាស់កម្ចីរបស់ MFI។ ទី១ កង្វះរបស់ដាក់ធានាជាឧបសគ្គធំជាងគេ ពីព្រោះកសិករ ៥៧% នៅខេត្តតាកែវ មានដីតូចជាង ១ហិកតា។ ទី២ ភាពងាយរងគ្រោះខ្លាំងរបស់អ្នកក្រ ទាំងចំពោះការប៉ះទង្គិចជាបុគ្គល និងជារួម (Idiosyncratic and covariant[2] shocks) បានរារាំងដល់ពួកគេក្នុងការបង្កើតជាក្រុមដើម្បីទទួលបានប្រាក់កម្ចី។ ទី៣ ហានិភ័យខ្ពស់នៃការខូចខាតផលដំណាំ ធ្វើឲ្យ MFIs រារែកខ្លាំងក្នុងការផ្តល់ប្រាក់កម្ចីដល់កសិករ។ មួយវិញទៀត កសិករក៏ខ្វះខាតចំណេះដឹងបច្ចេកទេស និងជំនាញជាសហគ្រិន ដើម្បីទទួលបាន និងប្រើប្រាស់ប្រាក់កម្ចីឲ្យមានប្រសិទ្ធភាពដែរ។

កសិករផលិតស្រូវពាក់កណ្តាលពាណិជ្ជកម្ម ដាំដុះទាំងស្រូវវស្សា និងស្រូវប្រាំង សម្រាប់ការប្រើប្រាស់ក្នុងគ្រួសារ និងសម្រាប់លក់។ ពួកគេពឹងផ្អែកលើអ្នកផ្គត់ផ្គង់ធាតុចូលនៅមូលដ្ឋាន (ទិញជឿ) ឬអ្នករកស៊ីចងការប្រាក់នៅមូលដ្ឋាន និង MFI សម្រាប់ដើមទុន។ កសិករប្រើប្រាស់ជីជាមធ្យម ១០០គ.ក/ហិកតា ដែលស្មើនឹង ២១% នៃចំណាយលើធាតុចូលសរុប។ ពួកគេប្រើប្រាក់កម្ចីបានពី MFI ដើម្បីជួលម៉ាស៊ីនកសិកម្មសម្រាប់បម្រើផលិតកម្មស្រូវប្រាំង ដែលស្មើនឹង ៣៨% នៃចំណាយលើធាតុចូលសរុប។ ប្រាក់កំចីតាមធម្មតាមិនសូវធំទេ គឺប្រមាណពី ២៥០ដុល្លារ ដល់ ៥០០ដុល្លារ ពីព្រោះដីកាន់កាប់ភាគច្រើនវាតូចពេក មិនអាចគ្រប់គ្រាន់ សម្រាប់ដាក់ធានាកម្ចីធំជាងនេះឡើយ។ ទាំងនេះបង្ហាញថា ឥណទានដែលកសិករអាចទទួលបាន វាតិចជាងតម្រូវការជាក់ស្តែង។ ចំណាយលើជី និងថ្នាំសម្លាប់សត្វចង្រៃសម្រាប់ការដាំស្រូវប្រាំង វាធំជាងចំណាយដូចគ្នាសម្រាប់ស្រូវវស្សា ដល់ទៅ ៧ដង ឬស្មើនឹង ៣២% ផលស្រូវសរុប។ កង្វះដើមទុនបានបង្ខំឲ្យកសិករទិញជឿធាតុចូលពី អ្នកផ្គត់ផ្គង់ក្នុងមូលដ្ឋាន ដោយត្រូវបង់ការប្រាក់ដល់ទៅ ៥% ក្នុងមួយខែ (តារាង១)។ ចំណាយខ្ពស់លើធាតុចូល ថ្លៃអង្ករឡើងចុះខ្លាំង អត្រាការប្រាក់ខ្ពស់ហួសប្រមាណ និងកង្វះលទ្ធភាពទទួលបានកម្ចីខ្នាតមធ្យម បានកាត់បន្ថយកម្រិតប្រាក់ចំណេញរបស់កសិករផលិតស្រូវពាក់កណ្តាលពាណិជ្ជកម្ម។ ប្រាក់ចំណេញដុលរបស់ពួកគេគឺ ២៧៧ដុល្លារ/ហិកតា សម្រាប់ស្រូវវស្សា និង ៥៤០ដុល្លារ/ហិកតា សម្រាប់ស្រូវប្រាំង។ ប្រាក់ចំណូលបានពីការងារកសិកម្មក៏បង្ហាញផងដែរ អំពីកម្រិតជីវភាពមិនសូវខ្ពស់ របស់គ្រួសារកសិករ និងសមត្ថភាពមានកម្រិតក្នុងការទប់ទល់នឹងការប៉ះទង្គិចផ្សេងៗ។

រូបភាព ៤៖ លំនាំនៃការទទួលបានឥណទានរបស់កសិករ គិតតាមស្រុក




[2] ការប៉ះទង្គិចជាបុគ្គល (Idiosyncratic shocks) ប៉ះពាល់តែលើបុគ្គល ឬគ្រួសារខ្លះ ប៉ុន្តែមិនប៉ះលើអ្នកដទៃទេ រីឯការប៉ះទង្គិចជារួម (Covariant shocks) វាប៉ះពាល់ដល់មនុស្សច្រើនគ្នាក្នុងពេលតែមួយ។

តារាង ១៖ បន្ទុកចំណាយក្នុងផលិតកម្មស្រូវជាលក្ខណៈពាក់កណ្តាលពាណិជ្ជកម្ម (ម៉ឺនរៀល/ហិកតា)

| ប្រភេទបន្ទុកចំណាយ | ស្រូវវស្សា | | | ស្រូវប្រាំង | | |
|---|---|---|---|---|---|---|
| ១. ធាតុចូល | ចំនួន (ម៉ឺនរៀល) | % នៃធាតុចូល | % នៃធាតុចេញ | ចំនួន (ម៉ឺនរៀល) | % នៃធាតុចូល | % នៃធាតុចេញ |
| ការរៀបចំដី | 16 | 13 | 7 | 36 | 11 | 6 |
| គ្រាប់ពូជ | 7.5 | 6 | 3 | 36 | 11 | 6 |
| ជួលពលកម្ម | 35.2 | 30 | 15 | 0 | 0 | 0 |
| ជីគីមី | 24.5 | 21 | 11 | 129 | 37 | 23 |
| ថ្នាំសម្លាប់សត្វចង្រៃ | 0 | 0 | 0 | 50 | 15 | 9 |
| ទឹកស្រោចស្រព | 30 | 25 | 13 | 64 | 19 | 11 |
| ការបោកស្រូវ | 6 | 5 | 3 | 28 | 7 | 6 |
| បន្ទុកចំណាយលើធាតុចូលសរុប | **119.2** | **100** | **52** | **343** | **100** | **61** |
| ២. ចំណេញដុល | **110.8** | | **48** | **215** | **0** | **39** |
| ៣. ធាតុចេញ៖ ផលស្រូវ | **230** | | **100** | **558** | | **100** |

ប្រភព៖ ទិន្នន័យបានពីសម្ភាសន៍ដល់កន្លែង (ខែឧសភា ២០១២)

កសិករដែលធ្វើកសិកម្មបែបពាណិជ្ជកម្ម ដាំដុះស្រូវប្រាំងសម្រាប់លក់ទាំងអស់ (តារាង ២)។ ពួកគេប្រើកម្ចីបានពី MFI សម្រាប់ដោះស្រាយរាល់ការចំណាយលើផលិតកម្ម។ កសិករភាគច្រើនមានដី ៣-៤ ហិកតា ដែលអាចឲ្យពួកគេទទួលបានកម្ចីពី MFI ពី ១០០០ដុល្លារ ដល់ ១៥០០ដុល្លារ ប៉ុន្តែមានកសិករខ្លះក៏ប្រើទុនផ្ទាល់ខ្លួនដែរ។ បន្ទុកចំណាយផលិតកម្មគឺ ៧៧២ ដុល្លារ/ហិកតា ឬស្មើនឹង ៦៥% នៃតម្លៃធាតុចេញសរុប។ កសិករដាំស្រូវពូជអ៊ីអ៊េរ ដែលផ្តល់ទិន្នផលជាមធ្យម ៦តោន/ហិកតា។ បន្ទាប់ពីប្រមូលផល កសិករអាចទទួលបានជាមធ្យម ៤២៧ ដុល្លារ/ហិកតា។ ប៉ុន្តែការប្រញាប់សងកម្ចី MFI (ដើម្បីជៀសវាងចំណាយការប្រាក់) ក៏ដូចជាចំណាយលើការជួលម៉ាស៊ីន និងការស្រោចស្រព បានបង្ខំឲ្យកសិករលក់ស្រូវរបស់ខ្លួនភ្លាមបន្ទាប់ពីប្រមូលផលរួច ដែលធ្វើឲ្យពួកគេមិនអាចបានចំណេញពីថ្លៃស្រូវកម្រិតខ្ពស់នៅក្នុងរដូវវស្សា។ ឥណទានហាក់ដូចជាបានជោគជ័យច្រើន នៅពេលវិនិយោគក្នុងការដាំដុះស្រូវសម្រាប់លក់។ ការទទួលបានឥណទាន ជួយឲ្យកសិករបានប្រើប្រាស់ទីផ្សារ ធាតុចូលកសិកម្ម និងសេវាគាំទ្រផ្សេងៗនៃហេដ្ឋារចនាសម្ព័ន្ធរូបវ័ន្ត ហើយពួកគេទាញយកអត្ថប្រយោជន៍បានច្រើនបំផុត ពីធនធានធម្មជាតិដែលមាន។ កត្តាទាំងអស់នេះ បានគួបផ្សំគ្នាបង្កើនផលិតភាពស្រូវ និងជួយរួមចំណែកយ៉ាងសំខាន់ដល់ការលើកកម្ពស់ជីវភាពរស់នៅរបស់កសិករ។

តារាង ២៖ បន្ទុកចំណាយក្នុងផលិតកម្មស្រូវប្រាំងសម្រាប់លក់ (ម៉ឺនរៀល/ហិកតា)

| ប្រភេទបន្ទុកចំណាយ | ស្រូវប្រាំង | | |
|---|---|---|---|
| ១. ធាតុចូល | ចំនួន (ម៉ឺនរៀល) | % ធាតុចូល | % ធាតុចេញ |
| ការរៀបចំដី | 28 | 9 | 6 |
| គ្រាប់ពូជ | 21 | 7 | 4 |
| ជួលពលកម្ម | 0 | 0 | 0 |
| ជីគីមី | 46 | 15 | 10 |
| ថ្នាំសម្លាប់សត្វចង្រៃ | 130 | 42 | 27 |
| ទឹកស្រោចស្រព | 56 | 18 | 12 |
| ការបោកស្រូវ | 28 | 9 | 6 |
| បន្ទុកចំណាយលើធាតុចូលសរុប | **309** | **100** | **65** |
| ២. ចំណេញដុល | **171** | | **35** |
| ៣. ធាតុចេញ៖ ផលស្រូវ | **480** | | |

ប្រភព៖ ទិន្នន័យបានពីសម្ភាសន៍ដល់កន្លែង (ខែឧសភា ២០១២)

**ផលប៉ះពាល់នៃឥណទានលើជីវភាពកសិករដាំស្រូវ**

លទ្ធភាពប្រើប្រាស់កម្ចីបានជោគជ័យ នៅក្នុងផលិតកម្មស្រូវបែបប្រពៃណី មានតួចណាស់ ដោយសារកំហិតធំៗក្នុងវិស័យកសិកម្ម ដូចជា កង្វះហេដ្ឋារចនាសម្ព័ន្ធសម្រាប់ជួយទ្រទ្រង់ តម្លៃធាតុចូលខ្ពស់ វត្ថុធានាមានមិនគ្រប់គ្រាន់ គ្រួសារកសិករត្រូវជួបហានិភ័យច្រើន និងងាយរងគ្រោះខ្លាំង ឱកាសមានតិចសម្រាប់ធ្វើពិពិធកម្មមុខចំណូល និងថ្លៃស្រូវឡើងចុះខ្លាំង។ ទោះយ៉ាងនេះក្តី ឥណទានអាចមានផលប៉ះពាល់វិជ្ជមានច្រើនជាងនេះ ប្រសិនបើកសិករប្រើវាក្នុង គោលដៅមិនមែនកសិកម្មដែលមានផលិតភាពខ្ពស់ជាង។ ក្នុងការពិភាក្សាក្រុមស្នូល (FGD) កសិករមួយចំនួនដែលបានប្រើកម្ចីនេះ ដើម្បីធ្វើពិពិធកម្មប្រភពចំណូលរបស់ខ្លួន តាមរយៈការវិនិយោគទៅលើសកម្មភាពមិនមែនកសិកម្ម បានរាយការណ៍អំពីកំណើនទ្រព្យសម្បត្តិ និងសន្តិសុខស្បៀងរបស់ខ្លួន។ សរុបមក កំណើនលទ្ធភាពប្រើប្រាស់ឥណទានជនបទតែងរួមចំណែកលើកកម្ពស់ជីវភាពរបស់កសិករបន្តិចម្តងៗ និងជួយពង្រឹងភាពធន់ទ្រាំនឹងការប៉ះទង្គិចផ្សេងៗ។

ការប្រើប្រាស់កម្ចី មានផលប៉ះពាល់មិនទាន់ប្រាកដប្រជាទេ ទៅលើជីវភាពកសិករដាំស្រូវពាក់កណ្តាលពាណិជ្ជកម្មពីព្រោះការធ្វើពិពិធកម្មកសិកម្មកម្រិតទាប ធ្វើឲ្យហានិភ័យនៃបរាជ័យផលិតកម្មកើនឡើង។ ការប្រើកម្ចីហុចផលវិជ្ជមាន ឬអវិជ្ជមាន អាស្រ័យលើកម្រិតចំណេញក្នុងកសិកម្ម ដែលជាប់ទាក់ទងនឹងកត្តាមិនប្រាកដប្រជាជាច្រើន ដូចជា ការឡើងចុះថ្លៃស្រូវ និងធាតុអាកាស។ ឧទាហរណ៍ នៅឆ្នាំ២០១២ ថ្លៃស្រូវបានធ្លាក់ចុះពី ១២០០រៀល ដល់៧០០រៀលក្នុងមួយគីឡូក្រាមដែលកាត់បន្ថយប្រាក់ចំណេញសុទ្ធលើដំណាំស្រូវ មកត្រឹម ៣២៨ដុល្លារ/ហិកតា។ ក្នុងស្ថានភាពបែបនេះ ការប្រើប្រាស់មីក្រូហិរញ្ញវត្ថុ អាចនាំឲ្យជីវភាពកសិករ

កាន់តែលំបាកថែមទៀត និងរុញច្រានពួកគេឲ្យជំពាក់បំណុលកាន់តែជ្រៅ។ ទោះយ៉ាងនេះក្តី ការទទួលបានមូលធនអាចជួយពន្លឿនការផ្លាស់ប្តូរពី ផលិតកម្មសម្រាប់មួយរស់ ទៅជាកសិកម្មបែបពាណិជ្ជកម្ម។

វត្តមាន MFI កាន់តែច្រើន បានជួយពង្រីកផលិតកម្មកសិកម្មបែបពាណិជ្ជកម្មនៅខេត្តតាកែវ។ ឥណទាន ព្រមទាំងប្រព័ន្ធស្រោចស្រព និងលទ្ធភាពចូលដល់ទីផ្សារ និងទទួលបានបច្ចេកវិទ្យាកសិកម្ម បានជួយកែលំអទិន្នផលក្នុងការដាំដុះស្រូវសម្រាប់ពាណិជ្ជកម្ម។ កសិកររាយការណ៍ទៀតថា កំណើនទ្រព្យគ្រួសារ ផ្ទះសម្បែងកាន់តែល្អប្រសើរ ការប្រើគ្រឿងយន្តកាន់តែច្រើន ការអប់រំកាន់តែប្រសើរសម្រាប់កុមារ និងសន្តិសុខស្បៀងកាន់តែប្រសើរ វាជាលទ្ធផលនៃការទទួលបានប្រាក់ចំណេញខ្ពស់ពីការដាំដុះ។ ប៉ុន្តែកំណើនបន្ទុកចំណាយផលិតកម្ម និងថ្លៃស្រូវឡើងចុះខ្លាំង អាចជះឥទ្ធិពលអវិជ្ជមានលើប្រាក់ចំណូលពីកសិកម្ម។ ម្យ៉ាងទៀត មានរបាយការណ៍ជាច្រើនពីហ្វូងសត្វចង្រៃកាត់បំផ្លាញជាញឹកញាប់ និងការបំពុលដោយការប្រើថ្នាំសម្លាប់សត្វចង្រៃច្រើន។ បញ្ហានេះ អាចមានផលវិបាកដល់បរិស្ថាន និងគុណភាពនៃប្រព័ន្ធកសិកម្ម។ ការប្រើប្រាស់ថ្នាំសម្លាប់សត្វចង្រៃច្រើន មិនត្រឹមតែបង្កើនបន្ទុកចំណាយផលិតកម្មប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងប៉ះពាល់ដល់សុខភាពកសិករទៀតផង ដែលបង្កើនចំណាយលើការថែទាំសុខភាព។

## បញ្ហាប្រឈម និងឱកាសល្អសម្រាប់ការប្រើប្រាស់ឥណទានបានជោគជ័យ

លទ្ធផលស្រាវជ្រាវ បានគូសរំលេចនូវ បញ្ហាប្រឈម និងឱកាសល្អជាច្រើនដូចខាងក្រោម សម្រាប់ការប្រើប្រាស់ឥណទានឲ្យបានជោគជ័យ៖

### បញ្ហាប្រឈម

***អត្រាការប្រាក់ខ្ពស់៖*** MFIs យកការប្រាក់ប្រមាណ ៣០% ក្នុងមួយឆ្នាំ សម្រាប់ដោះស្រាយបន្ទុកចំណាយប្រតិបត្តិការ និងរក្សាស្ថិរភាពហិរញ្ញវត្ថុ។ MFIs ជាច្រើននៅពឹងផ្អែកលើវិនិយោគិនពីខាងក្រៅនៅឡើយ ហើយប្រាក់សន្សំក្នុងស្រុកកម្រិតទាបនៅតែជាឧបសគ្គរាំងការបញ្ចុះអត្រាការប្រាក់ក្នុងរយៈពេលខ្លី និងមធ្យម។

***ចំណាយផលិតកម្មកសិកម្មខ្ពស់៖*** ចំណាយធាតុចូលខ្ពស់ ជាពិសេស ដីមានគុណភាពទាប និងកំណើនចំណាយលើការប្រើគ្រឿងយន្តដោយសារថ្លៃប្រេងខ្ពស់ បន្តរាំងដល់កំណើនក្នុងរយៈពេលវែងនៃកសិកម្មជាទូទៅមិនមែនត្រឹមតែផលិតកម្មស្រូវនោះទេ។

***ការដោះដូរគ្នាចុះឡើង (Trade off) រវាងលទ្ធភាពផ្តល់ឥណទានបានកាន់តែទូលំទូលាយ និងនិរន្តរភាពហិរញ្ញវត្ថុរបស់ MFIs៖*** តម្រូវការបានចំណូលច្រើនជាអតិបរមាពីកម្ចី ដោយធ្វើការវាយតម្លៃយ៉ាងប្រយ័ត្នប្រយែងលើអតិថិជន មានន័យថា MFIs ត្រូវជ្រើសយកចេញនូវកសិករណាដែលគ្មានរបស់ដាក់ធានា និងអ្នកក្រណាដែលទំនងងាយរងគ្រោះខ្លាំង។ MFIs មួយចំនួន ដូចជា CREDIT និង Vision Fund បានបង្កើតជាកញ្ចប់កម្ចីពិសេស (មានការឧបត្ថម្ភមូលធនពីអ្នកផ្តល់ជំនួយ) សម្រាប់ក្រុមកសិករបែបនេះ។

***កង្វះប័ណ្ណកម្មសិទ្ធិដីធ្លី និងជំនាញសហគ្រិន៖*** ដោយគ្មានប័ណ្ណកម្មសិទ្ធិដីជាផ្លូវការ កសិករគ្មានអ្វីសម្រាប់ដាក់ធានា ដូច្នេះហើយមិនអាចទទួលបានឥណទានផ្លូវការនោះទេ។ មកទល់បច្ចុប្បន្ន ដីចំនួន ២៧៣.២៥៣ឡូត៍ មានប័ណ្ណកម្មសិទ្ធិត្រឹមត្រូវ (MLMUPC ២០១១) ប៉ុន្តែ មិនមានទិន្នន័យអំពីសមាមាត្រដីមានប័ណ្ណកម្មសិទ្ធិ ធៀបនឹងចំនួនក្បាលដីសរុបនោះទេ។ ក្នុងការពិភាក្សាក្រុមស្នូល (FGD) កសិករមួយចំនួនបានបង្ហើបឲ្យដឹងថា ពួកគាត់មិនអាចទទួលបានកម្ចីពី MFIs ព្រោះដីគាត់គ្មានប័ណ្ណកម្មសិទ្ធិផ្លូវការ ហើយកសិករផ្សេងទៀតដែលអាចទទួលបានកម្ចីនេះ គាត់ខ្វះខាតជំនាញសហគ្រិនដើម្បីប្រើប្រាស់កម្ចីឲ្យមានប្រសិទ្ធភាព។

### ឱកាស

***អត្រាការប្រាក់ទាប៖*** MFIs ទំនងនឹងកាត់បន្ថយអត្រាការប្រាក់លើកម្ចីនៅពេលខាងមុខ ដោយសារកត្តាចម្បងពីរ៖ ការប្រកួតប្រជែងក្នុងចំណោម MFIs និងកំណើនប្រាក់សន្សំ/ប្រាក់បញ្ញើក្នុងស្រុក។ MFIs គ្រោងកាត់បន្ថយអត្រាការប្រាក់មកនៅត្រឹម ១% ក្នុងមួយខែ ប៉ុន្តែរឿងនេះអាស្រ័យលើចំនួនប្រាក់សន្សំដាក់នៅធនាគារ។

***ការនាំចេញស្រូវ៖*** កំណើនតម្រូវការស្បៀងអាហារក្នុងពិភពលោក គួបនឹងគោលនយោបាយរដ្ឋាភិបាល សំដៅបង្កើនការនាំចេញស្រូវ កំពុងតែជំរុញកំណើនវិស័យស្រូវអង្ករ។ កិច្ចប្រឹងប្រែងរបស់រដ្ឋាភិបាល ដើម្បីកែលំអហេដ្ឋារចនាសម្ព័ន្ធក្នុងវិស័យកសិកម្ម ដូចជា ប្រព័ន្ធធារាសាស្ត្រ បណ្តាញផ្លូវថ្នល់ និងកំណើនវិនិយោគឯកជនលើរោងចក្រកិនស្រូវ និងកន្លែងស្តុកស្រូវ នឹងជំរុញផលិតកម្ម ជួយសម្រួលពាណិជ្ជកម្ម ជួយធានាទីផ្សារក្នុងស្រុក និងរក្សាស្ថិរភាពថ្លៃស្រូវអង្ករ។

## ជម្រើសគោលនយោបាយ

លទ្ធផលស្រាវជ្រាវនេះ បានផ្តល់ជាជម្រើសមួយចំនួនសម្រាប់ការសម្រេចចិត្តខាងគោលនយោបាយ និងធ្វើផែនការដូចតទៅ៖

***ពន្លឿនការផ្តល់ប័ណ្ណកម្មសិទ្ធិដី៖*** គម្រោងគ្រប់គ្រងនិងរដ្ឋបាលដី (LMAP) កំពុងតែដំណើរការចេញប័ណ្ណកម្មសិទ្ធិដីថែមទៀត ប៉ុន្តែក្នុងនេះគួរផ្តល់អាទិភាពខ្ពស់ដល់កសិករតូចតាច និងអ្នកក្រ។

***ធ្វើវិនិយោគលើហេដ្ឋារចនាសម្ព័ន្ធកសិកម្ម៖*** នេះជាអាទិភាពរយៈពេលវែងរបស់រដ្ឋាភិបាលដើម្បីកែលំអផលិតភាព និងកាត់បន្ថយហានិភ័យផលិតកម្ម ក៏ដូចជាការវិនិយោគថែមទៀតលើហេដ្ឋារចនាសម្ព័ន្ធសម្រាប់ទ្រទ្រង់ដល់ ការដាំដុះដើម្បីមួយរស់។ គួរលើកទឹកចិត្តវិស័យឯកជនឲ្យចូលរួមក្នុងផលិតកម្មស្រូវ តាមរយៈការធ្វើកសិកម្មមានកិច្ចសន្យា។ រោងម៉ាស៊ីនកិនស្រូវខ្នាតតូច និងមធ្យម អាចជួយធានាទីផ្សារសម្រាប់ស្រូវអង្ករ និងកាត់បន្ថយការឡើងចុះថ្លៃ។

***ផ្តល់សេវាកម្មផ្សព្វផ្សាយបច្ចេកទេសកសិកម្មថែមទៀត៖*** ការធ្វើបង្ហាញជាក់ស្តែងនូវវិធីដាំដុះល្អប្រសើរដល់កសិករ អាចជួយបង្កើនផលិតភាព និងប្រាក់ចំណូលពីកសិកម្ម។ ឆ្លងតាមការ

*តទៅទំព័រ ១៤*

# ចំណេះដឹង អាកប្បកិរិយា និងការអនុវត្តរបស់គ្រួសារនៅជនបទ ពាក់ព័ន្ធនឹងទឹកស្អាត សុខភាព និងអនាម័យ[1]

## សេចក្ដីផ្ដើម

តាំងពីចុងទសវត្សរ៍ ១៩៧០ ដល់ពាក់កណ្ដាលទសវត្សរ៍ ១៩៩០ ប្រទេសកម្ពុជាបានផ្ដោតលើសកម្មភាពដោះស្រាយទឹកស្អាត និងអនាម័យដ៏ចាំបាច់នៅជនបទ តាមរយៈការផ្ដល់ជំនួយសង្គ្រោះបន្ទាន់។ ការពង្រីកដែនគ្របដណ្ដប់នៃការផ្គត់ផ្គង់ទឹកស្អាត ហេដ្ឋារចនាសម្ព័ន្ធបង្ហូរទឹកកខ្វក់ចេញ និងបង្កើនអនាម័យតាមគ្រួសារ បានលូតលាស់ទៅមុខយឺតៗនៅឡើយ។ ទិន្នន័យទទួលបានពីដំបូងៗបង្ហាញថា ប្រព័ន្ធអនាម័យនៅជនបទមានដែនគ្របដណ្ដប់តូចណាស់ត្រឹម ២% ប៉ុណ្ណោះនៅឆ្នាំ១៩៩៥ និង ៨% នៅឆ្នាំ២០០២ (Rosenboom 2011) ប៉ុន្តែបន្ទាប់ពីនោះមកវាក៏កើនឡើង និងកើនយ៉ាងគំហុកដល់ ១៤% នៅឆ្នាំ២០០៤ និងជិតដល់ ២២% នៅឆ្នាំ២០០៥ (World Bank 2008)។ អង្កេតកម្រិតជាតិស្ដីពី ចំណេះដឹង អាកប្បកិរិយា និងការអនុវត្ត (KAP) សុខភាព និងអនាម័យ របស់ក្រសួងអភិវឌ្ឍន៍ជនបទ (MRD) ក្នុង ១២ខេត្ត នៅឆ្នាំ២០១០ បានរកឃើញថា មានតែ គ្រួសារ ២៩,៦% ប៉ុណ្ណោះ ដែលមានបង្គន់ប្រើប្រាស់។

ការមានទឹកស្អាតសម្រាប់ហូបមិនគ្រប់គ្រាន់ និងការអនុវត្តរបៀបរក្សាសុខភាពនិងអនាម័យ (S&H) អន់ខ្សោយ វាបង្កការខាតបង់ដល់សេដ្ឋកិច្ចកម្ពុជា។ អនាម័យអន់ខ្សោយ បានបង្កការខាតបង់ដល់សេដ្ឋកិច្ច អស់ប្រមាណ ៤៤៨លានដុល្លារ/ឆ្នាំ ស្មើនឹងប្រហែល ៣២ដុល្លារក្នុងមនុស្សម្នាក់ ឬ ៧,២% នៃផសស កម្ពុជា នៅឆ្នាំ២០០៥ (World Bank 2008)។ ម្យ៉ាងទៀតមានកុមារកម្ពុជាអាយុក្រោម ៥ឆ្នាំ ដល់ ១៧% ត្រូវស្លាប់ដោយសារជំងឺរាគរូស ដែលបណ្ដាលពីទឹកកខ្វក់ និងកង្វះអនាម័យ (Mom 2011)។ទោះជាភាពក្រីក្របានធ្លាក់ចុះពី ៣០,១%នៅឆ្នាំ២០០៧ ដល់ ២៧,២%នៅឆ្នាំ២០១០ ក្ដី ក៏វិនិយោគរបស់គ្រួសារលើប្រព័ន្ធអនាម័យ នៅតែមានកម្រិតទាប។ ដោយសារមានប្រជាជនជាង ៨០% រស់នៅតាមតំបន់ជនបទ ការកែលំអស្ថានភាពសុខភាពនិងអនាម័យនៅជនបទ ជាកត្តាចាំបាច់បំផុតដើម្បីកាត់បន្ថយ ភាពក្រីក្រ និងបង្កើនសុខមាលភាពសង្គម ។ សម្ដេចនាយករដ្ឋមន្ត្រី ហ៊ុន សែន បានគូសបញ្ជាក់ពី សារៈសំខាន់នេះថា "នៅកម្ពុជា បញ្ហាសុខភាពនិងអនាម័យអន់ខ្សោយ ជាកត្តាមួយ ដែលរួមចំណែកដល់ភាពក្រីក្ររបស់ប្រជាជនកម្ពុជា និងរាំងស្ទះដល់កិច្ចប្រឹងប្រែងរបស់រាជរដ្ឋាភិបាលកម្ពុជា ក្នុងការអភិវឌ្ឍសេដ្ឋកិច្ចជាតិ" (World Bank 2008: 5)។

ឥឡូវនេះ រដ្ឋាភិបាលមានស្ថានភាពកាន់តែប្រសើរដើម្បីផ្ដោតកិច្ចប្រឹងប្រែងឲ្យបានកាន់តែច្រើនលើ ការផ្ដួចផ្ដើមគំនិតរយៈពេលវែង សំដៅកសាងហេដ្ឋារចនាសម្ព័ន្ធផ្គត់ផ្គង់ទឹកស្អាត និងបង្ហូរទឹកកខ្វក់ចេញនៅជនបទ និងលើកកម្ពស់ការយល់ដឹងជាសាធារណៈបង្កើនការអនុវត្ត S&H។ លទ្ធភាពបានប្រើប្រាស់ទឹកស្អាតនិងបង្គន់ និងការលើកកម្ពស់ការអនុវត្ត S&H បានទទួលអាទិភាពខ្ពស់ និងមានដាក់បញ្ចូលទៅក្នុងក្របខ័ណ្ឌយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ (CDC 2011)។ គោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍កម្ពុជាទី៧ (ធានាចីរភាពបរិស្ថាន) មានគោលដៅផ្ដល់លទ្ធភាពបានប្រើប្រាស់ទឹកស្អាតដល់ ៥០% និងសេវាអនាម័យកាន់តែប្រសើរដល់ ៣០% នៃប្រជាពលរដ្ឋនៅជនបទ នៅត្រឹមឆ្នាំ២០១៥។ ដើម្បីគាំទ្រដល់អាទិភាពទាំងនេះ គោលនយោបាយជាតិស្ដីពីទឹកស្អាតនិងអនាម័យ បានតាក់តែងឡើងនៅឆ្នាំ២០០៣ ដោយមានគូសបញ្ជាក់ពីចក្ខុវិស័យច្បាស់លាស់របស់រដ្ឋាភិបាលដែលកំណត់ថា "ជនគ្រប់រូបនៅសហគមន៍ជនបទ ត្រូវមានលទ្ធភាពយូរអង្វែងក្នុងការទទួលបានការផ្គត់ផ្គង់ទឹកស្អាត សេវាអនាម័យ និងបានរស់នៅក្នុងបរិស្ថានមួយមានអនាម័យល្អនៅត្រឹមឆ្នាំ២០២៥" (World Bank 2008: 9)។

## សារៈនៃការសិក្សា

ដើម្បីពង្រឹងនិងបំផុសការអនុវត្ត S&H នៅតាមសហគមន៍ជនបទ ក្រសួងអភិវឌ្ឍន៍ជនបទ (MRD) បានបង្កើតកម្មវិធីកែលំអសុខភាពនិងអនាម័យនៅជនបទកម្ពុជា (CR-SHIP) ដោយរួមសហការជាដៃគូជាមួយអង្គការ ផ្លែនអន្តរជាតិកម្ពុជា (Plan International Cambodia) និងមានការឧបត្ថម្ភថវិកាពី មូលនិធិអនាម័យសាកល (Global Sanitation Fund: GSF) នៃក្រុមប្រឹក្សាសហប្រតិបត្តិការអនាម័យ និងការផ្គត់ផ្គង់ទឹក (Water Supply and Sanitation Collaborative Council: WSSCC)។ CR-SHIP មានគោលដៅបង្កើនលទ្ធភាពទទួលបានសេវាអនាម័យកាន់តែល្អប្រសើរ និងការអនុវត្តអនាម័យបានកាន់តែសមស្រប ដោយ ១) លើកទឹកចិត្តឲ្យប្រជាជនប្រើបង្គន់យ៉ាងទៀងទាត់ លាងដៃជាមួយសាប៊ូ និងមានទឹកស្អាតហូបនៅតាមសហគមន៍ជនបទ និង ២) កសាង និងពង្រឹងសមត្ថភាពរដ្ឋាភិបាល អាជ្ញាធរមូលដ្ឋាន និងអង្គការមិនមែនរដ្ឋាភិបាល (NGOs) ដើម្បីលើកកម្ពស់ការអនុវត្ត S&H ឲ្យបានកាន់តែប្រសើរ។

វិទ្យាស្ថាន CDRI បានធ្វើអង្កេតជាមូលដ្ឋានមួយនៅខេត្តកំពង់ចាម កណ្ដាល ស្វាយរៀង តាកែវ និង កំពង់ស្ពឺ ដើម្បីសិក្សាពីចំណេះដឹង អាកប្បកិរិយា និងការអនុវត្ត (KAP) តាមគ្រួសារនៅជនបទ ស្ដីពី ទឹកហូបស្អាតនិងការស្តុកទឹក ការសាងសង់និងប្រើប្រាស់បង្គន់អនាម័យតាមគ្រួសារ និងការអនុវត្តអនាម័យ

---

[1] អត្ថបទនេះរៀបរៀងដោយកញ្ញា វង្ស ស្រីទូច ជាអ្នកស្រាវជ្រាវ ក្នុងកម្មវិធីអភិវឌ្ឍន៍សង្គមនៃ វិទ្យាស្ថាន CDRI។ អ្នកនិពន្ធសូមថ្លែងអំណរគុណដល់អង្គការ ផ្លែន កម្ពុជា ដែលបានឧបត្ថម្ភគាំទ្រដល់គម្រោងនេះ។

[2] ឃុំ គឺជាឯកតាត្រូវយកមកគណនា ដើម្បីកំណត់ថា តើតំបន់នោះស័ក្ដិសមជា "ទីប្រជុំជន" ឬ "ជនបទ"។ ធម្មតា សង្កាត់ សំដៅដល់ ឃុំរបស់ទីក្រុង ប៉ុន្តែបើប្រើប្រាស់និយមន័យឆ្នាំ២០០៤នោះ សង្កាត់នៅក្នុងក្រុងទាំង ២៦ នៅកម្ពុជាមិនសុទ្ធតែគ្រប់លក្ខណៈជាតំបន់ទីប្រជុំជនទាំងអស់ទេ។ សូមមើល http://db.ncdd.gov.kh/cdbonline/home/index.castle (accessed 26 May 2012)

ដើម្បីបង្កើតជាព័ត៌មានគោលសម្រាប់ CR-SHIP។ អត្ថបទនេះរាយការណ៍ពីគំហើញសំខាន់ៗ ព្រមទាំងអនុសាសន៍មួយចំនួន ដើម្បីកែលំអប្រសិទ្ធភាពនៃការផ្សព្វផ្សាយលើកកម្ពស់ S&H នាពេលបច្ចុប្បន្ន និងជំរុញការទទួលយករបៀបអនុវត្តន៍ S&H ឲ្យបានកាន់តែប្រសើរ ។

## វិធីសាស្ត្រ

ក្រុមស្រាវជ្រាវបានប្រើប្រាស់ទាំងវិធីសាស្ត្របែបបរិមាណ និងបែបគុណភាព ដែលរួមមាន អង្កេតលើ ៨៤១ គ្រួសារជ្រើសរើសដោយចៃដន្យ កិច្ចសម្ភាសន៍ពាក់កណ្ដាលរៀបរយ និងការពិនិត្យសង្កេតផ្ទាល់។ ការប្រមូលព័ត៌មានបែបបរិមាណ បានធ្វើឡើងតាមរយៈ ២០ បទសម្ភាសន៍ជាមួយអ្នកផ្ដល់ព័ត៌មានគន្លឹះ (KIIs) និង ៤០ ការពិភាក្សាតាមក្រុមស្នូល (FGDs)។ KIIs ជាមួយប្រធានភូមិ ក្រុមប្រឹក្សាឃុំ មាតាបិតាសិស្សនិងលោក/អ្នកគ្រូ ព្រមទាំងមណ្ឌលសុខភាពតាមមូលដ្ឋាន និងបុគ្គលិកមន្ទីរអភិវឌ្ឍន៍ជនបទខេត្ត (PDRD) ដែលបានផ្ដល់គំនិតទូលំទូលាយអំពីប្រសិទ្ធភាពជាទូទៅនៃការអនុវត្ត S&H នៅក្នុងតំបន់ចុះសិក្សា។ FGDs ធ្វើឡើងជាមួយ ក្រុមនារីសុទ្ធ ក្រុមនារីនិងបុរសចម្រុះគ្នា លោក/អ្នកគ្រូ និងសិស្សសាលាបឋមសិក្សា បានផ្ដល់ព័ត៌មានលំអិតពីបញ្ហាទាក់ទិននឹងការអនុវត្ត S&H ជាក់ស្ដែងតាមគ្រួសារ។ ដោយមានជំនួយពីបុគ្គលិក PDRD ទិន្នន័យអង្កេតបានប្រមូលយកក្នុងរយៈពេលជាង ១០ថ្ងៃ ចាប់ពីថ្ងៃទី២៧ វិច្ឆិកា ដល់ ០៦ ធ្នូ ២០១១។ ទិន្នន័យអង្កេត បានយកមកចាត់ចែងតាមកម្មវិធីកុំព្យូទ័រ SPSS និងបម្លែងជា STATA ដើម្បីវិភាគ។

## របកគំហើញ

### *ការប្រើប្រាស់ និងសាងសង់បង្គន់តាមគ្រួសារ*

គ្រួសារគំរូតាងជាងពាក់កណ្ដាល (៦០,១៧%) គ្មានបង្គន់ទេ ដូច្នេះ ជិត ៤០% គឺមានបង្គន់ប្រភេទណាមួយ។ អ្នកមានបង្គន់ភាគច្រើន (៩៧,៣១%) គេមានបង្គន់បានកែលំអ ដូចជាបង្គន់ដែលបង្ហូរចូលទៅក្នុងអាងស្តុក (តារាង ១)។ ក្នុងចំណោមអ្នកមានបង្គន់ មាន ៩៦,៤២% បញ្ជាក់ថា បង្គន់របស់ខ្លួនដំណើរការបានធម្មតា (តារាង ១) និងមាន ៥% ប្រាប់ថា នេះមិនមែនជា

តារាង ១៖ បង្គន់តាមគ្រួសារ បែងចែកតាមប្រភេទ (n=335)

| ប្រភេទបង្គន់តាមគ្រួសារ | ប្រភេទ |
|---|---|
| *បានកែលំអ* | |
| បង្គន់ចាក់ទឹកតទៅប្រព័ន្ធទឹកសំអុយ | 0.6 |
| បង្គន់ដែលបង្ហូរចូលទៅក្នុងអាងស្តុក | 97.31 |
| សរុប | 97.91 |
| *មិនបានកែលំអ* | |
| បង្គន់ចាក់ទឹកដែលគ្មានលូស្តុក | 0.9 |
| បង្គន់ស្ងួតដែលមានកំរាលតែគ្មានគំរប | 0.3 |
| បង្គន់ចំហហៀរចេញ | 0.6 |
| ផ្សេងៗ | 0.3 |
| សរុប | 2.1 |

បង្គន់ទី១ ដែលគាត់ធ្លាប់មាននោះទេ ដូច្នេះ មានជាច្រើនគ្រួសារណាស់ដែលទើបបានធ្វើបង្គន់ប្រើជាលើកដំបូង។

មូលហេតុចម្បងដែលគ្រួសារថា ធ្វើឲ្យខ្លួនគ្មានបង្គន់ប្រើ គឺថ្លៃសាងសង់ខ្ពស់ (៩៧,៨០%) គ្មានសម្ភារៈសំណង់នៅតំបន់ខ្លួនរស់នៅ (២៦%) គ្មានជំនួយពីក្រៅ ដូចជាពី រដ្ឋាភិបាល និង NGOs (១០,៥០%)។ លទ្ធផល FGD បញ្ជាក់ថា ស្ថានភាពហិរញ្ញវត្ថុក្នុងគ្រួសារ ជាមូលហេតុចម្បងមួយនៃការគ្មានបង្គន់ប្រើ។ អ្នកចូលរួមម្នាក់ក្នុង FGD ក្រុមនារីសុទ្ធ បានលើកថា "ការលក់កម្លាំងពលកម្មដើម្បីធ្វើបង្គន់ មិនមែនងាយនោះទេ ព្រោះលុយរកបានវា (ត្រូវចាយ) អស់ទៅវិញជារៀងរាល់ថ្ងៃ"។ ក្រុមប្រឹក្សាឃុំម្នាក់ ក៏លើកឡើងស្រដៀងគ្នាដែរថា "ខ្ញុំមិនដែលឮអ្នកណានិយាយពីការពិបាកប្រើបង្គន់នោះទេ មានតែឮនិយាយពីរឿងលុយកាក់ គឺបើសិនមានលុយ គេអាចធ្វើបង្គន់បានហើយ"។

ចំណុចគួរចាប់អារម្មណ៍មួយ គឺទោះបីមាន ឬគ្មានលុយកាក់យ៉ាងណាក្ដី ក៏មេគ្រួសារតែងចូលចិត្តបង្គន់ប្រភេទចាក់ទឹកជានិច្ច។ គ្រួសារគ្មានបង្គន់សព្វថ្ងៃ (៨៦%) តែងជ្រើសយកបង្គន់ប្រភេទចាក់ទឹក ហើយពួកគេនឹងសង់វាមួយបើសិនមានលុយ ដូចបញ្ជាក់ច្បាស់នៅក្នុង FGD ក្រុមនារីសុទ្ធ នៅខេត្តកំពង់ចាម ដែលថា "ខ្ញុំមិនចង់ធ្វើបង្គន់ស្ងួតដែលមានកំរាលតែគ្មានគំរបនោះទេ ព្រោះវាកខ្វក់ពេក។ ខ្ញុំរង់ចាំរហូតដល់ពេលមានលុយគ្រប់ រួចធ្វើបង្គន់ចាក់ទឹកតែម្ដង"។

### *ទស្សនៈគ្រួសារអំពីចំណាយសាងសង់បង្គន់*

កម្មវិធីផ្សព្វផ្សាយពីអនាម័យ ដែលឧបត្ថម្ភគាំទ្រដោយ NGOs និងអនុវត្តឡើងដោយរួមសហការជាដៃគូជាមួយ កន្លែងលក់សម្ភារៈសំណង់ឯកជន និងអាជ្ញាធរមូលដ្ឋាន កំពុងមានដំណើរការក្នុងខេត្តសិក្សាទាំង ៥។ ឧទាហរណ៍ អង្គការ Lien Aid កំពុងដំណើរការកម្មវិធីអប់រំ ដោយរួមសហការជាមួយអាជ្ញាធរមូលដ្ឋាន (មេភូមិ ក្រុមប្រឹក្សាឃុំ) ព្រមទាំងក្រុមជាង និងហាងលក់សម្ភារៈនៅមូលដ្ឋាន ដើម្បីផ្ទេរជំនាញសម្អាតទឹក និងកសាងហេដ្ឋារចនាសម្ព័ន្ធអនាម័យ ទៅឲ្យសហគមន៍នៅតាមមូលដ្ឋាន។ បង្គន់ចាក់ទឹកដែលមានលូបីកង់ និងចានបង្គន់ចាក់ទឹកមួយ មានតម្លៃ ១៦៤.០០០រៀល (៤០ដុល្លារ[២]) រួមទាំងថ្លៃដឹកជញ្ជូនផង។ សមាជិកក្រុមប្រឹក្សាឃុំម្នាក់ នៅស្រុកជើងព្រៃ ខេត្តកំពង់ចាម បានកត់សំគាល់ថា "ការទិញ (សម្ភារៈសាងសង់បង្គន់មួយឈុត) ពីអង្គការ Lien Aid គឺថោកជាង (ទិញមួយ) ពីប្រភពឯកជន ដែលមានថ្លៃដល់ទៅ ២០០.០០០រៀល (៤៨,៧៨ដុល្លារ) ឬច្រើនជាងនេះ ដោយលូមួយកង់អាចមានថ្លៃខុសគ្នាប្រហែល ១០.០០០ រៀល (២,៤៣ដុល្លារ)"។

យោងតាមអង្កេត គ្រួសារនានានៅតែយល់ថា ការសាងសង់បង្គន់មួយត្រូវចំណាយអស់ច្រើនពេក។ ឧទាហរណ៍ គ្រួសារ ១២% ជឿថា បង្គន់មួយត្រូវចំណាយមិនដល់ ១០០ដុល្លារ ទេ ប៉ុន្តែ មានប្រហែល ៧៥% ទៀត យល់ថា ត្រូវចំណាយអស់ដល់ ១០០ ទៅ ៣០០ដុល្លារ ឬលើសពីនេះ ទើបអាចសាងសង់បង្គន់

[២] ១ដុល្លារ ស្មើនឹង ៤១០០រៀល

រូបភាព ១: ការយល់ឃើញពីចំណាយសាងសង់បង្គន់មួយ




សមរម្យមួយបានសម្រាប់គ្រួសារខ្លួន (រូបភាព ១)។ ចំពោះគ្រួសារអ្នកគ្មានបង្គន់ ឧបសគ្គចម្បងដែលរាំងស្ទះការសាងសង់បង្គន់ប្រហែលជាការមិនមានលុយសន្សំផ្ទាល់ខ្លួនគ្រប់គ្រាន់ ។ ប្រជាជនជាទូទៅតែងគិតថា ការសាងសង់បង្គន់សមរម្យមួយ ត្រូវចំណាយអស់ច្រើនជាងការពិតជាក់ស្ដែងឆ្ងាយណាស់ ដែលធ្វើឲ្យពួកគាត់កាន់តែគ្មានទឹកចិត្តចង់ធ្វើបង្គន់។

ទាក់ទិននឹងកម្ចីផ្ដល់ឲ្យដោយស្ថាប័នមីក្រូហិរញ្ញវត្ថុ (MFIs) សម្រាប់សាងសង់បង្គន់ អ្នកផ្ដល់ព័ត៌មានគន្លឹះ (អ្នកភូមិ ក្រុមប្រឹក្សាឃុំ និងមេភូមិ) បានដឹងដោយចោះៗតែប៉ុណ្ណោះ។ ពួកគាត់ភាគច្រើនមិនដឹងថា មានការផ្ដល់កម្ចីសម្រាប់ឲ្យធ្វើបង្គន់នោះទេ ប៉ុន្តែមានខ្លះបានដឹងថា MFIs ក៏មានផ្ដល់កម្ចីបែបនេះដែរ។ MFIs ជាច្រើនបានចាប់ផ្ដើមពង្រីកសេវាកម្មទៅដល់ភូមិ តែកម្ចីទាក់ទងនឹងបញ្ហាអនាម័យ ខាង MFIs និង អ្នកភូមិ មិនសូវបានគិតគូរទេ។ អ្នកភូមិជារឿយៗប្រើកម្ចីបានពី MFIs មកធ្វើវិនិយោគលើការងារស្រែចំការ ប៉ុន្តែគាត់មិនចង់ខ្ចីលុយពី MFIs មកធ្វើបង្គន់ទេ។ ចំពោះសំណួរពីការយល់ឃើញក្នុងការប្រើប្រាស់សេវាកម្ម MFIs ដើម្បីសាងសង់បង្គន់ គ្រួសារ ៩២% មិនចង់ខ្ចីលុយមកធ្វើបង្គន់ទេ ហើយ ៨៣% លើកថា ខ្លាចមិនអាចសងគេវិញឲ្យបានទៀងទាត់តាមលក្ខខណ្ឌកម្ចីតម្រូវឡើងដោយ MFIs។ ការកត់សំគាល់ខាងក្រោមបានពី FGDs និង KIIs បានបញ្ជាក់គាំទ្រដល់ទស្សនៈទាំងនេះ៖

> *នៅទីនេះគ្មានអ្នកភូមិណាម្នាក់ បានប្រើកម្ចីពី MFIs មកធ្វើបង្គន់ទេ ...ពីព្រោះ MFIs មិនអនុញ្ញាត ហើយប្រជាជនក៏មិនហ៊ានខ្ចីដែរ ព្រោះខ្លាចអត់លុយសងកម្ចីនោះវិញ...* (មេភូមិសន្ទិចលិច ឃុំដងក្ដារ ស្រុកស្ទឹងត្រង់ ខេត្តកំពង់ចាម)
>
> *NGOs (MFIs) មិនផ្ដល់កម្ចីសម្រាប់ធ្វើបង្គន់ទេ... បើយើងចង់ខ្ចី គេឲ្យយើងខ្ចី តែពួកយើងមិនចង់ខ្ចីទេ ព្រោះខ្លាចមិនអាចសងគេវិញ...* (មេភូមិអង្គរជ័យលើ ឃុំមហាខ្ញូង ស្រុកកោះសូទិន ខេត្តកំពង់ចាម)
>
> *[ខ្ញុំ] មិនហ៊ានខ្ចីលុយ ឬប្រើកម្ចីមកសង់បង្គន់ទេ... [ខ្ញុំ] គ្មានមធ្យោបាយសងកម្ចីនោះវិញ ព្រោះបង្គន់មិនអាចផ្ដល់ជាប្រាក់ចំណូលអ្វីបាន...* (នារីមកពីភូមិសន្ទិចលិច ឃុំដងក្ដារ ស្រុកស្ទឹងត្រង់ ខេត្តកំពង់ចាម)
>
> *[ខ្ញុំ] មិនដែលគិតរកខ្ចីលុយមកសង់បង្គន់ ឬទិញពាងចម្រោះទឹកទេ ព្រោះ [ខ្ញុំ] ខ្លាចអស់ដីស្រែ...* (ឪពុកមានកូនបួននាក់ នៅភូមិត្រពាំងស្លា ឃុំសំពងជ័យ ស្រុកជើងព្រៃ ខេត្តកំពង់ចាម)

### ***ចំណេះដឹង អាកប្បកិរិយា និងការអនុវត្តរបស់គ្រួសារ ក្នុងបញ្ហាទឹកហូបស្អាត សុខភាព និងអនាម័យ***

ប្រព័ន្ធផ្សព្វផ្សាយ (ទូរទស្សន៍ និងវិទ្យុ) ជាប្រភពសារឬព័ត៌មានដ៏សំខាន់របស់គ្រួសារនានា បន្ទាប់មកមាន ការប្រជុំក្នុងសហគមន៍ (រួមទាំងការបណ្ដុះបណ្ដាលក្នុងសហគមន៍) ដែលជាច្រកមួយដ៏មានប្រសិទ្ធភាព សម្រាប់ផ្សព្វផ្សាយសារអំពីអនាម័យ និងទឹកស្អាត ទៅដល់បណ្ដាសហគមន៍នៅជនបទ។ ក្នុងឆ្នាំកន្លងទៅ គ្រួសារបានដឹងឬបានទទួលព័ត៌មានផ្សព្វផ្សាយអំពី ទឹកហូបស្អាត (៥៧,៩០%) ការធ្វើបង្គន់ (៣៦%) និង ការលាងដៃនឹងសាប៊ូ (៣២,៧០%)។

ជាទូទៅ គ្រួសារនានាបានអនុវត្ត S&H ពាក់ព័ន្ធនឹង ទឹកស្អាត (៨០%) អនាម័យនិងការសម្អាតដៃ (៦៤%) អនាម័យម្ហូបអាហារ (៤៤%) និងមានការយល់ដឹងពីរបៀបរក្សា S&H ឲ្យបានល្អ។ គ្រួសារ ដែលមានចំណេះដឹងពីការរាលដាលជំងឺរាគរូស និងការបង្ការ ក៏មានច្រើនគួរកត់សំគាល់ដែរ។ ពួកគេបានដឹងថា ជំងឺរាគឆ្លងតាមម្ហូបអាហារមិនស្អាត (៦៧%) ទឹកមិនស្អាត (៦៧%) សត្វរុយ (៦០%) ដៃកខ្វក់ (៤៨%) និងមាន ១៧% ដឹងថាវាអាចឆ្លងតាមការបន្ទោរបង់ពាសវាលពាសកាល (OD)។

ចំណេះដឹងអំពី S&H វាជាប់ទាក់ទងច្រើនទៅនឹងកម្រិតអប់រំរបស់មេគ្រួសារ។ ដោយប្រើទំនាក់ទំនង Spearman កម្រិតអប់រំរបស់មេគ្រួសារជាប់ទាក់ទងជាវិជ្ជមាន[៣] ជាមួយនឹងការយល់ដឹងរបស់គាត់ពីរបៀបឆ្លងជំងឺរាគ ហើយក៏ជាប់ទាក់ទងជាវិជ្ជមានជាមួយនឹង ចំណេះដឹងរបស់គ្រួសារអំពីការរាលដាលជំងឺរាគនៅកម្រិត ៥% ដោយមានមេគុណទំនាក់ទំនង (correlation coefficient) 0.085។ តួលេខនេះបញ្ជាក់ថា មេគ្រួសារមានកម្រិតអប់រំខ្ពស់កាលណា សមាជិកគ្រួសារក៏មានការយល់ដឹងបានច្រើនកាលនោះពីគោលបំណងនៃ S&H បានអនុវត្ត S&H ទៀងទាត់ល្អ និងដឹងពីវិធីបង្ការជំងឺរាគ។ លើសពីនេះ មេគ្រួសារតែងមើលឃើញការរក្សាសុខភាពបានល្អ ដូចជាការបញ្ចៀសជំងឺតម្កាត់ និងការបង្ការជម្ងឺឆ្លង (៩៤%) ជាមូលហេតុសំខាន់សម្រាប់រក្សាស្តង់ដារ S&H ឲ្យបានល្អ។ ពួកគេក៏បានដឹងពីផលប្រយោជន៍នៃការលាងដៃ ប៉ុន្តែការយល់ដឹងពីពេលសំខាន់ៗដែលត្រូវលាងដៃ វាប្រែប្រួលខុសគ្នា ទៅតាមមុខរបរពួកគេ៖ មេគ្រួសារជានារីតែងយល់ដឹងបានច្រើនជាង ពីតម្រូវការលាងដៃនៅមុនពេលរៀបចំនិងចម្អិនម្ហូបអាហារ ចំណែកអ្នកឯទៀតឆ្លើយថា ពេលសំខាន់បំផុតដែលត្រូវលាងដៃ គឺនៅមុននិងក្រោយពេលបរិភោគអាហារ និងក្រោយពេលទៅបន្ទោរបង់។

ចំណេះដឹងរបស់គ្រួសារអំពីការស្តុកទឹក និងការធ្វើឲ្យទឹកស្អាតអាចហូបបាន ក៏មានកម្រិតខ្ពស់ដែរ។ មូលហេតុសំខាន់ដែលគ្រួសារលើកឡើងពីតម្រូវការស្តុកទឹកទុក គឺដើម្បីបង្ការការឆ្លងចូលមេរោគ (៧៥%) ការរក្សាទឹកទុកឲ្យបានស្អាត (២៣%) និង

---

[៣] Significant នៅកម្រិត ១% ដោយមាន correlation coefficient 0,165

មានសុវត្ថិភាព (១៩%)។ ពួកគេក៏បញ្ជាក់ដែរថា ចំណាត់ការធ្វើឲ្យទឹកស្អាតអាចហូបបាននេះ គឺត្រូវធ្វើយ៉ាងណាកុំឲ្យមានមេរោគ ធូលី ឬលាមកធ្លាក់ចូលទឹក (៦២,៣០%) ដើម្បីរក្សាសុខភាពឲ្យបានល្អ (៥០%) និងបង្ការជំងឺផ្សេងៗ (១៩%)។

### *ការទទួលយករបស់គ្រួសារនូវការហូបទឹកស្អាត និងអនុវត្តវិធីអនាម័យ*

ជាការប្រសើរបំផុត ការលាងដៃគួរក្លាយជាទម្លាប់តែម្តង មិនមែនជាទង្វើម្តងម្កាលនោះទេ។ ពួកអ្នកចូលរួមក្នុង FGD និង KIIs រាយការណ៍ថា ពួកគេច្រើនលាងដៃតែនៅមុនពេលបរិភោគ ជាពិសេស ក្រោយពេលចុះធ្វើការក្នុងស្រែ ក្រោយពេលទៅបង្គន់ (បន្ទោរបង់) និងនៅពេលដៃកខ្វក់។ ទោះយ៉ាងនេះក្តី ពួកកុមារទំនងលាងដៃបានច្រើនជងជាងមនុស្សពេញវ័យ។ ឧទាហរណ៍ ម្តាយក្នុងគ្រួសារមួយបញ្ជាក់ថា "ពួកកូនៗលាងដៃបានល្អជាងខ្ញុំ និងប្តីខ្ញុំ។ ពួកគេតែងសួរថា តើលាងដៃហើយឬនៅ?"។ រឿងនេះប្រហែលមកពី លោក/អ្នកគ្រូ តែងរំលឹកពួកកុមារជាប្រចាំអំពី S&H ជាពិសេស សារៈសំខាន់នៃការលាងដៃ។ សិស្សសាលាពន្យល់ថា "លោក/អ្នកគ្រូ ណែនាំពួកយើងឲ្យលាងដៃបានទៀងទាត់ នៅមុនពេលនិងក្រោយពេលញ៉ាំហើយត្រូវលាងដៃនឹងសាប៊ូក្រោយពេលបោសសម្រាម ឬបោសដី...។ នាយកសាលាម្នាក់លើកបន្ថែមថា "សិស្សសាលាតែងលាងដៃ ពីព្រោះសាលារៀនបានតម្រូវដូច្នេះ"។

គំហើញបានពី FGD និង KIIs បញ្ជាក់គាំទ្រដល់អង្កេតដែលបានសង្កេតឃើញថា ប្រជាជនលាងដៃជាមួយតែទឹក ឬសាប៊ូ និងទឹក និងមានតិចនាក់ណាស់ដែលប្រើផេះ។ គ្រួសារដែលលាងដៃតែនឹងទឹក បានលើកថា ថ្លៃសាប៊ូជាឧបសគ្គរារាំងការអនុវត្តលាងដៃនឹងសាប៊ូ។ រឿងនេះមានបញ្ជាក់ក្នុងការពិភាក្សារបស់ក្រុមនារីសុទ្ធ ដែលថា "បើ [យើង] លាងដៃនឹងសាប៊ូ [យើង] ត្រូវចំណាយលុយទិញសាប៊ូ ដូច្នេះ [គួរ] ទុកលុយទិញប្រីចេងមកប្រើ បានពីរថ្ងៃវិញ"។ អ្នកចូលរួមម្នាក់ទៀតបន្ថែមថា "ពីមុនម្សៅសាប៊ូមានលក់ជាកញ្ចប់តូចថ្លៃត្រឹម ១០០រៀលប៉ុណ្ណោះ ប៉ុន្តែឥឡូវនេះត្រូវតែទិញច្រើនជាងមុនដល់ ៥០០រៀល/កញ្ចប់ ឬច្រើនជាងនេះទៀត"។ បុគ្គលិកមណ្ឌលសុខភាពបានលើកពីក្តីបារម្ភចំពោះអាកប្បកិរិយារបស់សហគមន៍ថា "សាប៊ូមាននៅគ្រប់គ្រួសារ ប៉ុន្តែគេមិនលាង... ពួកគេ (អ្នកភូមិ) តែងនិយាយជាញឹកញាប់ថា មិនដែលលាងដៃមែន តែមិនដែលឃើញមានបញ្ហាអ្វីផង"។

មានគ្រួសារប្រហែល ៨២% បានសម្អាតទឹកសម្រាប់ហូប តាមការដាំឲ្យពុះ (៩០,៥%) ឬប្រើធុងចម្រោះ (១០%)។ ពួកគេជឿថា ការធ្វើទឹកឲ្យស្អាត ជាចំណុចល្អដើម្បីថែទាំសុខភាព រីឯអ្នកដែលមិនធ្វើដូច្នោះបានពន្យល់ថា មកពី "គ្មានពេល" ដាំទឹក។ គ្រួសារមួយភាគតិច បានប្រកាន់ខ្ជាប់ទំលាប់មិនដាំទឹក ឬសម្អាតទឹកសម្រាប់ហូប ព្រោះពួកគេគ្មានទម្លាប់នេះ។ ការយល់ឃើញថា ទឹកនៅវាល្អសម្រាប់សុខភាពនេះ ជាកត្តាមួយទៀតដែលធ្វើឲ្យគ្រួសារ មិនសូវចង់សម្អាតទឹកសម្រាប់ហូប។ ឧទាហរណ៍ គ្រូបង្រៀនថ្នាក់បឋមសិក្សាម្នាក់បានលើកថា "ពួកអ្នកភូមិមិនជឿ (លើការដាំទឹក) ទេ។ ពួកគេនិយាយថា យើងធ្លាប់ផឹកទឹកក្នុងដានជើងគោ តាំងពីដូនតា មកម្លេះ"។

### *អាកប្បកិរិយារបស់គ្រួសារចំពោះការហូបទឹកស្អាត និងអនុវត្តវិធីអនាម័យ*

លទ្ធផលការសិក្សាបញ្ជាក់ថា គ្រួសារភាគច្រើនមានអាកប្បកិរិយាគាំទ្រការហូបទឹកស្អាត ការលាងដៃ ជាពិសេស ការប្រើបង្គន់មានអនាម័យល្អ ទោះបីគ្រួសារខ្លះនៅអនុវត្តផឹកទឹកនៅតាមទំលាប់ និងមិនទាន់ទម្លាប់ខ្លួនលាងដៃក្តី។ គ្រួសារប្រហែល ៨២% បានសម្អាតទឹក ដោយដាំពុះ ឬច្រោះ។ ស្ទើរគ្រប់មេគ្រួសារបញ្ជាក់ថា ទម្លាប់លាងដៃ ជាមួយតែទឹក ឬជាមួយទឹកនិងសាប៊ូ ឃើញមានជាទូទៅ។ គ្រួសារអ្នកមានបង្គន់ តែងប្រើបង្គន់ផ្ទាល់ខ្លួន ឬបង្គន់សាធារណៈ រីឯគ្រួសារអ្នកគ្មានបង្គន់ភាគច្រើនតែងបន្ទោរបង់ពាសវាលពាសកាល (OD) (៦៥%) ឬដោយជីកកប់ (២៣%)។

## សន្និដ្ឋាន

គ្រួសារនៅតាមជនបទ មានចំណេះដឹងខ្ពស់ពីបញ្ហាអនាម័យសុខភាព ការហូបទឹកស្អាត និងការស្តុកទឹក។ អាកប្បកិរិយាចំពោះការទទួលយកការអនុវត្ត S&H ការហូបទឹកស្អាត និងជាពិសេស ការប្រើបង្គន់អនាម័យ មានលក្ខណៈវិជ្ជមាន ទោះបីមានគ្រួសារខ្លះនៅតែអនុវត្ត ការហូបទឹកនៅតាមទំលាប់ពីបុរាណ និងមិនលាងដៃឲ្យបានទៀងទាត់តាមវិធានការ S&H។

គ្រួសារមានបង្គន់អនាម័យ តែងថែរក្សាវាឲ្យដំណើរការបាន ហើយសមាជិកគ្រួសារតែងប្រើប្រាស់វាជានិច្ច។ គ្រួសារអ្នកគ្មានបង្គន់អនាម័យ តែងបន្ទោរបង់ពាសវាលពាសកាល ឬជីកកប់ ដោយប្រើកន្លែងទាំងនេះ ទាំងនៅរដូវវស្សា និងរដូវប្រាំង។ បង្គន់ចាក់ទឹកជាប្រភេទពេញនិយមជាងគេ ទោះជាគ្រួសារមានធនធានតិចឬច្រើនក្តី ប៉ុន្តែចំណាប់អារម្មណ៍ថា ការសាងសង់បង្គន់ត្រូវចំណាយអស់ច្រើនពេក ធ្វើឲ្យប្រជាជនមិនចង់ទាំងគិតគូរពីការធ្វើបង្គន់ផង។ គ្រួសារភាគច្រើនតែងប្រើបង្គន់សាធារណៈនៅពេលទៅកន្លែងសាធារណៈ ដូចជា វត្ត ឬសាលារៀន។ រឿងនេះបង្ហាញថា ការមានបង្គន់ពុំមានទាស់ខុសអ្វីទេ ហើយបញ្ជាក់គាំទ្រដល់លទ្ធផលរកឃើញថា ចំណាយ និងការយល់ឃើញពីចំណាយខ្ពស់ ជាឧបសគ្គចម្បងចំពោះការសាងសង់បង្គន់។ គ្រួសារនានារារែកជាខ្លាំងក្នុងការប្រើកម្ចី MFIs ដើម្បីសាងសង់បង្គន់ ពីព្រោះមិនមែនគ្រាន់តែ ខ្លាចមិនអាចបំពេញបានតាមលក្ខខណ្ឌសងកម្ចីវិញនោះទេ ប៉ុន្តែវិនិយោគលើបង្គន់ក៏គ្មានផ្តល់ជាប្រាក់ចំណូលអ្វីដែរហើយចំណុចនេះបង្ហាញថា ការរកចំណូលដោះស្រាយជីវភាពប្រចាំថ្ងៃ មានអាទិភាពខ្ពស់ជាង ការមានអនាម័យល្អ។ អ្នកឆ្លើយសម្ភាសន៍ជាច្រើននាក់បានអះអាងថា គាត់នឹងសន្សំប្រាក់ធ្វើបង្គន់ បើសិនអាចរកបានគ្រប់គ្រាន់ សម្រាប់ដោះស្រាយតម្រូវការចំណាយប្រចាំថ្ងៃ និងសន្សំ បានមួយចំនួន។ ស្ទើរគ្រប់គ្រួសារបានដឹងពីផលប្រយោជន៍នៃការលាងដៃ ប៉ុន្តែការយល់ឃើញថាត្រូវលាងដៃនៅពេលណាវាជាប់ទាក់ទងនឹងមុខរបររបស់ពួកគេ។ស្ទើរគ្រប់គ្រួសារបានបញ្ជាក់ថា ទម្លាប់លាងដៃ ជាមួយតែទឹក ឬជាមួយទឹកនិងសាប៊ូ ឃើញមានអនុវត្តជាទូទៅ នៅមុនពេល និងក្រោយពេលបរិភោគ ក្រោយពេលទៅបន្ទោរបង់ និងនៅពេលដៃកខ្វក់។ ពួកកុមារច្រើនលាងដៃបានញឹកញាប់ជាង ពីព្រោះ S&H ជាផ្នែក

មួយនៃកម្មវិធីរបស់សាលារៀន ហើយលោក/អ្នកគ្រូ តែងរំលឹកសិស្សជាប្រចាំអំពីសារៈសំខាន់ នៃការលាងដៃ។

គ្រួសារភាគច្រើនបានសម្អាតទឹកសម្រាប់ហូប ដោយដាំពុះ ឬច្រោះ ដើម្បីរក្សាសុខភាពឲ្យបានល្អ និងបានដឹងពីការស្តុកទឹកទុកឲ្យស្អាត ដើម្បីបង្ការការឆ្លងមេរោគចូល។

## អនុសាសន៍

ថ្វីបើ ដំណោះស្រាយអំពីសេវាអនាម័យគ្របដណ្តប់ ក៏ដូចជាការទទួលបាននូវទឹកស្អាតសម្រាប់ហូប និងប្រើប្រាស់ និងការមានបង្គន់ផ្ទាល់ខ្លួននៅតាមតំបន់ជនបទ នៅមានកម្រិតនៅឡើយ ការលើកកម្ពស់អនាម័យតាមរយៈការផ្ញើសារអំពី S&H និងការលើកទឹកចិត្ត ប្រជាជនឲ្យទទួលអនុវត្ត S&H ជាប្រចាំ អាចជួយឲ្យប្រជាជននៅជនបទ អាចថែទាំសុខភាពរបស់ខ្លួន បានអស់ពីកម្លាំងកាយ ក៏ដូចជាអាចរក្សាចំណូលក្នុងគ្រួសារតាមរយៈការកាត់បន្ថយចំណាយលើសុខភាព។ ដោយផ្អែកលើលទ្ធផលនៃអង្កេត មានសកម្មភាពមួយចំនួនដូចខាងក្រោម ដែលគួរពិចារណាដាក់បញ្ចូលទៅក្នុងគោលនយោបាយ និងផែនការ៖

- គួររចនារៀបចំកម្មវិធីផ្សព្វផ្សាយ ជំរុញការផ្លាស់ប្តូរអាកប្បកិរិយាមួយ ដោយផ្តោតលើគ្រួសារមួយភាគតូចដែលមិនទាន់ទទួលអនុវត្ត S&H និងជំរុញការទទួលយកជាសាធារណៈ និងការប្រើប្រាស់ទឹកស្អាត និងស្តុកទឹកឲ្យស្អាត។
- ផ្តល់អាទិភាពដល់ការផ្សព្វផ្សាយកម្មវិធីអប់រំ S&H ជាសាធារណៈ ក្នុងនេះ វិទ្យុ និងទូរទស្សន៍ ជាច្រកសំខាន់សម្រាប់ផ្តល់ព័ត៌មាន និងលើកទឹកចិត្តប្រជាជនគ្រប់គ្នាទោះមានកម្រិតអប់រំទាប ឬខ្ពស់ក្តី។
- លើកកម្ពស់ការបណ្តុះបណ្តាលមានការរចនារៀបចំល្អ ដល់សហគមន៍ ឲ្យក្លាយជាប្រភពទី២ នៃសារផ្សព្វផ្សាយលើកកម្ពស់អនាម័យ និងការប្រើទឹកស្អាត និងត្រូវរំលឹកប្រជាជនជាប់ជានិច្ចពី ផលប្រយោជន៍នៃការអនុវត្ត S&H ។
- ធ្វើការងារបន្តពីអន្តរាគមន៍ផ្សេងៗក្នុងពេលកន្លងមកដែលបានផ្តល់កម្ចីសម្រាប់សាងសង់បង្គន់ ក្នុងទម្រង់ជាក្រុមសន្សំ ហើយគួររៀបចំនិងបង្កើតគម្រោងការស្រដៀងគ្នាផ្សេងទៀត សម្រាប់សហគមន៍ និងគ្រួសារដែលមិនអាចទទួលបានកម្ចី ពី MFIs។

## ឯកសារយោង


Council for the Development of Cambodia (2011), "Statement of the Rural Water Supply and Sanitation Sector in the Kingdom of Cambodia", available at <http://www.cdc-crdb.gov.kh/cdc/first_cdcf/session1/statement_rwss_eng.htm> (accessed 1 February 2012)

Ministry for Rural Development (2010), *National Sanitation and Hygiene Knowledge, Attitudes and Practices (KAP) Survey: Final Report* (Phnom Penh: Department of Rural Health Care, MRD)

Mom Chan Dara Soleil (2011), "Improving Rural Sanitation and Hygiene in Rural Cambodia", [online] Agence Kampuchea Press (AKP) 23 March 2012, available at <http://www.akp.gov.kh/?p=3834> (accessed 1 February 2012)

Rosenboom, J.W., C. Jacks, K. Phyrum, M. Roberts & T. Baker (2011), "Sanitation marketing in Cambodia", *Journal of Waterlines,* Vol. 30, No.1, pp. 21-40

World Bank (2008), *Economic Impacts of Sanitation in Cambodia: A five country study conducted in Cambodia, Indonesia, Lao PDR, the Philippines and Vietnam under the Economics of Sanitation Initiative (ESI)* (Jakarta: World Bank)


*តពីទំព័រ ៩* **ឥណទានសម្រាប់...**

បណ្តុះបណ្តាលពីជំនាញធ្វើអាជីវកម្ម កសិករមានលទ្ធភាពកាន់តែប្រសើរក្នុងការប្រើប្រាស់កម្ចីបានពី MFIs ឲ្យមានប្រសិទ្ធភាព និងជោគជ័យ។ NGOs និងដៃគូអភិវឌ្ឍន៍នានា អាចដាក់បញ្ចូលវិធានការទាំងនេះទៅក្នុងកម្មវិធីអភិវឌ្ឍន៍របស់ខ្លួន។

***ពង្រីកនូវកម្មវិធីគាំពារសង្គម៖*** ដោយងាយរងគ្រោះជាខ្លាំងនឹងការប៉ះទង្គិចផ្សេងៗ ប្រជាជនក្រីក្រតែងពឹងផ្អែកលើការខ្ចីបុលនៅពេលប្រាក់ចំណូលត្រូវតឹងតែងខ្លាំង ទោះបីមានហានិភ័យខ្ពស់នៃការធ្លាក់ខ្លួនជំពាក់បំណុលកាន់តែច្រើនក្តី។ កំណើនវិនិយោគក្នុងកម្មវិធីគាំពារសង្គម អាចជួយកាត់បន្ថយហានិភ័យ និងភាពងាយរងគ្រោះក្នុងចំណោមអ្នកក្រ និងជួយការពារពួកគេកុំឲ្យធ្លាក់ខ្លួនជំពាក់បំណុល។

## ឯកសារយោង


Agrifood Consulting International (2005), Final Report for the Cambodia Agrarian Structure Study, prepared for the Ministry of Agriculture, Forestry and Fisheries, Royal Government of Cambodia, the World Bank, the Canadian International Development Agency (CIDA) and the Government of Germany/Gesellschaft für Technische Zusammenarbeit (GTZ) (Bethesda, MA: ACI)

Cambodia Microfinance Association (2011), Microfinance Information Exchange (Phnom Penh: CMA)

Kim S (2001), "Reciprocity: Informal Patterns of Social Interactions in a Cambodian Village", master's thesis, Northern Illinois University, Illinois

MLMUPC (2011), Land Adminstration Sub Sector Program Newsletter, Issue 1(Phnom Penh: Ministry of Land Management Urban Planning and Construction (MLMUPC))


*តទៅទំព័រ ២១*

# តាមដានសេដ្ឋកិច្ច - ស្ថានភាពក្រៅប្រទេស[១]

ផ្នែកនេះ បង្ហាញពីសូចនាករសេដ្ឋកិច្ចនៃប្រទេសធំៗមួយចំនួនក្នុងពិភពលោក និងបណ្ដាប្រទេសនៅអាស៊ីអាគ្នេយ៍។

សេដ្ឋកិច្ចពិភពលោក បាននិងកំពុងងើបឡើងវិញជាបណ្ដើរៗ ពីវិបត្តិហិរញ្ញវត្ថុ និងសេដ្ឋកិច្ចដ៏ធ្ងន់ធ្ងរបំផុត គិតចាប់តាំងពីមហាវិបត្តិសេដ្ឋកិច្ចនៅទសវត្សរ៍១៩៣០ មក ទោះបីមានសញ្ញាបង្ហាញពីការធ្លាក់ចុះសេដ្ឋកិច្ច ក្នុងប្រទេសអាស៊ីមួយចំនួន នៅត្រីមាសទី២ ឆ្នាំ២០១២ ក្តី។

កំណើន ផសស ពិត នៅប្រទេសឥណ្ឌូនេស៊ី បានធ្លាក់ចុះបន្តិចនៅត្រីមាសទី២ មកត្រឹម ៦,៤% ធៀបនឹង ៦,៥% កាលពីមួយឆ្នាំមុន រីឯសេដ្ឋកិច្ចរបស់ប្រទេសម៉ាឡេស៊ី និងសិង្ហបុរី នៅបន្តមានសន្ទុះ ដោយមានកំណើន ផសស ឡើងដល់ ៥,៤% និង ១,៩% រៀងៗគ្នា។ នៅប្រទេសចិន និងប្រទេសខ្លះអាស៊ីភាគខាងកើតមួយចំនួន មានសញ្ញានៃការធ្លាក់ចុះសេដ្ឋកិច្ច។ កំណើន ផសស ពិត នៅចិន ធ្លាក់ចុះមកត្រឹម ៧,៦% ធៀបនឹង ៩,៥% កាលពីមួយឆ្នាំមុន។ កំណើននៅហុងកុង ធ្លាក់មកត្រឹម ៣,៦% ហើយនៅកូរ៉េខាងត្បូង វាធ្លាក់មកត្រឹម ២,៤% ដែលជាអត្រាទាបបំផុតគិតចាប់ពីឆ្នាំ២០១០ មក។ ប្រទេសតៃវ៉ាន់ មានអត្រាកំណើនអវិជ្ជមានដល់ -០,២% ធៀបនឹង ៤,៩% កាលពីមួយឆ្នាំមុន។ គ្រោះធម្មជាតិបានកើតមានជាញឹកញាប់នៅតំបន់អាស៊ី ក្នុង ២ឆ្នាំចុងក្រោយនេះ។ ព្យុះទីហ្វុងដ៏ខ្លាំងឈ្មោះ Bolaven បានសម្លាប់មនុស្ស ព្រមទាំងបំផ្លាញផ្ទះសំបែង និងបណ្ដាញអគ្គិសនី និងទូរគមនាគមន៍ នៅភាគខាងជើងនៃប្រទេសកូរ៉េខាងត្បូង ដោយធ្វើឲ្យសំណង់រាប់ពាន់ខ្នងគ្មានចរន្តអគ្គិសនី។ ព្យុះទីហ្វុងនេះ ក៏នឹងប៉ះពាល់ដល់ប្រទេសចិនដែរ។ មួយវិញទៀត ភាពតានតឹងនៃជម្លោះដណ្ដើមកោះមួយចំនួន បានធ្វើឲ្យកករល្អក់ដល់ចំណងទាក់ទងខាងនយោបាយ និងសេដ្ឋកិច្ចរវាងប្រទេសចិន កូរ៉េខាងត្បូង និងជប៉ុន និងប៉ះពាល់កាន់តែខ្លាំងដល់សកម្មភាពសេដ្ឋកិច្ចជាពិសេសពាណិជ្ជកម្ម។

តំបន់អឺរ៉ូ បន្តប្រឹងប្រែងប្រោះព្រំសេដ្ឋកិច្ចរបស់ខ្លួនឡើងវិញ ដោយមានវិបត្តិសេដ្ឋកិច្ចមួយទៀតកំពុងគំរាមផ្ទុះឡើង។ កំណើន ផសស នៅតំបន់អឺរ៉ូ១២ នៅត្រីមាសទី២ រួមចុះមកត្រឹម ០,៤% ធៀបនឹង ១,៦% ក្នុងរយៈពេលដូចគ្នានៅឆ្នាំមុន។ សេដ្ឋកិច្ចសហរដ្ឋអាមេរិក មានលទ្ធផលប្រៀបធៀបល្អគួរសម ដោយមានកំណើន ២,២% ធៀបនឹង ១,៥% ក្នុងរយៈពេលដូចគ្នាឆ្នាំមុន។ ប្រទេសជប៉ុន មានកំណើន ៣,៥% ធៀបនឹងកំណើនអវិជ្ជមាន -១,០% នៅត្រីមាសទី២ ឆ្នាំមុន។

## អតិផរណាក្នុងពិភពលោក និងអត្រាប្ដូរប្រាក់

នៅត្រីមាសទី២ នេះ អតិផរណាអាចគ្រប់គ្រងបានយ៉ាងល្អ បើធៀបនឹងឆ្នាំមុន។ អតិផរណាប្រចាំឆ្នាំនៅកម្ពុជា ធ្លាក់ចុះមកត្រឹម ២,៩% ធៀបនឹង ៦,៥% កាលពីមួយឆ្នាំមុន។ ប្រទេសវៀតណាម សម្រេចបានអត្រាអតិផរណាមានលេខមួយខ្ទង់គឺ ៨,៦%។ អត្រាអតិផរណានៅប្រទេសផ្សេងៗទៀតក៏គ្រប់គ្រងបានល្អដែរ។ អតិផរណានៅចិន ធ្លាក់ចុះមកត្រឹម ២,៩% នៅត្រីមាសទី២ ធៀបនឹង ៥,៧% នៅត្រីមាសដូចគ្នាឆ្នាំមុន។ កម្រិតថ្លៃសរុបនៅប្រទេសជប៉ុន កើនឡើង ០,២% ធៀបនឹង ០,៣% កាលពីមួយឆ្នាំមុន។

នៅត្រីមាសទី២ ប្រាក់រៀលទល់នឹងដុល្លារអាមេរិក ធ្លាក់ថ្លៃ ០,២% ធៀបនឹងត្រីមាសមុន (ធ្លាក់ ០,២៣% ធៀបនឹងមួយឆ្នាំមុន) ដោយប្ដូរបាន ៤០៥៤,៣រៀល/ដុល្លារ។ ក្នុងរយៈពេលដូចគ្នា ប្រាក់បាតថៃ ធ្លាក់ថ្លៃ ០,៩% (៣,៣% កាលពីមួយឆ្នាំមុន) ទល់នឹងដុល្លារ។ ប្រាក់យ៉ន់ចិន ធ្លាក់ថ្លៃ ០,៣% ប៉ុន្តែឡើងថ្លៃ ២,៦% បើធៀបនឹងកាលពីមួយឆ្នាំមុន។

## ថ្លៃទំនិញប្រើប្រាស់នៅលើទីផ្សារពិភពលោក

នៅត្រីមាសទី២ ពោត (US No. 2) ធ្លាក់ថ្លៃ ២,៥% ធៀបនឹងត្រីមាសមុន (ធ្លាក់ ១៣,២% ធៀបនឹងមួយឆ្នាំមុន) មកត្រឹម ២៧០,៤ដុល្លារ/តោន ហើយកៅស៊ូ (SMR 5) ធ្លាក់ថ្លៃ ៩,២% (៣២,៤% ធៀបនឹងមួយឆ្នាំមុន) មកត្រឹម ៣៣៦១ដុល្លារ/តោន។ ក្នុងពេលជាមួយគ្នា អង្ករ (Thai 100% B) ឡើងថ្លៃ ៩,៣% (១៦,៧% ធៀបនឹងមួយឆ្នាំមុន) ដល់ ៦០០,៣ដុល្លារ/តោន ប្រេងឆាឡើងថ្លៃ ២,៤% (ប៉ុន្តែធ្លាក់ថ្លៃ ១,២% ធៀបនឹងមួយឆ្នាំមុន) ដល់ ១១៣៣ដុល្លារ/តោន ហើយសណ្ដែកសៀង (US No. 1) ឡើងថ្លៃ ១១,៤% (ឡើង ៣,៩% ធៀបនឹងមួយឆ្នាំមុន) ដល់ ៥៤៦,៥ដុល្លារ/តោន។ សាំង (US Gulf Coast) ធ្លាក់ថ្លៃ ៦,៣% ធៀបនឹងត្រីមាសមុន (ធ្លាក់ ៦,០% ធៀបនឹងមួយឆ្នាំមុន) មកត្រឹម ០,៧៤ដុល្លារ/លីត្រ។ មាស៊ូត (low sulphur No.2) ធ្លាក់ថ្លៃ ៧,១% ធៀបនឹងត្រីមាសមុន មកត្រឹម ០,៧៨ដុល្លារ/លីត្រ ប៉ុន្តែឡើងថ្លៃ ២,៧% ធៀបនឹងមួយឆ្នាំមុន។ សព្វថ្ងៃមានការបារម្ភថា ថ្លៃស្បៀងអាហារក្នុងពិភពលោកអាចកើនឡើង ដោយសារមានគ្រោះធម្មជាតិជាញឹកញាប់ក្នុង ៦ខែចុងក្រោយនេះ។

[១] អត្ថបទនេះ រៀបរៀងដោយលោក រ័ត្ន វឌ្ឍនា អ្នកស្រាវជ្រាវនៅវិទ្យាស្ថាន CDRI។


**Cambodia Development Review—2012 Subscription Rates**

**Domestic Subscription (Individual)**

❒ English edition ($14) ❒ Khmer edition (5,000 riels) Payment by ❒ cash or ❒ local cheque (please add $2 to cover bank charges for processing local cheques). Total payment enclosed..........

**Domestic Subscription (Discount Price for Bulk Orders—Five Copies)**

❒ English edition ($60 for five copies) ❒ Khmer edition (20,000 riels for five copies) Payment by ❒ cash or ❒ local cheque (please add $2 to cover bank charges). Total payment enclosed..........

**International Subscription (Individual)**

❒ Thailand, Laos, Vietnam ❒ English edition ($25)* ❒ Khmer edition ($15)*
❒ Asia and Europe ❒ English edition ($30)* ❒ Khmer edition ($20)*
❒ Americas and Africa ❒ English edition ($35)* ❒ Khmer edition ($25)*

**Details for payment by telegraphic transfer**

Account Name: CDRI
Account Number: 133451
Bank Name: ANZ Royal Bank (Cambodia) Ltd
Bank Address: Phnom Penh, Cambodia Head Office
Swift Code: ANZBKHPP
Receiver Correspondent Bank: JP Morgan Chase Manhattan Bank, N.A., New York, USA
Swift Code: CHASUS33

Title: ❒Mr ❒Ms ❒Dr ❒ Other ..........
First name: .......... Last name: .......... Position: ..........
Organisation / Company: ..........
Address (CCC Box if applicable): ..........
City / Province: .......... Country: ..........
Telephone: .......... Fax: ..........
e-mail: .......... ❒ Tick to receive regular information about CDRI publications via e-mail

To subscribe, please fill in this form and return it to CDRI with your payment. Do not send cash through the post.
You will need to inform the Publishing Department at CDRI if your contact details change.

### តារាង១. កំណើន ផសស ពិត នៃដៃគូពាណិជ្ជកម្មជ្រើសរើស ពីឆ្នាំ២០០៦-២០១២ (កំណើនជាភាគរយធៀបនឹងឆ្នាំមុន)

| | 2006 | 2007 | 2008 | 2009 | 2010 | | 2011 | | | | 2012 | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | Q3 | Q4 | Q1 | Q2 | Q3 | Q4 | Q1 | Q2 |
| ប្រទេសអាស៊ានជ្រើសរើស | | | | | | | | | | | | |
| កម្ពុជា | 10.6 | 10.2 | 6.8 | 0.1 | - | - | - | - | - | - | - | - |
| ឥណ្ឌូនេស៊ី | 5.4 | 6.3 | 6.1 | 4.2 | 5.8 | 6.9 | 6.5 | 6.5 | 6.5 | 6.5 | 6.3 | 6.4 |
| ម៉ាឡេស៊ី | 5.9 | 6.3 | 4.6 | -2.4 | 5.3 | 4.8 | 4.6 | 4.0 | 5.8 | 5.2 | 4.7 | 5.4 |
| សិង្ហបុរី | 7.7 | 7.7 | 1.1 | -4.5 | 10.5 | 12.0 | 8.3 | 0.9 | 5.9 | 3.6 | 1.6 | 1.9 |
| ថៃ | 4.8 | 4.9 | 2.6 | 3.3 | 6.7 | 3.8 | 3.0 | 2.6 | 3.5 | -9.0 | 0.0 | 4.2 |
| វៀតណាម | 8.1 | 8.5 | 6.2 | 4.7 | 7.2 | 7.3 | 5.4 | 5.7 | 7.2 | 6.1 | - | - |
| ប្រទេសអាស៊ីជ្រើសរើស | | | | | | | | | | | | |
| ចិន | 10.5 | 11.9 | 9.0 | 8.2 | 9.7 | 9.8 | 9.7 | 9.5 | 9.1 | 8.9 | 8.1 | 7.6 |
| ហុងកុង | 6.6 | 6.4 | 2.4 | -3.2 | 6.8 | 6.2 | 7.2 | 5.1 | 4.3 | 3.0 | 4.2 | 3.6 |
| កូរ៉េខាងត្បូង | 5.0 | 4.9 | 2.2 | -1.0 | 4.5 | 4.8 | 4.2 | 3.4 | 3.4 | 3.4 | 3.0 | 2.4 |
| តៃវ៉ាន់ | 4.6 | 5.2 | 0.1 | -3.6 | 9.8 | 6.9 | 6.5 | 4.9 | 3.4 | 1.9 | 0.4 | -0.2 |
| ប្រទេសឧស្សាហកម្មជ្រើសរើស | | | | | | | | | | | | |
| អឺរ៉ូ-១២ | 2.7 | 2.9 | 0.9 | -3.8 | 1.9 | 2.0 | 2.5 | 1.6 | 1.4 | 0.7 | 0.0 | -0.4 |
| ជប៉ុន | 2.1 | 2.0 | -0.7 | -5.4 | 5.0 | 2.2 | -1.0 | -1.0 | 0.0 | -1.0 | 2.8 | 3.5 |
| សហរដ្ឋអាមេរិក | 3.3 | 2.2 | 1.1 | -2.5 | 2.3 | 2.8 | 2.3 | 1.5 | 1.6 | 1.6 | 2.1 | 2.2 |

*Sources: International Monetary Fund, Economist and countries' statistic offices.*

### តារាង២. អត្រាអតិផរណានៃដៃគូពាណិជ្ជកម្មជ្រើសរើស ពីឆ្នាំ២០០៦-២០១២ (កំណើនជាភាគរយធៀបនឹងឆ្នាំមុន-មធ្យមភាគតាមការិយបរិច្ឆេទ)

| | 2006 | 2007 | 2008 | 2009 | 2010 | | 2011 | | | | 2012 | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | Q3 | Q4 | Q1 | Q2 | Q3 | Q4 | Q1 | Q2 |
| ប្រទេសអាស៊ានជ្រើសរើស | | | | | | | | | | | | |
| កម្ពុជា | 4.7 | 10.5 | 19.7 | | 1.8 | 3.3 | 3.6 | 6.2 | 6.7 | 4.9 | 5.5 | 2.9 |
| ឥណ្ឌូនេស៊ី | 13.4 | 6.4 | 10.1 | 4.7 | 6.2 | 6.3 | 6.8 | 5.9 | 4.7 | 4.1 | 3.8 | 4.5 |
| ម៉ាឡេស៊ី | 3.7 | 2.0 | 5.3 | 0.4 | 1.9 | 2.1 | 2.8 | 3.3 | 3.4 | 3.2 | 2.3 | 1.7 |
| សិង្ហបុរី | 1.0 | 2.1 | 6.5 | 0.5 | 3.4 | 4.0 | 5.2 | 4.7 | 5.5 | 5.5 | 4.9 | 5.2 |
| ថៃ | 4.7 | 2.2 | 5.5 | -0.9 | 3.3 | 2.0 | 3.0 | 4.1 | 4.1 | 4.0 | 3.4 | 2.6 |
| វៀតណាម | 7.7 | 8.3 | 23.3 | 7.3 | 8.4 | 10.9 | 12.8 | 19.4 | 22.5 | 19.8 | 16.0 | 8.6 |
| ប្រទេសអាស៊ីជ្រើសរើស | | | | | | | | | | | | |
| ចិន | 1.5 | 4.8 | 5.9 | -0.8 | 3.3 | 4.7 | 5.1 | 5.7 | 6.3 | 4.6 | 3.8 | 2.9 |
| ហុងកុង | 2.2 | 2.0 | 4.3 | -0.3 | 2.3 | 2.9 | 4.0 | 5.1 | 6.5 | 5.7 | 5.2 | 4.2 |
| កូរ៉េខាងត្បូង | 2.4 | 2.5 | 4.6 | 2.8 | 2.9 | 3.6 | 4.4 | 4.2 | 4.8 | 4.1 | 2.9 | 2.4 |
| តៃវ៉ាន់ | 0.6 | 1.8 | 3.2 | -1.1 | 0.4 | 1.1 | 1.3 | 1.6 | 1.3 | 1.4 | 1.3 | 1.6 |
| ប្រទេសឧស្សាហកម្មជ្រើសរើស | | | | | | | | | | | | |
| អឺរ៉ូ-១២ | 2.1 | 2.1 | 3.3 | 0.4 | 1.7 | 2.0 | 2.5 | 2.7 | 2.7 | 2.9 | 2.7 | 2.5 |
| ជប៉ុន | 0.5 | 0.1 | 1.4 | -1.3 | -0.9 | 0.1 | 0.0 | 0.3 | 0.2 | -0.3 | 0.3 | 0.2 |
| សហរដ្ឋអាមេរិក | 3.2 | 2.9 | 3.8 | -0.4 | 1.2 | 1.3 | 2.1 | 3.5 | 3.8 | 3.3 | 2.8 | 1.9 |

*Sources: International Monetary Fund, Economist and National Institute of Statistics.*

### តារាង៣. អត្រាប្តូរប្រាក់ធៀបនឹងដុល្លារអាមេរិកនៃរូបិយវត្ថុរបស់ដៃគូពាណិជ្ជកម្មជ្រើសរើស ពីឆ្នាំ២០០៦-២០១២ (មធ្យមភាគតាមការិយបរិច្ឆេទ)

| | 2006 | 2007 | 2008 | 2009 | 2010 | 2011 | | | | 2012 | |
|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | Q4 | Q1 | Q2 | Q3 | Q4 | Q1 | Q2 |
| ប្រទេសអាស៊ានជ្រើសរើស | | | | | | | | | | | |
| កម្ពុជា (រៀល) | 4103.20 | 4062.70 | 4054.20 | 4140.48 | 4122.58 | 4041.90 | 4044.89 | 4095.66 | 4071.89 | 4045.98 | 4054.26 |
| ឥណ្ឌូនេស៊ី (រូពីយ៉ា) | 9134.00 | 9419.00 | 9699.00 | 10413.83 | 8965.70 | 8902.02 | 8593.94 | 8625.83 | 8985.65 | 9078.63 | 9281.28 |
| ម៉ាឡេស៊ី (រីងហ្គិត) | 3.70 | 3.30 | 3.30 | 3.52 | 3.11 | 3.05 | 3.02 | 3.02 | 3.15 | 3.06 | 3.11 |
| សិង្ហបុរី (ដុល្លារសិង្ហបុរី) | 1.59 | 1.51 | 1.42 | 1.45 | 1.30 | 1.28 | 1.24 | 1.23 | 1.29 | 1.26 | 1.26 |
| ថៃ (បាត) | 37.90 | 32.22 | 33.36 | 34.34 | 29.99 | 30.56 | 30.28 | 30.15 | 30.98 | 31.00 | 31.28 |
| វៀតណាម (ដុង) | 15,994.00 | 16,030.00 | 16,382.00 | 17,725.24 | 19,499.48 | 20,273.83 | 20,693.58 | 20,699.60 | 20,997.70 | 20,971.18 | - |
| ប្រទេសអាស៊ីជ្រើសរើស | | | | | | | | | | | |
| ចិន (យ៉ន់) | 7.97 | 8.03 | 6.94 | 6.83 | 6.66 | 6.58 | 6.50 | 6.42 | 6.36 | 6.31 | 6.33 |
| ហុងកុង (ដុល្លារហុងកុង) | 7.77 | 7.80 | 7.78 | 7.75 | 7.76 | 7.79 | 7.78 | 7.79 | 7.78 | 7.76 | 7.76 |
| កូរ៉េខាងត្បូង (វ៉ុន) | 955.00 | 929.04 | 1137.23 | 1277.76 | 1132.85 | 1120.19 | 1084.27 | 1084.90 | 1144.87 | 1131.17 | 1152.59 |
| តៃវ៉ាន់ (ដុល្លារតៃវ៉ាន់-NT$) | 32.50 | 32.85 | 31.54 | 33.04 | 30.36 | 29.30 | 28.86 | 29.19 | 30.26 | 29.68 | 29.62 |
| ប្រទេសឧស្សាហកម្មជ្រើសរើស | | | | | | | | | | | |
| អឺរ៉ូ-១២ (អឺរ៉ូ) | 0.80 | 0.70 | 0.84 | 0.72 | 0.74 | 0.73 | 0.70 | 0.71 | 0.74 | 0.76 | 0.77 |
| ជប៉ុន (យ៉េន) | 116.40 | 117.80 | 102.46 | 93.60 | 82.53 | 82.33 | 81.66 | 77.86 | 77.78 | 79.30 | 80.07 |

*Sources: International Monetary Fund, Economist and National Bank of Cambodia*

### តារាង៤. ថ្លៃផលិតផលជ្រើសរើសនៅលើទីផ្សារពិភពលោក ពីឆ្នាំ២០០៦-២០១២ (មធ្យមភាគតាមការិយបរិច្ឆេទ)

| | 2006 | 2007 | 2008 | 2009 | 2010 | 2011 | | | | 2012 | |
|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | Q4 | Q1 | Q2 | Q3 | Q4 | Q1 | Q2 |
| ពោត (US No. 2) - USA (USD/តោន) | 111.04 | 149.08 | 218.15 | 167.31 | 238.81 | 280.32 | 311.63 | 302.79 | 270.77 | 277.50 | 270.46 |
| ប្រេងឆា-អឺរ៉ុបពាយព្យ (USD/តោន) | 433.85 | 707.68 | 912.23 | 686.84 | 1108.00 | 1251.00 | 1147.00 | 1079.00 | 1024.67 | 1106.67 | 1133.0 |
| កៅស៊ូ SMR 5 (USD/តោន) | 1996.30 | 2202.30 | 2586.30 | 1884.84 | 4257.27 | 5278.03 | 4968.77 | 4617.57 | 3658.00 | 3701.17 | 3361.0 |
| អង្ករ (Thai 100%B) - បាងកក (USD/តោន) | 282.00 | 305.36 | 615.32 | 524.47 | 531.00 | 528.25 | 514.33 | 581.3 | 610.33 | 549.00 | 600.3 |
| សណ្តែកសៀង (US No. 1) - USA (USD/តោន) | 213.88 | 294.59 | 460.41 | 414.03 | 480.24 | 537.24 | 525.66 | 513.98 | 454.83 | 490.79 | 546.5 |
| ប្រេងឆៅ - OPEC spot (USD/ធុង) | 61.58 | 69.25 | 95.44 | 60.50 | 84.17 | 100.70 | 113.31 | 108.91 | - | - | - |
| សាំង - US Gulf Coast (សេន/លីត្រ) | 47.70 | 53.58 | 62.22 | 42.91 | 57.23 | 67.92 | 78.73 | 74.63 | 68.50 | 78.97 | 74.0 |
| ម៉ាស៊ូត (ស្តង់ដារតិច លេខ២) - US Gulf Coast (សេន/លីត្រ) | 51.35 | 55.51 | 76.20 | 43.05 | 61.68 | 72.47 | 75.72 | 77.27 | 77.31 | 83.75 | 77.8 |

*Sources: Food and Agriculture Organisation and US Energy Information Administration*

# តាមដានសេដ្ឋកិច្ច-ស្ថានភាពក្នុងប្រទេស[1]

## សកម្មភាពសេដ្ឋកិច្ចចម្បងៗ

នៅត្រីមាសទី២ ឆ្នាំ២០១២ មានសញ្ញាបង្ហាញពីការថយល្បឿនកំណើនសកម្មភាពសេដ្ឋកិច្ចខ្លះៗ ដែលអាចដោយសារភាពមិនច្បាស់លាស់ដែលនៅមានជាបន្តក្នុងសេដ្ឋកិច្ចពិភពលោក ជាពិសេសនៅសហភាពអឺរ៉ុប និងការធ្លាក់កំណើនសេដ្ឋកិច្ចក្នុងប្រទេសអាស៊ីបូព៌ាមួយចំនួន ដូចជា ចិន កូរ៉េខាងត្បូង ហុងកុង និង តៃវ៉ាន់។ កំណើនសេដ្ឋកិច្ចនៅកម្ពុជាសម្រាប់ឆ្នាំនេះ ត្រូវបានព្យាករណ៍សាជាថ្មី ដោយបញ្ចុះពី ៧% មកត្រឹម ៦,៧%។

អនុមតិវិនិយោគសរុបគិតជាទ្រព្យសកម្មជាប់លាប់ ធ្លាក់ចុះ ៣៤,១% ធៀបនឹងត្រីមាសមុន (ចុះ ៨៩,៧% ធៀបនឹងមួយឆ្នាំមុន) មកត្រឹម ២៧៣លានដុល្លារ។ វិនិយោគក្នុងវិស័យកសិកម្ម ធ្លាក់ចុះ ៤៧,៥% (៤៨,១% ធៀបនឹងមួយឆ្នាំមុន) វិស័យឧស្សាហកម្ម ធ្លាក់ចុះ ១៦,៧% (៣២,៤% ធៀបនឹងមួយឆ្នាំមុន) ហើយវិស័យសេវាកម្ម ធ្លាក់ចុះ ៦៤,៦% (៩៩,២% ធៀបនឹងមួយឆ្នាំមុន)។ វិនិយោគខាងផ្នែកកាត់ដេរសម្លៀកបំពាក់ ដែលជាផលិតផលឧស្សាហកម្មចម្បងមួយ ធ្លាក់ចុះ ៣០,១% (១០,១% ធៀបនឹងមួយឆ្នាំមុន) រីឯវិនិយោគផ្នែកសណ្ឋាគារ និងទេសចរណ៍ មានកម្រិតសូន្យ។ តម្លៃសរុបនៃអនុមតិគម្រោងសំណង់ កើន ៣,៣% ធៀបនឹងត្រីមាសមុន (៣៣១,១% ធៀបនឹងមួយឆ្នាំមុន) ដល់ ៣៣៣,៦លានដុល្លារ។ តម្លៃនៃអនុមតិសំណង់ ភូមិគ្រឹះនិងផ្ទះ កើន ២,៨% (១០២៨,៨% ធៀបនឹងមួយឆ្នាំមុន) ដល់ ៦៦,៦លានដុល្លារ និងផ្ទះល្វែង កើន ២៦០,៧% (៨៦១,៨% ធៀបនឹងមួយឆ្នាំមុន) ដល់ ២១៩,៣លានដុល្លារ។ ចំនួនភ្ញៀវទេសចរបរទេសមកដល់ ធ្លាក់ចុះ ១៩៤,៤% ធៀបនឹងត្រីមាសមុន ប៉ុន្តែកើន ៦,៣% ធៀបនឹងមួយឆ្នាំមុន។

ការនាំចេញសរុប ធ្លាក់ចុះ ២,៩% ធៀបនឹងត្រីមាសមុន (៩,៨% ធៀបនឹងមួយឆ្នាំមុន) មកត្រឹម ១២៤៣,២លានដុល្លារ ក្នុងនេះ ការនាំចេញសម្លៀកបំពាក់ ធ្លាក់ចុះ ៣,៨% (តែកើន ៦,៩% ធៀបនឹងមួយឆ្នាំមុន) មកត្រឹម ១០៣០,៤លានដុល្លារ។ ការនាំចេញទៅសហរដ្ឋអាមេរិក ធ្លាក់ចុះ ១០,៤% (៥,៣% ធៀបនឹងមួយឆ្នាំមុន) មកត្រឹម ៤៤១,៨លានដុល្លារ ហើយការនាំចេញទៅជប៉ុន ធ្លាក់ចុះ ២៩,៥% ប៉ុន្តែកើន ២៦,១% ធៀបនឹងមួយឆ្នាំមុន។ ការនាំចេញសម្លៀកបំពាក់ទៅតំបន់អឺរ៉ូ ដែលកំពុងពុះពារការលំបាកខាងសេដ្ឋកិច្ចនោះ នៅតែរស់រវើកដោយកើន ៦,៨% ធៀបនឹងត្រីមាសមុន (១៦,៤% ធៀបនឹងមួយឆ្នាំមុន) ដល់ ៣៥០,៨លានដុល្លារ។ ការនាំចេញទៅបណ្តាប្រទេសអាស៊ានកើន២០,២%(៨៣,៩%ធៀបនឹងមួយឆ្នាំមុន)។ ការនាំចេញផលិតផលកសិកម្ម ធ្លាក់ចុះ ១១,៣% ធៀបនឹងត្រីមាសមុន (ធ្លាក់ ២៦,៤% ធៀបនឹងមួយឆ្នាំមុន) មកត្រឹម ១៥,៦លានដុល្លារ។ ការនាំចេញអង្ករ ធ្លាក់ចុះ ០,៤% (១០,៩% ធៀបនឹងមួយឆ្នាំមុន) កៅស៊ូធ្លាក់ចុះ ១៤,៩% (២៩,៥% ធៀបនឹងមួយឆ្នាំមុន) និងត្រីធ្លាក់ចុះ ២០.០%។ ក្នុងពេលជាមួយគ្នា ការនាំចូលសរុប កើន ១៧,២% (១១,៥% ធៀបនឹងមួយឆ្នាំមុន) ដល់ ១៨៨៥,៤លានដុល្លារ។ ការនាំចូលសាំង កើន ៨,៥% ធៀបនឹងត្រីមាសមុន រីឯការនាំចូលម៉ាសូត ធ្លាក់ចុះ ៩,២%។ ការនាំចូលសម្ភារៈសំណង់ កើន ៤,៤% (១១.០% ធៀបនឹងមួយឆ្នាំមុន) ដល់ ១៤,១លានដុល្លារ។ ឱនភាពពាណិជ្ជកម្ម កើន ៩៥,១% ធៀបនឹងត្រីមាសមុន (១៥,១% ធៀបនឹងមួយឆ្នាំមុន) ដល់ ៦៤២,២លានដុល្លារ។

## ហិរញ្ញវត្ថុសាធារណៈ

ការកែលំអការប្រមូលចំណូល និងការកាត់បន្ថយចំណាយហួសកម្រិតរបស់រដ្ឋាភិបាលសំខាន់ខ្លាំងណាស់ ដើម្បីកសាងកម្លាំងហិរញ្ញវត្ថុឡើងវិញ និងជៀសវាងការប្រាទចេញវិនិយោគឯកជន ដោយសារតែកម្ចីរដ្ឋាភិបាល។ នៅត្រីមាសទី១ ឆ្នាំ២០១២ ចំណូលសរុបរបស់រដ្ឋាភិបាល ធ្លាក់ចុះ ២,៧% ធៀបនឹងត្រីមាសមុន មកត្រឹម ១៧២៨,៩ពាន់លានរៀល ប៉ុន្តែកើន ១០,៥% ធៀបនឹងមួយឆ្នាំមុន។ ចំណូលចរន្ត ធ្លាក់ចុះ ៣,៥% ក្នុងនោះ ចំណូលបានពីពន្ធក្នុងស្រុក ធ្លាក់ចុះ ១,១% និងពន្ធលើពាណិជ្ជកម្មអន្តរជាតិ ធ្លាក់ចុះ ១១,១% ប៉ុន្តែចំណូលមិនមែនពន្ធ កើន ១៥,៨% (៦៩,៣% ធៀបនឹងមួយឆ្នាំមុន) ដល់ ៣៣០,៩ពាន់លានរៀល។ នៅត្រីមាសដដែល ចំណាយសរុប ធ្លាក់ចុះ ៤៥,៨% (១៦,៦% ធៀបនឹងមួយឆ្នាំមុន) មកត្រឹម ១៦៨៨,៣ពាន់លានរៀល ចំណាយមូលធន ធ្លាក់ចុះ ៥១,៦% (២,៩% ធៀបនឹងមួយឆ្នាំមុន) និងចំណាយចរន្ត ធ្លាក់ចុះ ៤០,៨% (២៤,២% ធៀបនឹងមួយឆ្នាំមុន)។ ចំណាយបៀវត្សរ៍បុគ្គលិករដ្ឋ ធ្លាក់ចុះ ១៦,៣% ធៀបនឹងត្រីមាសមុន (៤,៣% ធៀបនឹងមួយឆ្នាំមុន) មកត្រឹម ៥០៨,៩ពាន់លានរៀល និងចំណាយឧបត្ថម្ភធន និងជំនួយសង្គមកិច្ច ធ្លាក់ចុះ ៦១,១% (៥៧,៩% ធៀបនឹងមួយ ឆ្នាំមុន មកត្រឹម ១៨៩,៦ពាន់លានរៀល។

## អតិផរណា និងអត្រាប្តូរប្រាក់បរទេស

នៅត្រីមាសទី២ ឆ្នាំ២០១២ អតិផរណានៅភ្នំពេញ (គ្រប់មុខទំនិញ) ធ្លាក់ចុះមកត្រឹម ២,៩% ធៀបនឹង ៦,៣% នៅត្រីមាសដូចគ្នាឆ្នាំមុន ដោយសារមួយចំណែក ថ្លៃប្រេងក្នុងស្រុកទាប និងការបន្តធ្វើឲ្យធម្មតាឡើងវិញនូវកម្រិត ថ្លៃទំនិញទូទៅក្នុងប្រទេសជិតខាង ដូចជា វៀតណាម ជាដើម។ អត្រាឡើងថ្លៃអាហារ និងភេសជ្ជៈ គ្មានជាតិស្រា ធ្លាក់ចុះមកត្រឹម ៣,៤% ធៀបនឹង ៧,៦% កាលពីមួយឆ្នាំមុន ហើយសម្រាប់ថ្លៃដឹកជញ្ជូន វាធ្លាក់ចុះមកត្រឹម ៥,៣% ធៀបនឹង ៧,៣% កាលពីមួយឆ្នាំមុន។ នៅត្រីមាសទី២ ប្រាក់រៀលធ្លាក់ថ្លៃ ០,២១% (០,២៣% ធៀបនឹងមួយឆ្នាំមុន) ទល់នឹងប្រាក់ដុល្លារ ប៉ុន្តែឡើងថ្លៃ ០,៩% (៣,៦% ធៀបនឹងមួយឆ្នាំមុន) ទល់នឹងប្រាក់បាតថៃ។ ប្រាក់រៀលធ្លាក់ថ្លៃ ០,៥% ទល់នឹងប្រាក់ដុងវៀតណាម ប៉ុន្តែឡើងថ្លៃ ១% ធៀបនឹងមួយ

[1] អត្ថបទនេះរៀបរៀងដោយលោក រ័ត្ន វឌ្ឍនា អ្នកស្រាវជ្រាវ និងលោកស្រី ប៊ុន ដូរីណា ជាជំនួយការស្រាវជ្រាវនៅវិទ្យាស្ថាន CDRI។

ឆ្នាំមុន។ មាសធ្លាក់ថ្លៃ ៤,៧% មកត្រឹម ១៩៤,៤ដុល្លារ/ជី ប៉ុន្តែឡើងថ្លៃ ៧,១% ធៀបនឹងមួយឆ្នាំមុន។ ម៉ាសូតធ្លាក់ថ្លៃ ១៤,២% ធៀបនឹងត្រីមាសមុន (៦,៨% ធៀបនឹងមួយឆ្នាំមុន) មកត្រឹម ៤៤៥៨រៀល/លីត្រ។

## ការវិវត្តរូបិយវត្ថុ

នៅត្រីមាសទី១ ទ្រព្យសកម្មបរទេសសុទ្ធ កើន ៤,២% (៩,២% ធៀបនឹងមួយឆ្នាំមុន) ដល់ ១៨.៦៥២,៣៣ពាន់លានរៀល ហើយទ្រព្យសកម្មក្នុងស្រុកសុទ្ធ កើន ៧,៨% (៩៤,១% ធៀបនឹងមួយឆ្នាំមុន) ដល់ ៦២១១,២៣ពាន់លានរៀល។ រូបិយវត្ថុទូទៅ (M2) កើន ៥,១% (២២,៦% ធៀបនឹងមួយឆ្នាំមុន) ដល់ ២៤.៨៦៣,៥៣ពាន់លានរៀល។ ឥណទានដល់វិស័យឯកជន កើន ៧% (៣៥,១% ធៀបនឹងមួយឆ្នាំមុន) ដល់ ១៨.៧៨៩៣ពាន់លានរៀល។ រូបិយវត្ថុចរាចរ កើន ០,៧% ធៀបនឹងត្រីមាសមុន ឬកើន ១៣,៩% ធៀបនឹងមួយឆ្នាំមុន។

## ស្ថានភាពក្រីក្រ

ធៀបនឹងមួយឆ្នាំមុន ប្រាក់ចំណូលមធ្យមប្រចាំថ្ងៃពិតរបស់ពលករងាយរងគ្រោះទាំង ១០ក្រុម កើន ៤,៦% នៅខែកុម្ភៈ ១៧,៥% នៅខែឧសភា និង ១៨,៨% នៅសីហា។

នៅខែសីហា ប្រាក់ចំណូលប្រចាំថ្ងៃពិតរបស់អ្នកធាក់ស៊ីក្លូ កើន ១៥,៤% ធៀបនឹងខែដូចគ្នាឆ្នាំមុន គឺពី ៩៣៤៣រៀល ដល់ ១០.៧៨៣រៀល។ អ្នកធាក់ស៊ីក្លូ ៨០% ទទួលបានការអប់រំ ១ឆ្នាំ រីឯ ៧,៥% ទទួលបានការអប់រំ ២ឆ្នាំ និង ២,៥% ទទួលបានការអប់រំ ៣ឆ្នាំ ហើយ ១០% មិនដែលបានចូលរៀនសាលាទេ។ ជាមធ្យម ពួកគាត់មានសមាជិក ៤នាក់ក្នុងគ្រួសារ ហើយអ្នកឆ្លើយសម្ភាសន៍គ្រប់គ្នាជា អ្នករកចំណូលចម្បងក្នុងគ្រួសារ។ នៅខែសីហា អ្នកធាក់ស៊ីក្លូ ១៥% គិតថា ចំណូលរបស់គាត់កើនឡើងធៀបនឹងខែមុន រីឯ ៦៣% គិតថា វាធ្លាក់ចុះ និង ២៣% គិតថា នៅដដែល។ អ្នកដែលរកចំណូលបាន ២០.០០០រៀល/ថ្ងៃ កាលពីសប្តាហ៍មុន មាន ៣៨% និងមាន ៥% ដែលអាចរកបានដល់ ២៥.០០០រៀល/ថ្ងៃ។ អ្នកធាក់ស៊ីក្លូ ៥០% ធ្វើការ ៣០ថ្ងៃ/ខែ ហើយមាន ៤៥% ធ្វើការ ១០ម៉ោង/ថ្ងៃ និង ២២.៥% ធ្វើការ ១២ម៉ោង/ថ្ងៃ។

ប្រាក់ចំណូលប្រចាំថ្ងៃរបស់អ្នកលីសែង កើន ២៦% ធៀបនឹងខែដូចគ្នាក្នុងឆ្នាំ២០១១ ដល់ ១២.៥៨៨រៀល/ថ្ងៃ រីឯចំណាយជាមធ្យមលើអាហារ មានចំនួន ៨៦០០រៀល/ថ្ងៃ និងលើការស្នាក់នៅ ៩៧៥រៀល/ថ្ងៃ។ ចំណាយជាមធ្យមលើសុខភាព មានចំនួន ៤៥២៥រៀល/ខែ។ អ្នកលីសែង ៩៥% និយាយថា អាហារឡើងថ្លៃបានផលប៉ះពាល់ដោយផ្ទាល់ដល់ជីវភាព រីឯ ២,៥% ប្រាប់ថា ចំណាយលើឈ្នួលផ្ទះ និងការដឹកជញ្ជូនបានប៉ះពាល់ដោយផ្ទាល់ដល់ការរស់នៅ។

អ្នកលក់បន្លែតូចតាច អាចបង្កើនចំណូលប្រចាំថ្ងៃបាន ៣០% ធៀបនឹងខែដូចគ្នាឆ្នាំមុន។ អ្នកលក់បន្លែតូចតាច ៤០% គិតថា គាត់អាចរកចំណូលបានច្រើនជាងកាលពី ៤ឆ្នាំមុន, ១៧,៥% គិតថារកចំណូលបានតិចជាងកាលពីឆ្នាំ២០០៨, ១៥% គិតថាមានប្រាក់ចំណូលនៅដដែល និង ២៧% ប្រាប់ថា មិនដឹង។ មួយវិញទៀត មានអ្នកលក់បន្លែតូចតាចតែ ២,៥% ប៉ុណ្ណោះដែលរាយការណ៍ថា ប្រាក់ចំណូលរបស់គាត់អាចផ្គត់ផ្គង់គ្រួសារបាន និងមាន ៩៧% រាយការណ៍ថា គាត់ជាអ្នករកចំណូលចម្បងក្នុងគ្រួសារ។

នៅខែសីហា ប្រាក់ចំណូលរបស់អ្នករើសអេតចាយ កើន ២៧,៧% ធៀបនឹងខែដូចគ្នាឆ្នាំមុន ដោយមានប្រាក់ចំណូលប្រចាំថ្ងៃឡើងដល់ ៩២១៩រៀល រីឯចំណាយលើអាហារអស់ប្រហែល ៤៧០០រៀល/ថ្ងៃ។ ជាមធ្យម ពួកគាត់ធ្វើការប្រហែល ២៥ថ្ងៃ/ខែ និង ១១,៤ម៉ោង/ថ្ងៃ។ អ្នករើសអេតចាយ ៥០% គិតថា ប្រភពរបស់អេតចាយកើនឡើង, ៤០% គិតថា វាធ្លាក់ចុះ និង ១០% គិតថា នៅដដែល។ អ្នករើសអេតចាយ ៨៥% ជួលផ្ទះស្នាក់នៅ និង ១០% ស្នាក់នៅផ្ទះបងប្អូន រីឯ ៥% ស្នាក់នៅផ្ទះផ្ទាល់ខ្លួន។

ប្រាក់ចំណូលប្រចាំថ្ងៃរបស់អ្នកស៊ីឈ្នួលធ្វើស្រែកើន ២២% ធៀបនឹងខែដូចគ្នាឆ្នាំមុន ដល់ ៨៥៥៨រៀល។ នៅខែសីហា អ្នកស៊ីឈ្នួលធ្វើស្រែ ៦២% ជំពាក់បំណុលគេ។

ប្រាក់ចំណូលប្រចាំថ្ងៃរបស់កម្មករកាត់ដេរកើន ១៦,៧% ដល់ ៩៦៨៣រៀល។ ពួកគេចំណាយអស់ ៥៩០៩រៀល/ថ្ងៃ លើអាហារ និង ៣៦.៩៧១រៀល/ខែ លើឈ្នួលផ្ទះ។ ពួកគេគ្មានចំណាយលើការធ្វើដំណើរទេ ប៉ុន្តែ ត្រូវចំណាយលើការថែទាំសុខភាពអស់ប្រហែល ១២.៩៤១រៀល/ខែ និងអាចសន្សំបាន ១៨៤.៣៦៨រៀល/ខែ។ កម្មករកាត់ដេរ ៥៣% ធ្វើការម៉ោងបន្ថែមញឹកញាប់ រីឯ ៣២% ធ្វើការម៉ោងបន្ថែមម្តងម្កាល និង ១៥% មិនដែលធ្វើការម៉ោងបន្ថែមទេ។ កម្មករកាត់ដេរ ៤០% ជាសមាជិកសហជីពក្នុងរោងចក្រ និង ៦០% ទៀតមិនសូវដឹងពីសកម្មភាពសហជីពទេ។

នៅខែសីហា ប្រាក់ចំណូលប្រចាំថ្ងៃរបស់អ្នករត់ម៉ូតូឌុប កើន ២១,៤% ធៀបនឹងខែដូចគ្នាឆ្នាំមុន។ ពួកគាត់ធ្វើការជាមធ្យម ២៥,៤ថ្ងៃ/ខែ។ ប្រាក់ចំណូលជាមធ្យមរបស់ពួកគាត់មានចំនួន ១២.៩១៩រៀល/ថ្ងៃ រីឯចំណាយលើអាហារអស់ដល់ ៨៤១២រៀល/ថ្ងៃ។ អង្កេតបង្ហាញថា ពួកគាត់ធ្វើការច្រើនជាង ១០ម៉ោង/ថ្ងៃ។ អ្នករត់ម៉ូតូឌុបគ្រប់គ្នាសុទ្ធតែធ្វើចំណាកស្រុកមកភ្នំពេញ ក្នុងនេះ ៥៨% ធ្វើចំណាកស្រុកមកតែម្នាក់ឯង និង ៤២% ធ្វើចំណាកស្រុកជាមួយក្រុមគ្រួសារ មករស់នៅក្រុងភ្នំពេញ ឬសៀមរាប។

ប្រាក់ចំណូលប្រចាំថ្ងៃរបស់កម្មករសំណង់មានជំនាញ កើន ១៤% ធៀបនឹងខែដូចគ្នាឆ្នាំមុន ពី ១២.៤០៥រៀល ដល់ ១៤.១៥២រៀល។ ក្នុងចំណោមពួកគាត់ មានតែ ៥% ប៉ុណ្ណោះដែលនិយាយថា គាត់អាចផ្គត់ផ្គង់គ្រួសារដែលមានសមាជិកជាមធ្យម ៤នាក់បាន។ ពួកគាត់ធ្វើការ ២៦,៥ថ្ងៃ/ខែ និងមានតែ ៧,៥% ប៉ុណ្ណោះ ដែលធ្លាប់បានឮពីសមាគមកម្មករសំណង់ ប៉ុន្តែគ្មាននរណាម្នាក់បានចូលរួមក្នុងសមាគមនោះទេ។ ពួកគាត់ទាំងអស់អះអាងថា សកម្មភាពសំណង់បានកើនឡើងក្នុងបីខែចុងក្រោយនេះ។

## តារាង១. គម្រោងវិនិយោគឯកជនបានអនុម័ត ឆ្នាំ២០០៥-១២*

| | 2005 | 2006 | 2007 | 2008 | 2009 | 2010 Q4 | 2011 Q1 | Q2 | Q3 | Q4 | 2012 Q1 | Q2 |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | | ទ្រព្យសកម្មជាប់លាប់ (លានដុល្លារ) | | | | | | |
| កសិកម្ម | 26.8 | 498.0 | 135.6 | 92.0 | 615.0 | 36.7 | 4.1 | 156.4 | 123.9 | 440.6 | 154.7 | 81.2 |
| ឧស្សាហកម្ម | 914.6 | 365.3 | 709.1 | 724.9 | 818.5 | 87.7 | 67.1 | 257.1 | 2361.0 | 174.9 | 208.7 | 173.7 |
| *កាត់ដេរ* | *174.4* | *89.4* | *170.7* | *142.8* | *90.1* | *50.0* | *57.1* | *108.4* | *109.7* | *118.7* | *139.4* | *97.5* |
| សេវាកម្ម | 155.5 | 2939.1 | 1742.5 | 10,003.2 | 4432.0 | 1096.2 | 209.5 | 2229.2 | 264.1 | 722.6 | 50.9 | 18.0 |
| *សណ្ឋាគារ និងទេសចរណ៍* | *102.6* | *345.0* | *1048.3* | *8758.1* | *3980.1* | *1087.4* | *107.9* | *2221.9* | *264.1* | *257.0* | *50.9* | *0.0* |
| សរុប | 1096.9 | 3802.4 | 2587.2 | 10,570.9 | 5865.5 | 1220.6 | 280.72 | 2642.7 | 2748.9 | 1338.1 | 414.4 | 273.0 |
| | | | | | | បម្រែបម្រួលជាភាគរយធៀបនឹងត្រីមាសមុន | | | | | | |
| សរុប | - | - | - | - | - | 278.8 | -77.0 | 841.4 | 4.0 | -51.3 | -69.0 | -34.1 |
| | | | | | | បម្រែបម្រួលជាភាគរយធៀបនឹងឆ្នាំមុន | | | | | | |
| សរុប | 275.6 | 246.6 | -32.0 | 308.6 | -44.5 | -71.3 | -44.2 | 1115.0 | 752.9 | 9.6 | 47.6 | -89.7 |

*Including expansion project approvals. Source: Cambodian Investment Board*

## តារាង២. តម្លៃគម្រោងសំណង់នៅភ្នំពេញបានអនុម័ត ឆ្នាំ២០០៥-១២

| | 2005 | 2006 | 2007 | 2008 | 2009 | 2010 Q4 | 2011 Q1 | Q2 | Q3 | Q4 | 2012 Q1 | Q2 |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | | លានដុល្លារ | | | | | | |
| ភូមិគ្រឹះ និងផ្ទះ | 45.5 | 33.1 | 79.1 | 154.7 | 87.1 | 9.5 | 4.1 | 5.9 | 106.3 | 60.9 | 64.8 | 66.6 |
| ផ្ទះល្វែង | 204.2 | 213.3 | 297.2 | 221.6 | 73.3 | 20.3 | 16.1 | 22.8 | 90.0 | 58.5 | 60.8 | 219.3 |
| ផ្សេងៗ | 109.1 | 76.8 | 259.6 | 740.9 | 268.8 | 76.2 | 23.6 | 48.7 | 51.1 | 29.3 | 197.2 | 47.8 |
| សរុប | 358.8 | 323.3 | 635.8 | 1117.0 | 196.8 | 106.0 | 43.8 | 77.4 | 247.4 | 148.7 | 322.8 | 333.6 |
| | | | | | | បម្រែបម្រួលជាភាគរយធៀបនឹងត្រីមាសមុន | | | | | | |
| សរុប | - | - | - | - | - | 35.3 | -58.7 | 76.7 | 219.7 | -39.9 | 117.1 | 3.3 |
| | | | | | | បម្រែបម្រួលជាភាគរយធៀបនឹងឆ្នាំមុន | | | | | | |
| សរុប | 36.2 | -9.9 | 96.7 | 75.7 | -82.4 | 58.7 | -14.8 | -61.7 | 215.6 | 40.29 | 637.1 | 331.1 |

*Source: Department of Cadastre and Geography of Phnom Penh municipality*

## តារាង៣. ចំនួនអ្នកដំណើរមកដល់ប្រទេសកម្ពុជា ឆ្នាំ២០០៥-១២

| | 2005 | 2006 | 2007 | 2008 | 2009 | 2010 Q4 | 2011 Q1 | Q2 | Q3 | Q4 | 2012 Q1 | Q2 |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | | ចំនួនអ្នកដំណើរ (ពាន់នាក់) | | | | | | |
| តាមផ្លូវអាកាស | 856.5 | 1029.0 | 1296.5 | 1239.4 | 1111.7 | 383.7 | 427.4 | 286.9 | 335.3 | 430.7 | 513.6 | 317.1 |
| តាមផ្លូវគោក និងទឹក | 565.1 | 672.9 | 718.6 | 881.9 | 999.7 | 321.4 | 351.0 | 319.6 | 364.5 | 366.3 | 481.5 | 424.3 |
| សរុប | 1421.6 | 1701.9 | 2015.1 | 2121.3 | 2111.5 | 705.1 | 778.4 | 606.5 | 699.8 | 797.1 | 995.2 | 761.4 |
| | | | | | | បម្រែបម្រួលជាភាគរយធៀបនឹងត្រីមាសមុន | | | | | | |
| សរុប | - | - | - | - | - | 21.2 | 10.4 | -22.1 | 15.4 | 13.9 | 24.9 | -23.5 |
| | | | | | | បម្រែបម្រួលជាភាគរយធៀបនឹងឆ្នាំមុន | | | | | | |
| សរុប | 34.7 | 19.7 | 28.4 | 5.3 | 0.5 | 15.8 | 19.4 | 20.0 | 13.9 | 12.8 | 20.2 | 13.0 |

*Source: Ministry of Tourism*

## តារាង៤. ការនាំចេញ និងនាំចូល ឆ្នាំ២០០៥-១២

| | 2005 | 2006 | 2007 | 2008 | 2009 | 2010 Q4 | 2011 Q1 | Q2 | Q3 | Q4 | 2012 Q1 | Q2 |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | | លានដុល្លារ | | | | | | |
| ការនាំចេញសរុប | 2352.8 | 2810.9 | 3050.3 | 3097.8 | 2901.6 | 1070.3 | 1017.7 | 1132 | 1455.6 | 1324.2 | 1280.1 | 1243.2 |
| ក្នុងនេះ៖ សម្លៀកបំពាក់ | 2253.3 | 2698.8 | 2938.9 | 2986.2 | 2565.3 | 942.74 | 880.48 | 964.15 | 1285.71 | 1129.23 | 1070.8 | 1030.4 |
| *- សហរដ្ឋអាមេរិក* | 1546.1 | 1847.2 | 1956.5 | 1908.3 | 1512.6 | 524.75 | 464.47 | 466.71 | 619.38 | 504.71 | 493.3 | 441.76 |
| *- សហភាពអឺរ៉ុប* | 503.1 | 601.0 | 654.3 | 689.0 | 644.7 | 248.03 | 232.02 | 301.37 | 397.53 | 391.28 | 328.4 | 350.8 |
| *- អាស៊ាន* | 2.28 | 2.6 | 3.2 | 10.76 | 6.9 | 2.99 | 3.77 | 4.18 | 4.73 | 4.95 | 6.4 | 7.69 |
| *- ជប៉ុន* | 23.5 | 29.4 | 28.5 | 25.2 | 44.5 | 26.25 | 34.32 | 28 | 43.4 | 41.25 | 50.1 | 35.31 |
| *- ប្រទេសផ្សេងៗ* | 178.3 | 218.7 | 296.4 | 352.9 | 356.5 | 140.72 | 145.9 | 163.89 | 220.68 | 187.03 | 192.5 | 194.84 |
| កសិកម្ម | 61.25 | 59.7 | 55.7 | 44.5 | 73.1 | 71.67 | 74.01 | 97.07 | 98.91 | 92.06 | 80.5 | 71.41 |
| *- កៅស៊ូ* | 36.8 | 41.5 | 41.0 | 35.8 | 51.6 | 38.08 | 49.86 | 48.6 | 56.11 | 43.06 | 40.3 | 34.26 |
| *- ឈើ* | 10.3 | 8.6 | 8.7 | 3.4 | 3.5 | 18.1 | 6.2 | 16.8 | 16.1 | 9.7 | 8.9 | 6.7 |
| *- ត្រី* | 10.05 | 6.0 | 3.2 | 2.3 | 3.9 | 0.8 | 0.6 | 0.4 | 1.4 | 0.7 | 0.5 | 0.4 |
| *- ស្រូវ* | 2.8 | 2.5 | 1.5 | 2.6 | 10.9 | 12.1 | 16.9 | 30.3 | 22.4 | 37.027.1 | | 27.0 |
| ផលិតផលកសិកម្មផ្សេងៗ | 1.7 | 1.2 | 1.2 | 0.5 | 3.0 | 2.6 | 0.5 | 1.0 | 2.9 | 1.6 | 3.9 | 3.0 |
| ផ្សេងៗ | 38.29 | 52.33 | 55.8 | 67.1 | 263.22 | 55.9 | 63.2 | 70.8 | 71.0 | 102.9 | 128.8 | 141.4 |
| ការនាំចូលសរុប | 2509.0 | 3047.9 | 3770.2 | 4272.5 | 4331.5 | 1336 | 1454.9 | 1690.1 | 1519.1 | 1711.9 | 1609.2 | 1885.4 |
| ក្នុងនេះ៖ សាំង | 40.1 | 49.4 | 73.6 | 84.8 | 91.13 | 30.5 | 62.2 | 76.7 | 73.8 | 81.8 | 70.7 | 76.7 |
| ម៉ាស៊ូត | 92.94 | 121.6 | 133.7 | 119.5 | 180.67 | 50.4 | 92.7 | 129.9 | 118.9 | 105.5 | 139.4 | 126.6 |
| សម្ភារៈសំណង់ | 46.6 | 33.8 | 44.31 | 56.3 | 49.74 | 13.9 | 11.8 | 12.7 | 11.6 | 12.0 | 13.5 | 14.1 |
| ផ្សេងៗ | 2329.5 | 2843.1 | 3518.5 | 4011.8 | 4010 | 1241 | 1288 | 1471 | 1315 | 1513 | 1386 | 1668.0 |
| ជញ្ជីងពាណិជ្ជកម្ម | -156.2 | -237.0 | -719.9 | -1174.7 | -1429.9 | -265.7 | -437.2 | -558.1 | -63.5 | -387.6 | -329.1 | -642.2 |
| | | | | | | បម្រែបម្រួលជាភាគរយធៀបនឹងត្រីមាសមុន | | | | | | |
| ការនាំចេញសម្លៀកបំពាក់សរុប | - | - | - | - | - | 0.5 | -6.6 | 9.5 | 33.4 | -12.2 | -5.2 | -3.8 |
| ការនាំចេញសរុប | - | - | - | - | - | 2.4 | -4.9 | 11.2 | 28.6 | -9.0 | -3.3 | -2.9 |
| ការនាំចូលសរុប | - | - | - | - | - | -9.2 | 8.9 | 16.2 | -10.1 | 12.7 | -6.0 | 17.2 |
| | | | | | | បម្រែបម្រួលជាភាគរយធៀបនឹងឆ្នាំមុន | | | | | | |
| ការនាំចេញសម្លៀកបំពាក់សរុប | 11.2 | 19.8 | 8.9 | 1.6 | -14.1 | 42.7 | 40.8 | 34.5 | 37.0 | 19.8 | 21.6 | -6.9 |
| ការនាំចេញសរុប | 11.6 | 19.5 | 8.5 | 1.6 | -6.3 | 45.3 | 46.7 | 37.9 | 39.3 | 23.7 | 25.8 | -9.8 |
| ការនាំចូលសរុប | 17.1 | 21.5 | 23.7 | 13.3 | 1.4 | 21.2 | 30.1 | 33.7 | 3.2 | 28.1 | 10.6 | 11.6 |

*Import data include tax-exempt imports. Sources: Department of Trade Preferences Systems, MOC and Customs and Excise Department, MEF (web site)*

## តារាង៥. ប្រតិបត្តិការថវិកាជាតិលើមូលដ្ឋានសាច់ប្រាក់ ឆ្នាំ២០០៥-១២ (ពាន់លានរៀល)

| | 2005 | 2006 | 2007 | 2008 | 2009 | 2010 Q3 | Q4 | 2011 Q1 | Q2 | Q3 | Q4 | 2012 Q1 |
|---|---|---|---|---|---|---|---|---|---|---|---|---|
| ចំណូលសរុប | 2625.0 | 3259.2 | 1146.1 | 5290.0 | 5988.993 | 1436.04 | 1346.07 | 1400.46 | 1564.25 | 1510.1 | 1776.61 | 1728.9 |
| ចំណូលចរន្ត | 2474.0 | 2881.8 | 1141.6 | 5210.7 | 5859.075 | 1431.2 | 1337.65 | 1378.61 | 1563.01 | 1497.59 | 1740.12 | 1725.8 |
| ចំណូលពន្ធ | 1911.0 | 2270.9 | 965.2 | 4409.9 | 4692.958 | 1225.46 | 1224.09 | 1142.29 | 1367.52 | 1313.35 | 1454.33 | 1403.82 |
| ពន្ធក្នុងស្រុក | - | - | 661.8 | 3248.4 | 3533.567 | 916.886 | 808.541 | 875.569 | 1095.26 | 996.642 | 1104.12 | 1092.27 |
| ពន្ធលើពាណិជ្ជកម្មក្រៅប្រទេស | - | - | 303.5 | 1161.5 | 1159.394 | 308.577 | 303.389 | 266.719 | 272.27 | 316.709 | 350.207 | 311.253 |
| ចំណូលមិនមែនពន្ធ | 563.0 | 610.9 | 176.4 | 800.8 | 1166.13 | 205.74 | 225.72 | 236.329 | 195.48 | 184.23 | 285.8 | 330.98 |
| ចំណូលលើទ្រព្យសម្បត្តិ | - | - | 13.6 | 78.0 | 291.13 | 19.52 | 14.3 | 10.6426 | 18.64 | 15.19 | 19.35 | 91.28 |
| លក់ទំនិញ និងសេវា | - | - | 124.3 | 424.7 | 460.072 | 127.02 | 121.881 | 129.982 | 138.92 | 144.192 | 175.627 | 166.899 |
| ចំណូលមិនមែនពន្ធផ្សេងទៀត | - | - | 38.5 | 298.2 | 408.906 | 59.193 | 89.53 | 95.7053 | 37.9 | 24.856 | 90.815 | 63.8 |
| ចំណូលជាមូលធន | 152.0 | 377.4 | 4.5 | 79.3 | 129.918 | 4.842 | 8.425 | 21.8524 | 1.25 | 12.513 | 36.486 | 3.148 |
| ចំណាយសរុប | 3295.0 | 4174.7 | 1689.7 | 6297.8 | 8784.648 | 2390.26 | 1877.09 | 1581.62 | 2025.15 | 2310.61 | 3115.05 | 1688.33 |
| ចំណាយជាមូលធន | 1328.0 | 1638.1 | 807.4 | 2574.4 | 2853.233 | 886.954 | 634.92 | 579.818 | 721.01 | 801.167 | 1444.89 | 699.937 |
| ចំណាយចរន្ត | 1967.0 | 2536.8 | 882.3 | 3809.0 | 4773.067 | 1503.3 | 1332.34 | 857.492 | 1304.13 | 1509.44 | 1670.15 | 988.398 |
| បៀវត្សរ៍ | 711.0 | 822.0 | 362.6 | 1397.0 | 2048.81 | 562.4 | 642.5 | 401.0 | 531.6 | 629.697 | 608.253 | 508.919 |
| ឧបត្ថម្ភធន និងជំនួយសង្គមកិច្ច | - | - | 194.2 | 927.1 | 1099.419 | 401.513 | 195.578 | 257.356 | 450.85 | 323.282 | 487.345 | 189.594 |
| ចំណាយចរន្តផ្សេងទៀត | - | - | 325.5 | 1384.9 | 1624.838 | 539.4 | 494.3 | 199.1 | 321.7 | 556.5 | 574.6 | 289.9 |
| សមតុល្យជាទូទៅ | -670 | -915.5 | -543.6 | -1007.8 | -2795.66 | -954.2 | -531.0 | -181.2 | -460.9 | -800.5 | -1,338.4 | 40.6 |
| ហិរញ្ញប្បទានពីក្រៅប្រទេស | -396.0 | -445.1 | -185.8 | -127 | 1845.207 | 409.1 | 406.4 | 544.4 | 576.9 | 272.9 | 985.0 | 577.8 |
| ហិរញ្ញប្បទានក្នុងស្រុក | - | - | - | - | 938.644 | 343.3 | 254.0 | -1,745.2 | 238.7 | 312.5 | 105.6 | -565.7 |

*Source: MEF website.*

## តារាង៦. សន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់ អត្រាប្ដូរប្រាក់ និងថ្លៃមាស (មធ្យមភាគតាមការិយបរិច្ឆេទ) ២០០៥-១២

| | 2005 | 2006 | 2007 | 2008 | 2009 | 2010 Q4 | 2011 Q1 | Q2 | Q3 | Q4 | 2012 Q1 | Q2 |
|---|---|---|---|---|---|---|---|---|---|---|---|---|
| (តុលា-ធ្នូ ២០០៦:១០០) | សន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់ (បម្រែបម្រួលជាភាគរយធៀបនឹងឆ្នាំមុន) | | | | | | | | | | | |
| ភ្នំពេញ - ទំនិញគ្រប់មុខ | 5.8 | 4.7 | 5.8 | 19.7 | -0.7 | 3.3 | 3.6 | 6.3 | 6.7 | 4.9 | 2.9 | 2.9 |
| - ស្បៀងអាហារ និងភេសជ្ជៈគ្មានជាតិស្រា | 8.6 | 6.4 | 9.9 | | 33.1<br>-0.3 | 4.1 | 3.9 | 7.6 | 8.2 | 6.2 | 3.4 | 3.4 |
| - ដឹកជញ្ជូន | 11.4 | 9.1 | 5.8 | 19.4 | -10.7 | 3.1 | 5.0 | 7.3 | 8.8 | 6.3 | 3.0 | 5.3 |
| | អត្រាប្ដូរប្រាក់ ថ្លៃមាស ថ្លៃប្រេងឥន្ធនៈ (តាមអត្រាទីផ្សារនៅភ្នំពេញ) | | | | | | | | | | | |
| រៀលក្នុង ១ ដុល្លារ | 4119.7 | 4119.0 | 4062.7 | 4058.2 | 4140.5 | 4122.6 | 4041.9 | 4044.9 | 4095.7 | 4071.9 | 4046.0 | 4054.3 |
| រៀលក្នុង ១ បាតថៃ | 102.6 | 108.7 | 122.8 | 123.5 | 121.1 | 137.3 | 132.7 | 133.8 | 135.2 | 131.1 | 130.2 | 129.0 |
| រៀលក្នុង ១០០ ដុងវៀតណាម | 25.8 | 25.1 | 25.0 | 24.8 | 23.4 | 21.1 | 19.9 | 19.6 | 19.8 | 19.4 | 19.3 | 19.4 |
| ថ្លៃមាស (ដុល្លារក្នុង១ជី) | 54.0 | 70.6 | 83.2 | 105.9 | 113.1 | 165.7 | 147.9 | 181.5 | 204.6 | 203.8 | 204.1 | 194.4 |
| ថ្លៃម៉ាស៊ូត (រៀល/លីត្រ) | 2633.0 | 3140.0 | 3262.3 | 4555.2 | 3170.9 | 4066.1 | 4427.2 | 4784.6 | 4924.5 | 4908.3 | 5193.9 | 4458.3 |
| ថ្លៃសាំង (រៀល/លីត្រ) | 3442.0 | 4004.0 | 4005.0 | 4750.8 | 3593.1 | 4535.2 | 4750.1 | 5065.5 | 5248.4 | 5113.8 | 5395.8 | 5308.3 |

*Sources: NIS, NBC and CDRI*

## តារាង៧. ស្ថានភាពរូបិយវត្ថុ ឆ្នាំ២០០៥-១២ (តួលេខនៅចុងការិយបរិច្ឆេទ)

| | 2005 | 2006 | 2007 | 2008 | 2009 | 2010 Q3 | Q4 | 2011 Q1 | Q2 | Q3 | Q4 | 2012 Q1 |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | ពាន់លានរៀល | | | | | | | | | | | |
| ទ្រព្យសកម្មបរទេសសុទ្ធ | 5475.0 | 7224.0 | 10,735.0 | 10,345.0 | 14,655.0 | 16,903.0 | 16,697.9 | 17,079.1 | 18,099.9 | 17,695.2 | 17,893.9 | 18,652.3 |
| ទ្រព្យសកម្មក្នុងស្រុកសុទ្ធ | -450.0 | -282.0 | 576.0 | 1513.3 | 1573.0 | 1984.8 | 2778.9 | 3199.2 | 3907.7 | 4961.6 | 5760.8 | 6211.2 |
| ឥណទេយ្យសុទ្ធលើរដ្ឋាភិបាល | -421.0 | -953.0 | -1816.0 | -2987.0 | -2252.0 | -2120.4 | -2126.6 | -2252.7 | -2184.2 | -1925.8 | -2123.1 | -2542.4 |
| ឥណទានដល់ផ្នែកឯកជន | 2394.0 | 3630.0 | 6386.0 | 9894.0 | 10,532.0 | 12,479.8 | 13,331.2 | 13,909.0 | 15,290.6 | 16,385.7 | 17,552.8 | 18,789.0 |
| រូបិយវត្ថុទូទៅ M2 | 5025.0 | 6942.0 | 11,311.0 | 11,858.0 | 16,228.0 | 18,887.8 | 19,476.8 | 20,278.3 | 22,007.6 | 22,656.8 | 23,654.7 | 24,863.5 |
| រូបិយវត្ថុ M1 | 1323.0 | 1658.0 | 2052.0 | 2399.0 | 3120.0 | 3061.7 | 3220.9 | 3497.2 | 3539.8 | 3681.3 | 3956.2 | 3984.6 |
| រូបិយវត្ថុផ្សេងៗ | 3702.0 | 5285.0 | 9259.0 | 9459.0 | 13,108.0 | 15,826.1 | 16,255.9 | 16,781.1 | 18,467.8 | 18,975.5 | 19,698.5 | 20,878.9 |
| | បម្រែបម្រួលជាភាគរយធៀបនឹងឆ្នាំមុន | | | | | | | | | | | |
| រូបិយវត្ថុទូទៅ M2 | 16.1 | 38.1 | 62.9 | 4.8 | 36.9 | 26.7 | 20.0 | 17.7 | 20.5 | 20.0 | 21.5 | 20.2 |
| រូបិយវត្ថុ M1 | 14.7 | 25.3 | 23.8 | 16.9 | 30.1 | 10.4 | 3.2 | 11.1 | 13.6 | 20.2 | 22.8 | 11.4 |
| រូបិយវត្ថុផ្សេងៗ | 16.6 | 42.8 | 75.2 | 2.2 | 38.6 | 30.4 | 24.0 | 19.1 | 21.9 | 19.9 | 21.2 | 22.0 |

*Source: National Bank of Cambodia*

## តារាង៨. ចំណូលប្រចាំថ្ងៃជាមធ្យមពិតរបស់ពលករងាយរងគ្រោះ (ថ្លៃថេរ ខែវិច្ឆិកា ២០០០)

| | ចំណូលប្រចាំថ្ងៃ (ជារៀល) | | | | | | | | | បម្រែបម្រួលជាភាគរយធៀបឆ្នាំមុន | | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | 2007 | 2008 | 2009 | 2010 | 2011 សីហា | វិច្ឆិកា | 2012 កុម្ភៈ | ឧសភា | សីហា | 2012 កុម្ភៈ | ឧសភា | សីហា |
| អ្នកធាក់ស៊ីក្លូ | 8075 | 12,628 | 8091 | 9055 | 9343 | 9296 | 9380 | 10,954 | 10,783 | -11.8 | 32.1 | 15.4 |
| អ្នកលីសែង | 8588 | 9005 | 9549 | 9964 | 9994 | 11,490 | 10,804 | 13,033 | 12,588 | -3.4 | 32.2 | 26 |
| អ្នកលក់បន្លែតូចតាច | 8220 | 9926 | 8273 | 8266 | 8027 | 7077 | 12,292 | 10,150 | 10,438 | 34.3 | 18 | 30 |
| អ្នករើសអេតចាយ | 5422 | 4652 | 5857 | 6698 | 7217 | 10,289 | 7986 | 8473 | 9219 | 15.2 | -2.2 | 27.7 |
| អ្នកបម្រើតុភោជនីយដ្ឋាន* | 4482 | 4327 | 4646 | 5607 | 5166 | 6236 | 6179 | 6418 | 5617 | 0.4 | 5.8 | 8.7 |
| អ្នកស៊ីឈ្នួលធ្វើស្រែ | 5516 | 8697 | 6197 | 5691 | 7015 | 4552 | 4690 | 6592 | 8558 | -2.4 | 10.2 | 22 |
| កម្មកររោងចក្រកាត់ដេរ | 7568 | 6554 | 7085 | 7746 | 8687 | 8572 | 8555 | 8602 | 9683 | 2.9 | 8.2 | 16.7 |
| អ្នករត់ម៉ូតូឌុប | 10,634 | 15,691 | 10,685 | 10,623 | 11,645 | 12,899 | 12,256 | 13,958 | 12,919 | 7.1 | 31.3 | 21.4 |
| កម្មករសំណង់គ្មានជំនាញ | 6155 | 8779 | 8343 | 8790 | 10,052 | 9859 | 10,658 | 11,880 | 10,783 | -5.6 | 26.2 | 7.3 |
| កម្មករសំណង់មានជំនាញ | 11,154 | 12,710 | 12,487 | 11,952 | 12,405 | 14,930 | 13,824 | 13,169 | 14,152 | 10.7 | 6.5 | 14.1 |

** Waitresses' earnings do not include meals and accommodation provided by shop owners. Surveys on the revenue of waitresses, rice-field workers, garment workers, motorcycle taxi drivers, unskilled construction workers and skilled construction workers began in February 2000.*
*Source: CDRI*

*តពីទំព័រ ៥* **បញ្ហាប្រឈម...**

UK; New York: Cambridge University Press)

MAFF (2009), *Cambodia's National Forest Programme: Framework Document, 4th Draft* (Phnom Penh: MAFF)

MAFF (2012), *Draft of National Action Program to Combat Land Degradation in the Kingdom of Cambodia 2011-2020* (Phnom Penh: MAFF)

MoE (2002), *Cambodia's Initial National Communication* (Phnom Penh: MoE)

MoE & UNDP (2011), *Building Resilience: The Future for Rural Livelihoods in the Face of Climate Change, Cambodia Human Development Report 2011* (Phnom Penh: MoE & UNDP)

MoP (2010), *Achieving Cambodia's Millennium Development Goals* (Phnom Penh: MoP)

MOWRAM (2011), *Draft Sub Decree on River Basin Management* (Phnom Penh: MOWRAM)

MRC (2009), *Adaptation to Climate Change in the countries of the Lower Mekong Basin,* MRC Technical Paper No 24,http://www.mrcmekong.org/assets/Publications/report-management-develop/MRC-IM-No1-Adaptation-to-climate-change-in-LMB.pdf (accessed 12 July 2012) (MRC: Ventiane)

MRC (2010), *Technical Note 10. Assessment of Basin-wide Development Scenarios: Impacts on the Tonle Sap Ecosystem* : MRC

Nang P. & Yem D. (2010), *Sustainable Pathways for Attaining the Millennium Development Goals: Cambodia Case Study.* ACDRI Special Report (Phnom Penh: CDRI)

RGC (2010a), *Achieving Cambodia's Millennium Development Goals. Updated 2010* (Phnom Penh: MoP)

RGC (2010), *Cambodia Post-Ketsana Disaster Needs Assessment. Part I: Main Report,*http://www.gfdrr.org/gfdrr/sites/gfdrr.org/files/GFDRR_Cambodia_PDNA_2010_EN.pdf (accessed 9 August 2012) (Phnom Penh: CNCDM)

RGC (2012), *Flood 2011 Report* (Phnom Penh: CNCDM)

Ros B., Nang P. & Chhim C. (2011), *Agricultural Development and Climate Change: The Case of Cambodia,*Working Paper Series No. 65 (Phnom Penh: CDRI)

Saad-Filho, Alfredo (2010), *Growth, Poverty and Inequality: From Washington Consensus to Inclusive Growth,* DESA Working Paper No. 100 (New York:UN-Department of Economic and Social Affairs),http://www.un.org/esa/desa/papers/2010/wp100_2010.pdf (accessed 10 June 2012)

So S., B.D. Ratner, K. Mam & S. Kim (2011), *Conflict and Collective Action in Tonle Sap Fisheries: Strategic Priorities to Improve Governance and Support Community Livelihoods,* Policy Brief (drafted) (Phnom Penh: CDRI)

UNEP (2012), "Environment and Development Challenges: The Impartive to Act", paper presented at the 12th UNEP Governing Council meeting, Nairobi, Kenya, 20 February 2012, http://www.nfp-facility.org/21398-0-0.pdf (accessed 2 August 2012)

UNESCAP (2008), *Monitoring and Reporting Progress on Community-Based Disaster Risk Management in Cambodia*(Bangkok: Asian Disaster Preparedness Center). http://www.adpc.net/v2007/programs/CBDRM/Publications/Downloads/Publications/Cambodia_Update.pdf (accessed 2 August 2012)

USAID (2005), *Livelihoods and Conflict: A Toolkit for Intervention* http://www.adpc.net/v2007/programs/CBDRM/INFORMATION%20RESOURCE%20CENTER/CBDRM%20Publications/2008/final_crcambodia_23nov.pdf (accessed 12 July 2012)

Vong, S. & Michael Dutschke (2009), Integrate Climate Change Issues into the National Forest Programme in Cambodia, background paper for National Workshop, Phnom Penh

Women's Environmental Network (2010), *Gender and the Climate Change Agenda: The impacts of Climate Change on Women and Public Policy* (London: WEN)

*តពីទំព័រ ១៤* **ឥណទានសម្រាប់ ...**

NIS (2008), National census map layers and database (Phnom Penh: NIS)

Ovesen, J., I.B. Trankell, Heng K. & Sochoeun C. (2012), *Rice Farming and Microcredit in Takeo* (Phnom Penh: Uppsala University and Intean Poalroath Rongroeurng Ltd)

Phlong P. (2009), "Informal Credit Systems in Cambodia", master's thesis, Nothern Illinois University, Illinois

UNCDF (2011), *Takeo Provincial Development Outlook* (Phnom Penh: UNCDF)

World Bank (2007), *Sharing Growth: Equity and Development in Cambodia* (Phnom Penh: World Bank for the Cambodia Development Cooperation and Forum)

*តពីទំព័រ ២៤* **ព័ត៌មានថ្មីៗ...**

## ការស្រាវជ្រាវ

**កម្មវិធីអភិបាលកិច្ចបែបប្រជាធិបតេយ្យ និងកំណែទម្រង់វិស័យសាធារណៈ** (DGPSR)

កម្មវិធីនេះ កំពុងអនុវត្តគម្រោងស្រាវជ្រាវប្រាំមួយ ដែលទទួលបានហិរញ្ញប្បទានចម្បងពី ទីភ្នាក់ងារសហប្រតិបត្តិការអភិវឌ្ឍន៍អន្តរជាតិស៊ុយអែត (Sida)។ កម្រងសំណួរពាក់កណ្ដាលរៀបរយសម្រាប់ការសិក្សាពី "ការផ្លាស់ប្ដូរសង្គមឆ្លងតាមការធ្វើកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ (D&D)៖ ផលប៉ះពាល់នៃទំនាក់ទំនងជាបដិការរវាងរដ្ឋ និងសង្គមនៅកម្ពុជា" បានកែសម្រួលរួចរាល់ និងបានយកទៅប្រើប្រាស់ក្នុងពេលចុះសិក្សានៅខេត្តបាត់ដំបង។ ឯកសារសម្រាប់គម្រោង "អភិបាលកិច្ចតំបន់ទីក្រុងនៅកម្ពុជាក្រោយធ្វើវិមជ្ឈការ" បានធ្វើរួចរាល់ ហើយក្រុមអ្នកស្រាវជ្រាវ បានចុះអនុវត្តការសិក្សាដល់ទីកន្លែងនៅក្នុងខេត្តកំពង់ចាម។ សម្ភាសន៍ជាដំបូងៗ បានធ្វើនៅត្រឹមកម្រិតជាតិ និងកម្រិតមូលដ្ឋាន សម្រាប់ការសិក្សាពី "អភិបាលកិច្ចទឹកសម្រាប់កសិកម្ម៖ វិមជ្ឈការ អភិបាលកិច្ចច្រើនកម្រិត និងសហគមន៍មូលដ្ឋាននៅអាងទន្លេសាប" ដែលបានទទួលមូលនិធិមួយភាគពីកម្មវិធីស្ដីពីបញ្ហាទឹក និងអាហារ (CPWF) នៃកម្មវិធីមេគង្គស្ដីពីទឹក បរិស្ថាន និងភាពធន់ទ្រាំ (M-POWER)។ សម្រាប់គម្រោង "វិមជ្ឈការបែបប្រជាធិបតេយ្យ និងយេនឌ័រ៖ ការវិភាគពីយេនឌ័រនៅក្នុងគណបក្សនយោបាយនៅកម្ពុជា" ក្រុមស្រាវជ្រាវបានបញ្ចប់ការចុះសិក្សាដល់កន្លែងក្នុងបួនខេត្ត និងកំពុងវិភាគទិន្នន័យ។

គម្រោងចំនួនពីរ កំពុងស្ថិតក្នុងដំណាក់កាលទើបចាប់ផ្ដើមអនុវត្ត។ គម្រោង "រឿងល្អទាំងអស់ មិនមែនសុទ្ធតែដើរស្របគ្នានោះទេ៖ ការវិភាគពីភាពប្រទាំងប្រទើសគ្នា រវាងការកសាងសន្តិភាព និងប្រជាធិបតេយ្យភាវូបនីយកម្ម" កំពុងដំណើរការទៅមុខ។ គម្រោងនេះ គ្រោងអនុវត្តក្រោមកិច្ចសហការជាដៃគូជាមួយសាកលវិទ្យាល័យ Gothenburg ដើម្បីកំណត់ពីបែបបទ និងមូលហេតុ ដែលទំនាស់នានាផុសឡើង (ក្នុងរយៈពេលខ្លី និងវែង) បន្ទាប់ពីមាន ឬក៏អាចកើតឡើងពី អន្តរាគមន៍ខាងការកសាងសន្តិភាព។ គម្រោង "សមត្ថភាពរដ្ឋដើម្បីជួយទ្រទ្រង់ដល់ការគ្រប់គ្រងកម្លាំងពលកម្មនៅកម្ពុជា" ដែលជាការសិក្សាតាមដានបន្តអំពីសមត្ថភាពរដ្ឋនោះ ត្រូវបានផ្ដួចផ្ដើមឡើង ហើយបច្ចុប្បន្នកំពុងស្ថិតក្នុងដំណាក់កាលរចនារៀបចំការសិក្សា។

**កម្មវិធីសេដ្ឋកិច្ច ពាណិជ្ជកម្ម និងសហប្រតិបត្តិការក្នុងតំបន់** (ETRC)

អង្កេតពលករងាយរងគ្រោះ និងអង្កេតថ្លៃទំនិញតាមខេត្ត ព្រមទាំងការចងក្រងរបាយការណ៍ថ្មីៗ ស្ដីពីសេដ្ឋកិច្ចកម្ពុជា កំពុងជឿនលឿនទៅមុខយ៉ាងល្អ។ គម្រោងកំពុងដំណើរការដទៃទៀតមានដូចតទៅ៖ (១) គម្រោង "វិបត្តិហិរញ្ញវត្ថុសាកល និងភាពងាយរងគ្រោះនៅកម្ពុជា" ដែលទទួលហិរញ្ញប្បទានពី IDRC (២) គម្រោងរយៈពេលប្រាំឆ្នាំស្ដីពី "កំណើនសម្រាប់គ្រប់គ្នា" ទទួលបានហិរញ្ញប្បទានពី Sida និងផ្ដោតលើកំណើនខ្ពស់មានចីរភាព (៣) គម្រោង "កំណើនសេដ្ឋកិច្ច វិសមភាព និងការកាត់បន្ថយភាពក្រីក្រ" (៤) គម្រោង "ការវាយតម្លៃពីភាពគាំទ្រដល់ជនក្រីក្រនៃគោលនយោបាយសារពើពន្ធ" (៥) គម្រោង "កំណើនសេដ្ឋកិច្ចពាណិជ្ជកម្ម និងការកាត់បន្ថយភាពក្រីក្រ និង (៦) គម្រោងស្ដីពី "មធ្យោបាយដើម្បីសម្រេចបានកំណើនសម្រាប់គ្រប់គ្នា"។

របាយការណ៍ព្រាងទី១ ស្ដីពី "ការវាយតម្លៃពីកំណើនសម្រាប់គ្រប់គ្នានៅកម្ពុជា៖ វិធីសាស្ត្រជួយទ្រទ្រង់ជនក្រីក្រតាមរយៈចំណូល និងកត្តាផ្សេងក្រៅពីចំណូល (បណ្ដាញវិភាគអភិវឌ្ឍន៍នៅមហាអនុតំបន់មេគង្គ៖ GMS-DAN 9)" ហើយលទ្ធផលរកឃើញសំខាន់ៗ នឹងយកទៅធ្វើបទបង្ហាញក្នុងសិក្ខាសាលា GMS-DAN នាថ្ងៃទី២៧ សីហា នៅទីក្រុងគុនមីញ ខេត្តយូណាន ប្រទេសចិន។ របាយការណ៍ព្រាងទី២ ស្ដីពី "តើមានឧបសគ្គអ្វីខ្លះចំពោះកំណើនសម្រាប់គ្រប់គ្នានៅកម្ពុជា?" និង "កញ្ចុំឧស្សាហកម្ម សមាគមអាជីវកម្ម និងផលិតភាពសហគ្រាសខ្នាតតូច និងមធ្យម (SME)៖ ភស្តុតាងបានពីអង្កេតសហគ្រាសនៅកម្ពុជា" បានផ្ញើទៅបណ្ដាញស្រាវជ្រាវអាស៊ីប៉ាស៊ីហ្វិក និងបណ្ដុះបណ្ដាលពីពាណិជ្ជកម្ម (ARTNeT) រួចរាល់ ដើម្បីសុំយោបល់បន្ថែម។

អត្ថបទបង្កើតគោលគំនិតស្ដីពី "កត្តាកំណត់ខាងសេដ្ឋកិច្ច និងប្រជាសាស្ត្រនៃចំណាកស្រុកកម្លាំងពលកម្មនៅកម្ពុជា" បានទទួលការយល់ព្រមពី បណ្ដាញស្រាវជ្រាវសេដ្ឋកិច្ចទន្លេមេគង្គ (MERN) ឲ្យបង្កើតជាសំណើស្រាវជ្រាវពេញលេញ ហើយក្រុមស្រាវជ្រាវបានបញ្ជូនសំណើនោះ កាលពីដើមខែកក្កដា និងកំពុងរង់ចាំចម្លើយតបពី MERN។

សៀវភៅ "ផលចំណេញ និងបន្ទុកចំណាយនៃចំណាកស្រុកកម្លាំងពលកម្មក្នុងមហាអនុតំបន់មេគង្គ" បានចេញផ្សាយហើយ។

**កម្មវិធីធនធានធម្មជាតិ និងបរិស្ថាន** (NRE)

របាយការណ៍គម្រោង "ការពិនិត្យតាមដានផលប៉ះពាល់សង្គម និងវាយតម្លៃភាពងាយរងគ្រោះ" ដែលទទួលបានការឧបត្ថម្ភគាំទ្រពីគណៈកម្មការទន្លេមេគង្គនោះ បានចងក្រងរួចរាល់ និងកំពុងរង់ចាំការត្រួតពិនិត្យផ្នែកបច្ចេកទេសជាលើកទី២ នៅពាក់កណ្ដាលខែកញ្ញា មុនពេលបោះពុម្ពផ្សាយ។

កម្មវិធី NRE កំពុងអនុវត្តគម្រោងស្រាវជ្រាវបួន។ ក្រុមស្រាវជ្រាវគម្រោង "ការពង្រឹងអភិបាលកិច្ចធនធានជលផល (STARGO)" បានដំណើរការវគ្គបណ្ដុះបណ្ដាលផ្អែកលើសហគមន៍មួយស្ដីពី ការដោះស្រាយទំនាស់ខាងនេសាទ និងបានតាក់តែងអត្ថបទករណីសិក្សាបែបបច្ចេកទេសមួយស្ដីពី បឹងទន្លេសាប ក្រោមចំណងជើងថា "ក្រោយកំណែទម្រង់៖ ការពង្រឹងអភិបាលកិច្ចធនធានជលផលនៅទន្លេសាប"។ ក្រុមស្រាវជ្រាវគម្រោង "យេនឌ័រ និងអភិបាលកិច្ចទឹក៖ ការគ្រប់គ្រង និងអភិវឌ្ឍន៍ប្រព័ន្ធធារាសាស្ត្រ ក្នុងបរិបទនៃការផ្លាស់ប្ដូរអាកាសធាតុ" ដែលទ្រទ្រង់ដោយ Sida បានចងក្រងរបាយការណ៍ពីការសិក្សាឯកសារយោង និងសរសេរអត្ថបទមួយសម្រាប់ចុះផ្សាយក្នុងទស្សនាវដ្ដីអភិវឌ្ឍន៍កម្ពុជា ហើយបច្ចុប្បន្នកំពុងចុះសិក្សាដល់កន្លែង នៅខេត្តកំពង់ធំ កំពង់ឆ្នាំង និងពោធិ៍សាត់។

ក្រុមស្រាវជ្រាវគម្រោងរួមគ្នាមួយជាមួយ សាកលវិទ្យាល័យភូមិន្ទភ្នំពេញ (RUPP) ស្ដីពី "បម្រែបម្រួលអាកាសធាតុ និង

ភាពធន់ទ្រាំ៖ ការប្រើប្រាស់ដី ការប្រែប្រួលរបបទឹកភ្លៀង និង អភិបាលកិច្ចទឹក ដែលជះឥទ្ធិពលលើសន្តិសុខស្បៀង និង ជីវភាពប្រជាជន" កំពុងបន្តជួយគាំទ្រដល់ការចងក្រងព័ត៌មាន ជលសាស្ត្រ តាមការប្រើប្រាស់ទិន្នន័យបានពី កម្មវិធីអភិវឌ្ឍន៍ សមត្ថភាពស្រាវជ្រាវ និងគ្រប់គ្រងធនធានទឹក (WRMRDP)។ សម្រាប់គម្រោងរួមគ្នាជាមួយ កម្មវិធីភាពក្រីក្រ កសិកម្ម និង អភិវឌ្ឍន៍ជនបទ (PARD) ដើម្បីធ្វើ "ការវាយតម្លៃផលប៉ះពាល់ នៃគម្រោងផ្តល់មូលនិធិដោយ មូលនិធិស្រាវជ្រាវកសិកម្មកម្ពុជា (CARF)" ក្រុមស្រាវជ្រាវនៃ NRE កំពុងចូលរួមវាយតម្លៃលើ គម្រោងប្រាំបួនផ្តល់មូលនិធិដោយ កម្មវិធីខ្សែសង្វាក់តម្លៃកសិកម្ម កម្ពុជា (CAVAC) ដើម្បីពិនិត្យពីកម្រិតទទួលយក និងជោគជ័យ នៃគម្រោងនានាដែលបានអនុវត្តតាំងពីឆ្នាំ២០០៥ មក។

ក្រុមស្រាវជ្រាវ NRE ក៏បានបញ្ជូនសំណើស្រាវជ្រាវចំនួន ប្រាំមួយ ទៅឲ្យដៃគូផ្តល់មូលនិធិនៅក្នុងប្រទេសកម្ពុជា និងនៅឯ បរទេសដែរ។

**កម្មវិធីភាពក្រីក្រ កសិកម្ម និងអភិវឌ្ឍន៍ជនបទ** (PARD)

កម្មវិធីនេះ កំពុងអនុវត្តគម្រោងស្រាវជ្រាវប្រាំពីរ។ របាយ ការណ៍សម្រាប់គម្រោងទទួលមូលនិធិពី ADB ស្តីពី "ការលើក កម្ពស់សមភាពយេនឌ័រនៅទីផ្សារពលកម្ម ដើម្បីជំរុញកំណើន សម្រាប់គ្រប់គ្នា" កំពុងរៀបចំបង្ហើយឲ្យរួចរាល់។ ការសិក្សាស្តីពី "ការរួមចំណែកនៃសេវាកម្មក្រុមប្រឹក្សាអាជ្ញាកណ្តាល ដើម្បីលើក កម្ពស់ទំនាក់ទំនងខាងឧស្សាហកម្មនៅកម្ពុជា៖ ករណីរោងចក្រ កាត់ដេរ" បានជួបបញ្ហាខ្លះៗ ដោយសាររោងចក្រកាត់ដេរ មិនបាន ផ្តល់ព័ត៌មានបែបបរិមាណដ៏ចាំបាច់សម្រាប់ការសិក្សា។ បច្ចុប្បន្ន មូលនិធិក្រុមប្រឹក្សាអាជ្ញាកណ្តាល (ACF) និង សមាគមរោងចក្រ កាត់ដេរកម្ពុជា (GMAC) កំពុងជួយវិទ្យាស្ថាន CDRI ឲ្យទទួល បានទិន្នន័យនេះពីសមាជិករបស់ GMAC។ លទ្ធផលជាដំបូងៗនៃ ការស្រាវជ្រាវក្នុងគម្រោង "ការកសាងគោលនយោបាយកសិកម្ម សម្រាប់ប្រព័ន្ធកសិកម្មផ្អែកលើដំណាំស្រូវនៅប្រទេសកម្ពុជា និង ឡាវ" ត្រូវបានយកទៅធ្វើបទបង្ហាញនៅក្នុងសិក្ខាសាលាថ្នាក់ តំបន់មួយដែលប្រព្រឹត្តទៅកាលពីថ្ងៃទី១៧-១៩ កក្កដា នៅខេត្ត ដាណាង ប្រទេសវៀតណាម ដើម្បីចែករំលែក និងបូកសរុបចូល គ្នានូវ លទ្ធផលស្រាវជ្រាវរបស់ក្រុមស្រាវជ្រាវមកពីប្រទេសទាំង បួនគឺ កម្ពុជា ឡាវ ថៃ និង វៀតណាម។ ការសិក្សាមួយក្រោម ជំនួយហិរញ្ញវត្ថុពី Sida អំពី "ផលប៉ះពាល់នៃការធ្វើកសិកម្ម តាមកិច្ចសន្យាទៅលើជីវភាពរស់នៅរបស់ម្ចាស់ដីតូចៗ" កំពុង ស្ថិតក្នុងដំណាក់កាលរចនារៀបចំការសិក្សា។ ក្រុមស្រាវជ្រាវ គម្រោង "ការវាយតម្លៃផលប៉ះពាល់នៃគម្រោងផ្តល់មូលនិធិដោយ CARF" កំពុងប្រមូលទិន្នន័យ។ សម្រាប់គម្រោង "ការសិក្សា តាមដាននៅពាក់កណ្តាលអាណត្តិ ពីតម្រូវការរបស់ក្រុមប្រឹក្សា អាជ្ញាកណ្តាលលើផ្នែកអភិបាលកិច្ចល្អ" ក្រុមស្រាវជ្រាវបាន បញ្ចប់ការប្រមូលទិន្នន័យ ហើយកំពុងវិភាគទិន្នន័យ និងសរសេរ របាយការណ៍។ សម្រាប់គម្រោងទើបចុះកិច្ចសន្យាថ្មីស្តីពី "ការ សិក្សាវាយតម្លៃមូលដ្ឋានលើ គម្រោងជួយដោះស្រាយភាពងាយ រងគ្រោះនៅតាមជនបទ និងស្ថិរភាពប្រព័ន្ធអេកូឡូស៊ី (កម្ពុជា ហារវែស៖ HARVEST) ផ្តល់ហិរញ្ញប្បទានដោយទីភ្នាក់ងារសហរដ្ឋ អាមេរិកសម្រាប់ការអភិវឌ្ឍអន្តរជាតិ (USAID)" ក្រុមស្រាវ ជ្រាវកំពុងបង្ហើយក្របខ័ណ្ឌជ្រើសយកសំណាក និងឧបករណ៍ សម្រាប់អង្កេត ហើយការសិក្សាដល់កន្លែង គ្រោងអនុវត្តពីពាក់ កណ្តាលខែសីហា ដល់ដើមខែតុលា ឆ្នាំ២០១២។

**កម្មវិធីអភិវឌ្ឍន៍សង្គម** (SD)

ក្រុមស្រាវជ្រាវប្រចាំកម្មវិធីនេះ កំពុងអនុវត្តគម្រោងស្រាវ ជ្រាវបួន។ គម្រោង "កសាងប្រព័ន្ធសុខាភិបាលអំណោយផលដល់ ជនក្រីក្រ ក្នុងពេលកសាងប្រទេសឡើងវិញបន្ទាប់ពីបានបញ្ចប់ ទំនាស់" បានបញ្ចប់ឆ្នាំដំបូងនៃការកសាងគោលគំនិត ហើយ ក្រុមស្រាវជ្រាវបានចាប់ផ្តើមអនុវត្តអនុគម្រោងបីគឺ៖ (១) "ផល ប៉ះពាល់នៃ គោលនយោបាយផ្តល់ហិរញ្ញប្បទានផ្នែកសុខាភិបាល ទៅលើចំណាយរបស់គ្រួសារក្រីក្រក្នុងការថែទាំសុខភាព" (២) "គោលនយោបាយទាក់ទាញ និងរក្សាបុគ្គលិកសុខាភិបាលឲ្យធ្វើ ការនៅតំបន់ជនបទ៖ ការពិនិត្យឡើងវិញពីកត្តាជំរុញផ្នែកគោល នយោបាយ ការអនុវត្ត និងប្រសិទ្ធភាពគោលនយោបាយក្រោយ ការបញ្ចប់ទំនាស់នៅកម្ពុជា" និង (៣) "ដំណើរការផ្លាស់ប្តូរនៃ របៀបរៀបចំកិច្ចសន្យានៅកម្ពុជា"។ ទិន្នន័យអង្កេតសេដ្ឋកិច្ច-សង្គមកិច្ចកម្ពុជា កំពុងតែយកមកពិនិត្យឡើងវិញ ដើម្បីកំណត់ ម៉ូដែលសម្រាប់អនុគម្រោងទី១។ សម្រាប់អនុគម្រោងទី២ ក្រុម ស្រាវជ្រាវបានបញ្ចប់ការវាយតម្លៃបឋមក្នុងប្រាំខេត្ត និងកំពុងកែ សម្រួលផែនការការងារ និងតារាងទិន្នន័យសម្រាប់ការប្រមូល ទិន្នន័យប្រភពទី២។ អនុគម្រោងទី៣ កំពុងរង់ចាំការអនុម័ត យល់ព្រមពីគណៈកម្មាធិការក្រមសីលធម៌ជាតិ។ ក្រុមស្រាវជ្រាវ អនុគម្រោងទាំងបី កំពុងពិនិត្យឡើងវិញលើការសិក្សាមានស្រាប់ និងប្រមូលទិន្នន័យប្រភពទី២។ ការប្រមូលទិន្នន័យប្រភពទី១ សម្រាប់គម្រោងទាំងបីនេះ គ្រោងធ្វើឡើងនៅដើមឆ្នាំ២០១៣។

គម្រោង "អភិបាលកិច្ចសម្រាប់ការអប់រំថ្នាក់ឧត្តមនៅកម្ពុជា" ដែលផ្តល់មូលនិធិដោយ Sida មានបំណងកំណត់ពីចន្លោះខ្វះ ខាតក្នុងគោលនយោបាយផ្នែកអប់រំ ពង្រឹងគុណភាពការអប់រំថ្នាក់ ឧត្តមសិក្សា និងកំណត់គំរូអភិបាលកិច្ចដែលអាចអនុវត្តបាន សម្រាប់ការផ្តល់សេវាអប់រំថ្នាក់ឧត្តមសិក្សានៅកម្ពុជា។ បច្ចុប្បន្ន ក្រុមស្រាវជ្រាវកំពុងចងក្រងរបាយការណ៍។ គម្រោង "ការផ្គត់ផ្គង់ និងតម្រូវការកម្លាំងពលកម្មនៅកម្ពុជា" ដែលទទួលមូលនិធិពី Sida ដែរនោះ កំពុងស្ថិតក្នុងដំណាក់កាលសិក្សាស្រាវជ្រាវលើ ឯកសារមានស្រាប់។ គម្រោងនេះ កំណត់ពីសន្ទុះ និងគម្លាត រវាងការអប់រំជាន់ខ្ពស់ និងទីផ្សារការងារ និងពិនិត្យពីតួនាទីនៃ ស្ថាប័នអប់រំជាន់ខ្ពស់ និងសហគ្រាសនានាដែលជាប់ទាក់ទង នឹងការផ្គត់ផ្គង់ និងតម្រូវការនៃទីផ្សារពលកម្មនៅកម្ពុជា។ គម្រោង "ការអង្កេតស្រាវជ្រាវពីហេតុការណ៍សំខាន់ៗ៖ ការចរចាលើបញ្ហា យេនឌ័រនៅកម្ពុជា" ដែលទទួលហិរញ្ញប្បទានពី GIZ កំពុងស្ថិត ក្នុងដំណាក់កាលវិភាគទិន្នន័យ និងគ្រោងបញ្ចប់ក្នុងខែកញ្ញា។ កម្មវិធី SD ក៏កំពុងធ្វើការរួមគ្នាជាមួយកម្មវិធី PARD ផងដែរលើ គម្រោងស្តីពី "ការវាយតម្លៃផលប៉ះពាល់នៃគម្រោងផ្តល់មូលនិធិ ដោយ CARF"។

# ព័ត៌មានថ្មីៗពីវិទ្យាស្ថាន CDRI

## ព្រឹត្តិការណ៍សំខាន់ៗ

វិទ្យាស្ថាន CDRI និងធនាគារ ANZ Royal នៅកម្ពុជា បានចុះហត្ថលេខាលើកិច្ចព្រមព្រៀងសហការជាដៃគូរយៈពេលបីឆ្នាំថ្មីមួយ ដើម្បីរួមដៃគ្នារៀបចំសន្និសីទចក្ខុវិស័យប្រទេសកម្ពុជាប្រចាំឆ្នាំ សម្រាប់ឆ្នាំ២០១៣-១៥។ សន្និសីទចក្ខុវិស័យឆ្នាំ២០១៣ គ្រោងធ្វើឡើងនៅខែកុម្ភៈ ២០១៣ ដោយផ្ដោតលើប្រធានបទចម្បងស្ដីពីការធានាអនាគតប្រទេសកម្ពុជា៖ សន្តិសុខស្បៀង ថាមពល និងធនធានធម្មជាតិ។

កាលពីថ្ងៃទី២១ សីហា ២០១២ វិទ្យាស្ថាន CDRI បានរៀបចំពិធីអបអរសាទរ និងបញ្ចប់ កម្មវិធីបណ្ដុះបណ្ដាល និងអប់រំ ពីការកសាងសន្តិភាព និងដោះស្រាយទំនាស់ បន្ទាប់ពីកម្មវិធីនេះបានដំណើរការជាងពីរទសវត្សរ៍។ ការពិនិត្យឡើងវិញពីដំណើរកកើតកម្មវិធីបណ្ដុះបណ្ដាលនេះ និងការបូកសរុបពីសមិទ្ធផលនានា ត្រូវបានធ្វើឡើងដោយលោកស្រី អេវ៉ា មីស្លីវិច ជាស្ថាបនិក និងអតីតនាយិកាប្រតិបត្តិនៃវិទ្យាស្ថាន CDRI, លោក ឱក សេរី សោភក្ដិ៍ ជាអតីតអ្នកសម្របសម្រួល មជ្ឈមណ្ឌលដើម្បីសន្តិភាព និងអភិវឌ្ឍន៍ នៃវិទ្យាស្ថាន CDRI និងជាអតីតអ្នកសម្របសម្រួលកម្មវិធីបង្ការទំនាស់ក្នុងការបោះឆ្នោតនៅកម្ពុជា (ខប់សែល/COPCEL), លោក សុត ផ្លាយង៉ាម ជាអតីតនាយកក្រុមការងារដើម្បីដោះស្រាយទំនាស់ (ACT) និង លោកស្រី ហ៊ុយ រំដួល ជាអតីតអ្នកបណ្ដុះបណ្ដាលជាន់ខ្ពស់ក្នុង កម្មវិធីបណ្ដុះបណ្ដាលពីការកសាងសន្តិភាព និងដោះស្រាយទំនាស់ នៃវិទ្យាស្ថាន CDRI។ លោកស្រី ហ៊ុយ រំដួល និង លោកស្រី ទូច វ៉ារីន ជាអតីតអ្នកបណ្ដុះបណ្ដាលក្នុង កម្មវិធីបណ្ដុះបណ្ដាលពីការកសាងសន្តិភាព និងដោះស្រាយទំនាស់ដែរ បានទទួល លិខិតសរសើរនិងថ្លែងអំណរគុណ ចំពោះការប្ដេជ្ញាចិត្តយូរអង្វែងក្នុងការងារកសាងសន្តិភាពនៅកម្ពុជា។ ទោះកម្មវិធីបានចប់ហើយក្ដី ក៏វិទ្យាស្ថាន CDRI នឹងបន្តធ្វើការស្រាវជ្រាវខាងគោលនយោបាយពាក់ព័ន្ធនឹងការកសាងសន្តិភាពនិងការគ្រប់គ្រងដោះស្រាយទំនាស់នៅកម្ពុជាជាពិសេសទំនាស់ទាក់ទងនឹងលទ្ធភាពប្រើប្រាស់ធនធានធម្មជាតិ មាន ដី ទឹក ព្រៃឈើ និងជលផល ជាដើម។

កិច្ចប្រជុំពាក់កណ្ដាលឆ្នាំនៃ ក្រុមប្រឹក្សាភិបាលវិទ្យាស្ថាន CDRI បានធ្វើឡើងនៅថ្ងៃទី៣០ សីហា ២០១២។ ក្រុមប្រឹក្សាភិបាល បានពិនិត្យពិចារណាលើឯកសារព្រាងនៃ យុទ្ធសាស្ត្រកៀងគរធនធាន ដែលជាការប្ដេជ្ញាចិត្តដ៏សំខាន់មួយនៅក្នុងផែនការយុទ្ធសាស្ត្រឆ្នាំ២០១១-២០១៥ របស់ CDRI ដែលបានរចនារៀបចំឡើងដើម្បីអនាគតប្រកបដោយចីរភាពនៃ CDRI ក្នុងពេលដែលប្រទេសកម្ពុជាកំពុងផ្លាស់ប្ដូរទៅមុខ។ ឯកសារព្រាងនេះគ្រោងរៀបចំឲ្យស្រេចបាច់សម្រាប់ដាក់ជូន ក្រុមប្រឹក្សាភិបាលទាំងមូលអនុម័ត ក្នុងកិច្ចប្រជុំលើកក្រោយ នៅខែកុម្ភៈ ២០១៣។ ទន្ទឹមគ្នានេះ វិទ្យាស្ថាន CDRI បាននិងកំពុងបន្តពិនិត្យតាមដាន និងបង្កើតឱកាសល្អៗ ដើម្បីកសាងភាពជាដៃគូផ្នែកធនធានថ្មីៗ និងកាន់តែស៊ីជម្រៅ ជាមួយទីភ្នាក់ងារអភិវឌ្ឍន៍ និងស្ថាប័នដ៏ជាក់លាក់ជាច្រើនទៀត។

នៅខែកញ្ញា នាយកប្រតិបត្តិនៃវិទ្យាស្ថាន CDRI បានទៅចូលរួមម្ដងទៀតក្នុង វេទិកាវិទ្យាស្ថានអាស៊ីបូព៌ាប្រចាំឆ្នាំ នៃវិទ្យាស្ថានកូរ៉េសម្រាប់គោលនយោបាយសេដ្ឋកិច្ចអន្តរជាតិ (KIEP) ដែលនៅឆ្នាំនេះបានធ្វើឡើងនៅទីក្រុងវៀងចន្ទន៍ ប្រទេសឡាវ ដោយផ្ដោតលើប្រធានបទស្ដីពី សមាហរណកម្មសេដ្ឋកិច្ចនៅអាស៊ីបូព៌ា និងកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍៖ ការវាយតម្លៃ និងកិច្ចការទៅអនាគត។ លោកនាយកប្រតិបត្តិ បានរួមចំណែកធ្វើបទបង្ហាញមួយស្ដីពី កិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍នៅអាស៊ីបូព៌ាទៅអនាគត៖ តើប្រទេសលូតលាស់តិចជាងគេ ដូចជា កម្ពុជា ឡាវ និងមីយ៉ាន់ម៉ា ត្រូវការអ្វីខ្លាំងជាងគេ ពីកិច្ចសហប្រតិបត្តិការនេះ?

(តទៅទំព័រ ២២)

ទស្សនាវដ្ដី អភិវឌ្ឍន៍កម្ពុជា

ឯកសារបោះពុម្ពផ្សាយរបស់
វិទ្យាស្ថានបណ្ដុះបណ្ដាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា

ឆ្នាំទី១៦ លេខ៣ ខែតុលា ឆ្នាំ២០១២

*ទស្សនាវដ្ដីអភិវឌ្ឍន៍កម្ពុជា* បោះពុម្ពផ្សាយដោយ វិទ្យាស្ថានបណ្ដុះបណ្ដាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា នៅភ្នំពេញចំនួន ៤ដង ក្នុងមួយឆ្នាំជាភាសាខ្មែរ និងភាសាអង់គ្លេសនៅពេលដំណាលគ្នា ។

*ទស្សនាវដ្ដីអភិវឌ្ឍន៍កម្ពុជា* ផ្ដល់ជាវេទិកាមួយ ដើម្បីពិភាក្សាពីបញ្ហាអភិវឌ្ឍន៍ដែលកំពុងតែជះឥទ្ធិពលដល់ប្រទេសកម្ពុជា ។ អត្ថបទតាមដានសេដ្ឋកិច្ច ផ្ដល់ជូននូវមូលវិចារឯករាជ្យស្ដីពីដំណើរការនៃសេដ្ឋកិច្ចប្រទេសកម្ពុជា ។

*ទស្សនាវដ្ដីអភិវឌ្ឍន៍កម្ពុជា* ស្វាគមន៍អត្ថបទទាំងឡាយពីប្រិយមិត្តអ្នកអាន ។ លិខិត ត្រូវចុះហត្ថលេខា អាចផ្ទៀងផ្ទាត់បាន មានលេខទូរស័ព្ទ និងអាសយដ្ឋាន ។ អ្នកនិពន្ធ ត្រូវទាក់ទង វបសអ មុននឹងផ្ដល់អត្ថបទ ទោះជាឯកសារនោះមិនទាន់រៀបរយក៏ដោយ ។ ឯកសារទាំងអស់នឹងត្រូវកែសម្រួលសម្រាប់ការបោះពុម្ព ។ វបសអ សូមរក្សាសិទ្ធិបដិសេធការបោះពុម្ព ដោយមិនចាំបាច់បញ្ជាក់ពីហេតុផល ។

វិទ្យាស្ថានបណ្ដុះបណ្ដាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា
☛ អាសយដ្ឋាន ៥៦ ផ្លូវ ៣១៥ ទួលគោក ភ្នំពេញ កម្ពុជា
✉ ប្រអប់សំបុត្រលេខ ៦២២ ភ្នំពេញ កម្ពុជា
☎ (៨៥៥-២៣) ៨៨១-៧០១, ៨៨១-៩១៦, ៨៨៣-៦០៣ 🖷 (៨៥៥-២៣) ៨៨០-៧៣៤
e-mail: cdri@cdri.org.kh
website: http://www.cdri.org.kh

9 789995 052065

គ្រឹះស្ថានផ្សាយៈ វបសអ
គ្រប់គ្រងកែសំរួលៈ យូ សិទ្ធិរិទ្ធ
កែសំរួលផលិតកម្មៈ អ៊ុំ ចាន់ថា និង ម៉េន ច័ន្ទធីតា
ជំនួយការកែសំរួលៈ ខេង សេង និង អ៊ឹង សុជាតិ
សហគ្រាសបោះពុម្ព ព្រីនម៉ាស្ទ័រ ភ្នំពេញ រូបភាពទំព័រមុខៈ រូបភាព វបសអ

© រក្សាសិទ្ធិ ២០១២ វិទ្យាស្ថានបណ្ដុះបណ្ដាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា
រក្សាសិទ្ធិគ្រប់យ៉ាង-គ្មានផ្នែកណាមួយនៃការបោះពុម្ពផ្សាយនេះត្រូវបានចំលងទុក ឬផ្សព្វផ្សាយតាមទម្រង់ និងមធ្យោបាយផ្សេងៗដូចជាៈ អេឡិចត្រូនិក យន្តកម្មថតចម្លង... ដោយគ្មានការអនុញ្ញាតជាលាយល័ក្ខណ៍អក្សរពី វបសអ ឡើយ ។

ISSN 1560-7615 / ISBN 978-99950-52-06-5

គំនិត ការលើកពីហេតុការណ៍ និងការបញ្ចេញយោបល់ទាំងឡាយនៅក្នុង *ទស្សនាវដ្ដីអភិវឌ្ឍន៍កម្ពុជា* ស្ថិតក្រោមការទទួលខុសត្រូវទាំងស្រុងរបស់អ្នកនិពន្ធ ។ ការបញ្ចេញយោបល់ និងការបកស្រាយទាំងនោះ មិនមែនជាទស្សនៈរបស់ *វបសអ* ទេ ។

រាល់ឯកសារបោះពុម្ពផ្សាយរបស់វិទ្យាស្ថាន CDRI មានផ្ដល់ជូនដោយឥតគិតថ្លៃតាមរយៈគេហទំព័រៈ http://www.cdri.org.kh